# ជីវិត ដោយសារការសុគតរបស់ទ្រង់

# ជីវិត ដោយសារការសុគតរបស់ទ្រង់

សៀវភៅនេះគឺជាសំណោរបង្រួមដ៏ងាយអាន ពីសៀវភៅដ៏ល្បីល្បាញមួយដែល
មានឈ្មោះថា

## ការស្លាប់របស់សេចក្តីស្លាប់នៅក្នុង
## ការសុគតរបស់ព្រះគ្រីស្ទ

ជាស្នាដៃនិពន្ធរបស់ បណ្ឌិត **ចន អូវ៉ិន** (ឆ្នាំ ១៦១៦-១៦៨៣)

រៀបរៀងដោយ **អេច ចេ អាពលប៊ី**

សរសេរអារម្ភកថាដោយ បណ្ឌិត **ចេ អាយ ផាកគ័រ**

អ្នកកែសំរួលទូទៅ **ចេ ខេ ដេវីស** បរិញ្ញាប័ត្រវិជ្ជាព្រះគម្ពីរ

© Grace Publications Trust
139 Grosvenor Avenue
LONDON N5 2NH
England
1992

Join managing editors:
J P Arthur MA
H J Appleby

Printed 1981 1992 1997

We gratefully acknowledge the help and encouragement receive from the Banner of Truth Trust (3 Murrayfield Road Edinburgh EH 12 6EL the publishers of the full version of "The Death of Death in the Death of Christ" from whom it is available.

ISBN 0 9505476 3 8

Distributed by:
EVANGELICAL PRESS
Grange Close
Faverdale Industrial Estate
Darlington
DL3 0PH
England

កម្មសិទ្ធិរបស់៖

**ក្រុមជំនុំមេត្តាករុណាព្រែកអំបិល**

បកប្រែដោយ៖

**លោក អ៊ុច អគ្គីរិន**

**លោក ហេល ម៉ៀល**

ផ្ទៀងផ្ទាត់អក្ខរាវិរុទ្ធខ្មែរដោយ៖

**លោក ឯម វណ្ណាថន**

**លោក អ៊ុច អគ្គីរិន**

**លោក ចាន់ សារ៉ាត**

រក្សាសិទ្ធិគ្រប់យ៉ាង

Copyright 2012

Special thanks to Grace Baptist Church in Madison, Alabama USA for their love, support, and commitment to advancing the Gospel in Cambodia.

**Contact Information:**

www.thechurchofmercy.org

info@thechurchofmercy.org

Cambodia:

Pastor Chheng Nuon

mmcchheng@yahoo.com

(+855) 12 662 710

USA:

Pastor Bill Hale

hale.bill@live.com

(+1) 972 977 82 61

**Church of Mercy Books**

Road 21 Prek Talay, Prek Ambel Saang, Kandal Cambodia

# មាតិកា


អារម្ភកថា

បុព្វកថា: បុព្វហេតុដែលសរសេរសៀវភៅនេះឡើង

សេចក្ដីផ្ដើម : តើសៀវភៅនេះនិយាយអំពីអ្វី?

ផ្នែកទី ១ : គោលបំណងរបស់ព្រះជាម្ចាស់ក្នុងការចាត់ ព្រះយេស៊ូវឲ្យមកសុគត

ផ្នែកទី ២ : គោលបំណងពិតនៃការសុគតរបស់ព្រះគ្រីស្ទ ហើយនិងអ្វីដែលទ្រង់បានសម្រេច

ផ្នែកទី ៣ : ការវែកញែក ១៦ចំណុចដែលបង្ហាញថាព្រះគ្រីស្ទមិនបានសុគតដើម្បីសង្គ្រោះមនុស្សទាំងអស់គ្រប់ៗរូបទេ

ផ្នែកទី ៤ : ការឆ្លើយតបទៅនឹងការវែកញែក អំពីសេចក្ដីប្រោសលោះជាសកល

# អារម្ភកថា

នេះជាសេចក្ដីសម្រង់ចេញពីសំណេរនៃសេចក្ដីផ្ដើមរបស់បណ្ឌិត J.I. Packer ចំពោះសៀវភៅ “ការស្លាប់របស់សេចក្ដីស្លាប់នៅក្នុងការសុគតរបស់ព្រះគ្រីស្ទ” (Death of Death in the Death of Christ) ដោយបណ្ឌិត J. Owen នៅក្នុងរោងពុម្ព the Banner of Truth Trust edition 1959។

“ការស្លាប់របស់សេចក្ដីស្លាប់នៅក្នុងការសុគតរបស់ព្រះគ្រីស្ទ” គឺជាកិច្ចការវែកញែកមួយដែលត្រូវបានរៀបចំឡើង ដើម្បីបង្ហាញ (នៅក្នុងចំណោមកិច្ចការជាច្រើនដទៃទៀត)ថា គោលលទ្ធិអំពីសេចក្ដីប្រោសលោះជាសកលគឺជាគោលលទ្ធិដែលប្រាសចាកពីបទគម្ពីរ ហើយជាគោលលទ្ធិដែលបំផ្លាញដល់ដំណឹងល្អ។ មានមនុស្សជាច្រើន ហាក់ដូចជាមិនសូវចាប់អារម្មណ៍នឹងវាទេ។ អស់អ្នកដែលយល់ឃើញថា មិនបាច់ត្រូវការភាពជាក់លាក់នៃគោលលទ្ធិនេះ ហើយនិងមិនមានពេលវេលាសម្រាប់ការវែកញែកខាងឯវិជ្ជាព្រះគម្ពីរដែលបង្ហាញឲ្យឃើញពីការមិនចុះសម្រុងគ្នា រវាងពួកគ្រីស្ទានអាចនឹងមានវិប្បដិសារីជាខ្លាំងចំពោះការលេចឡើងសារជាថ្មីម្ដងទៀតរបស់វា។ អ្នកខ្លះអាចនឹងភ្ញាក់ផ្អើលយ៉ាងខ្លាំងចំពោះសំណេររបស់ លោក ចន អូវ៉ិន ហើយពួកគេនឹងមិនព្រមអានសៀវភៅរបស់គាត់ទៀតផងដូច្នេះវាជាការរើសអើង និងជាការអំនួតយ៉ាងខ្លាំងចំពោះគំនិតនៃព្រះគម្ពីរ របស់យើង។ ប៉ុន្តែសង្ឃឹមថា ការបោះពុម្ពជាថ្មីនេះនឹងរកបានអ្នកអានដែលមានវិញ្ញាណមួយផ្សេងទៀតវិញ។ សព្វថ្ងៃនេះមានសញ្ញានានាកើនឡើងនៃការចាប់អារម្មណ៍ក្នុងព្រះគម្ពីរដូចជា ការត្រៀមខ្លួនថ្មីមួយដើម្បីធ្វើតេស្តលើទំនៀមទម្លាប់ ដើម្បីស្រាវជ្រាវបទគម្ពីរ ហើយនិងដើម្បីគិតពិចារណាពីសេចក្ដីជំនឿ។ សម្រាប់អស់អ្នកដែលត្រៀមខ្លួនយ៉ាងនេះ សូមណែនាំថាសៀវភៅរបស់ចន អូវ៉ិន ត្រូវបានផ្ដល់ឲ្យហើយ ហើយជឿជាក់ថា វានឹងជួយយើងក្នុងកិច្ចការដ៏បន្ទាន់បំផុតមួយ ដែលកំពុង

តែប្រឈមមុខនឹងពួកគ្រីស្ទានទាំងអស់នៅបច្ចុប្បន្ននេះ គឺការស្តារដំណឹងល្អពិតប្រាកដឡើងវិញ។

សំដីចុងក្រោយនេះអាចនឹងធ្វើឲ្យគេបើកភ្នែកធំៗ ប៉ុន្តែវាហាក់ដូចជារាប់ថាជាត្រឹមត្រូវគ្រប់គ្រាន់ទៅតាមសេចក្តីពិតវិញ។

ជាការពិតណាស់ សព្វថ្ងៃនេះការប្រកាសដំណឹងល្អ ស្ថិតនៅក្នុងសភាពនៃការច្របូកច្របល់ និងចម្រូងចម្រាស។ នៅក្នុងបញ្ហាជាច្រើនដូចជា ការអនុវត្តន៍នៃការប្រកាសដំណឹងល្អ ការបង្រៀនពីសេចក្តីបរិសុទ្ធ ការស្អាងជីវិតពួកជំនុំ ការងាររបស់គ្រូគង្វាលជាមួយវិញ្ញាណ និងការអនុវត្តន៍វិន័យ មានភស្តុតាងនៃការរីករាលដាលនៃការមិនពេញចិត្ត នឹងសេចក្តីជាច្រើន ព្រមទាំងភាពមិនប្រាកដប្រជាផ្សេងៗ។ នេះគឺជាបញ្ហាដ៏ស្មុកស្មាញមួយដែលមកពីកត្តាជាច្រើនផ្សំគ្នា ប៉ុន្តែប្រសិនបើយើងទៅឯឫសគល់នៃបញ្ហានេះ យើងនឹងរកឃើញថា ការច្របូកច្របល់ទាំងនេះគឺព្រោះតែមិនបានតោងជាប់ដំណឹងល្អតាមបទគម្ពីរ។ ដោយមិនដឹងខ្លួន ក្នុងកំឡុងមួយសតវត្សកន្លងទៅនេះ យើងបានដោះដូរដំណឹងល្អទៅយកផលិតផលថ្មីមួយជំនួសវិញ ដែលមើលទៅហាក់ដូចជាមានខ្លឹមសារប្រហាក់ប្រហែលគ្នា តែតាមពិតមានភាពផ្សេងគ្នាទាំងស្រុង។ ដូច្នេះ នេះហើយជាបញ្ហារបស់យើង ដ្បិតផលិតផលជំនួសនោះមិនបានឆ្លើយតបនឹងគោលបំណងដូចជាដំណឹងល្អពិតប្រាកដក្នុងអតីតកាល បានបង្ហាញថា វាមានអំណាចខ្លាំងណាស់នោះទេ។ ដំណឹងល្អថ្មី បានបរាជ័យក្នុងការបង្កើតឲ្យមានការគោរពដ៏ជ្រាលជ្រៅដល់ព្រះជាម្ចាស់ ការបន្ទាបខ្លួនវិញ្ញាណនៃការថ្វាយបង្គំ និងការព្រួយបារម្ភចំពោះក្រុមជំនុំ។ ហេតុអ្វី? យើងអាចនឹងវែកញែកថា ហេតុផលគឺនៅក្នុងលក្ខណៈនិងខ្លឹមសាររបស់វា។ វាបរាជ័យក្នុងការធ្វើឲ្យមនុស្សយកព្រះជាម្ចាស់ជាធំនៅក្នុងគំនិតរបស់ពួកគេ ហើយនិងការកោតខ្លាចនៅក្នុងចិត្តរបស់ពួកគេ ពីព្រោះតែការនេះមិនមែនជាការសំខាន់ដែលវាព្យាយាមចង់ធ្វើ។ ការខុសគ្នាមួយរបស់វា និងដំណឹងល្អចាស់គឺ វាមានការព្រួយ

បារម្ភចំពោះ “អត្ថប្រយោជន៍” ដល់មនុស្ស ដូចជាការនាំមកនូវសេចក្ដីសុខសាន្ត ការកំសាន្តចិត្ត សុភមង្គល ការស្កប់ចិត្ត ហើយព្រួយបារម្ភតែបន្តិចបន្តួចក្នុងការថ្វាយសិរីល្អដល់ព្រះ។ រីឯដំណឹងល្អពិតក៏មាន “អត្ថប្រយោជន៍” ដល់មនុស្សដែរ តែច្រើនជាងដំណឹងល្អថ្មីឆ្ងាយណាស់ ហើយការព្រួយបារម្ភរបស់វាទៀតសោត គឺតែងតែព្រួយបារម្ភពីការថ្វាយសិរីល្អដល់ព្រះជាម្ចាស់ជាទីមួយ។ វាតែងតែជាសេចក្ដីប្រកាសមួយនៃរាជអំណាចគ្រប់គ្រងរបស់ព្រះ ដោយសេចក្ដីមេត្តាករុណា និងសេចក្ដីជំនុំជម្រះ ហើយវាជាការកោះហៅមួយ ដើម្បីឲ្យមនុស្សបានមកក្រាបថ្វាយបង្គំដល់ព្រះដ៏មានគ្រប់អំណាចព្រះចេស្ដា ដែលទ្រង់ជាទីពឹងដល់មនុស្សសម្រាប់គ្រប់ទាំងសេចក្ដីល្អ ទាំងនិស្ស័យនិងព្រះគុណ។ ចំណុចសំខាន់របស់វាគឺយកព្រះជាទីមួយ។ ប៉ុន្តែនៅក្នុងដំណឹងល្អថ្មីវិញ ចំណុចសំខាន់គឺយកមនុស្សជាទីមួយ។ នេះមានន័យថាដំណឹងល្អចាស់ជាលក្ខណៈជំនឿដល់ព្រះ តែដំណឹងល្អថ្មីវិញមិនមែនទេ។ គោលបំណងសំខាន់នៃដំណឹងល្អចាស់ គឺដើម្បីបង្រៀនមនុស្សឲ្យចេះថ្វាយបង្គំដល់ព្រះ រីឯការព្រួយបារម្ភនៃដំណឹងល្អថ្មីវិញ ហាក់ដូចជាមានកំណត់ក្នុងការធ្វើឲ្យពួកគេមានអារម្មណ៍ល្អប្រសើរ។ ប្រធានបទនៃដំណឹងល្អចាស់ គឺអំពីព្រះនិងផ្លូវរបស់ទ្រង់ជាមួយនឹងមនុស្ស រីឯប្រធានបទនៃដំណឹងល្អថ្មីវិញ គឺអំពីមនុស្សនិងជំនួយដែលព្រះប្រទានឲ្យមនុស្ស។ វាមានលក្ខណៈខុសគ្នា ទាំងស្រុង។ គំនិតនិងការផ្ដោតយកចិត្តទុកដាក់នៃការប្រកាសដំណឹងល្អ បានផ្លាស់ប្ដូរហើយ។

ដោយសារតែការផ្លាស់ប្ដូរការចាប់អារម្មណ៍នេះ ធ្វើឲ្យលេចឡើងនូវការផ្លាស់ប្ដូរមួយនៃខ្លឹមសារដំណឹងល្អចាស់ ដ្បិតដំណឹងល្អថ្មីបានរៀបចំបទគម្ពីរជាថ្មីឡើងវិញ និងដាក់ឲ្យប្រើប្រាស់ជាធរមាន ដោយការចាប់អារម្មណ៍លើ “អត្ថប្រយោជន៍” ដែលគេស្មាន។ ដូច្នេះ គេមិនបានប្រកាសពីប្រធានបទដូចជា អំពីមនុស្សគ្មានសមត្ថភាពក្នុងការជឿលើព្រះជាម្ចាស់ អំពីការជ្រើសរើសដោយសេរីភាពយ៉ាងពេញទីរបស់ព្រះ ដែលទ្រង់ជាបុព្វហេតុតែមួយនៃសេចក្ដីសង្គ្រោះ ហើយនិង

ព្រះគ្រីស្ទបានសុគតជាពិសេសសម្រាប់ចៀមរបស់ទ្រង់ទេ។ គេនឹងអាចនិយាយថា គោលលទ្ធិទាំងនេះមិនមាន "អត្ថប្រយោជន៍" ទេ ហើយពួកគេនឹងជំរុញឲ្យមនុស្សមានបាបទៅកាន់ភាពអស់សង្ឃឹម នៅពេលដែលពួកគេត្រូវបានប្រាប់ថាមិនមែនជាអំណាចរបស់ពួកគេផ្ទាល់ទេ ដើម្បីឲ្យគេបានសង្គ្រោះតាមរយៈព្រះគ្រីស្ទនោះ (គេមិនបានពិចារណាថា ភាពអស់សង្ឃឹមនោះ អាចជាលទ្ធភាពជំរុញឲ្យបានប្រសើរឡើងទេ ហើយគេស្មានថា វាមិនអាចជាយ៉ាងដូច្នេះបាន ពីព្រោះវាជាការភ្ញាក់ផ្អើលនិងអាក់អន់ស្រពន់ចិត្តដល់ទំនុកចិត្តនិងតម្លៃរបស់ខ្លួនគេ)។ ទោះបីជាការនេះអាចទៅរួចក៏ដោយ (យើងនឹងនិយាយរឿងនេះនៅពេលក្រោយទៀត) លទ្ធផលនៃការលប់ចោលទាំងនេះ គឺជាការលប់ចោលផ្នែកនៃដំណឹងល្អតាមព្រះគម្ពីរ ហើយដំណឹងល្អដែលគេលប់ចោលផ្នែកនៃដំណឹងល្អតាមព្រះគម្ពីរនេះ ត្រូវបានគេប្រកាសប្រៀបបីដូចជាប្រកាសផ្នែកទាំងស្រុងនៃដំណឹងល្អតាមព្រះគម្ពីរអញ្ចឹង។ ហើយសេចក្តីពិតតែពាក់កណ្តាលដែលធ្វើពើជាសេចក្តីពិតទាំងស្រុងនេះក្លាយទៅជាសេចក្តីមិនពិតទាំងស្រុងវិញ។ ដូច្នេះយើងលើកដំកើងដល់មនុស្សប្រៀបបីដូចជាពួកគេមានសមត្ថភាពក្នុងការទទួលព្រះគ្រីស្ទនៅពេលណាក៏បានអញ្ចឹង ហើយយើងនិយាយពីការងារប្រោសលោះរបស់ទ្រង់ ប្រៀបបីដូចជាទ្រង់មិនបានធ្វើអ្វីទៀតដោយការសុគត ក្រៅពីធ្វើឲ្យមានលទ្ធភាពសម្រាប់យើងដើម្បីឲ្យបានសង្គ្រោះតាមរយៈការជឿ ហើយយើងនិយាយពីសេចក្តីស្រឡាញ់របស់ព្រះប្រៀបបីដូចវាជាការស្ម័គ្រចិត្តទូទៅមួយ ដើម្បីទទួលអស់អ្នកដែលបែរមក និងទុកចិត្តដល់ទ្រង់ ហើយយើងពិពណ៌នាព្រះវរបិតា និងព្រះរាជបុត្រាថាទ្រង់មិនមានសកម្មភាពគ្រប់គ្រងទាំងស្រុង នៅក្នុងកិច្ចការទាញមនុស្សមានបាបមកឯទ្រង់ទេ តែទ្រង់គ្រាន់តែរង់ចាំយើងដោយស្ងៀមស្ងាត់នៅឯ "ទ្វាចិត្តរបស់យើង" ដើម្បីឲ្យយើងបើកទ្វាចិត្តនោះឲ្យទ្រង់ចូលប៉ុណ្ណោះ។ ជាការពិតណាស់ របៀបនេះហើយគឺជារបៀបដែលយើងប្រកាសដំណឹងល្អ ហើយរបៀបនេះទៀតសោត ប្រហែលជាអ្វីដែលយើងជឿ ផងមិនដឹង។ ប៉ុន្តែយើងត្រូវតែនិយាយដោយម៉ឺងម៉ាត់ថា សេចក្តី

ពិតតែពាក់កណ្ដាលដែលត្រូវបានគេបំភ្លៃនេះ គឺជាអ្វីម្យ៉ាងដែលខុសពីដំណឹងល្អតាមព្រះគម្ពីរ។ ព្រះគម្ពីរប្រឆាំងនឹងយើង នៅពេលដែលយើងប្រកាសដំណឹងល្អតាមរបៀបនេះ ហើយ ការប្រកាសដំណឹងល្អដែលបានក្លាយស្ទើរតែជាខ្នាតអនុវត្តសម្រាប់យើងរាល់គ្នានេះ បង្ហាញបានតែភាពចាំបាច់បន្ទាន់ ដែលយើងរាល់គ្នាត្រូវពិនិត្យលើបញ្ហានេះឡើងវិញប៉ុណ្ណោះ។ ការឲ្យបានត្រឡប់ទៅជាដំណឹងល្អចាស់ដែលជាដំណឹងល្អដ៏ពិតប្រាកដតាមបទគម្ពីរវិញហើយនិងការនាំការបង្រៀន និងការអនុវត្តន៍របស់យើងត្រឡប់ទៅតាមដំណឹងល្អចាស់វិញ គឺប្រហែលជាតម្រូវការដ៏ចាំបាច់បំផុតរបស់យើងនៅពេលនេះ។ ដោយហេតុនេះហើយបានជាសំណេររបស់លោក អូវិន អំពីការប្រោសលោះ អាចនឹងជួយយើងបាន។

# **បុព្វកថា**

*បុព្វហេតុដែលសរសេរសៀវភៅនេះឡើង*

ខ្ញុំសូមពន្យល់ពីមូលហេតុដែលខ្ញុំសរសេរសៀវភៅនេះឡើង។ ខ្ញុំជាមនុស្សមិនចូលចិត្តនឹងការវែកញែកទេ! ប៉ុន្តែព្រះគម្ពីរចែងថា យើងត្រូវ “ខំតយុទ្ធ ដើម្បីការពារសេចក្តីជំនឿដែលបានប្រគល់មកពួកបរិសុទ្ធ” (យូដាស ១:៣)។ ថ្មីៗនេះ ខ្ញុំបានពិគ្រោះគ្នាជាញឹកញាប់អំពីប្រធានបទនៃសៀវភៅនេះ។ ហើយខ្ញុំឮថា បញ្ហាទាំងនេះកំពុងតែត្រូវបានគេធ្វើការវែកញែកនៅគ្រប់ទីកន្លែងទូទាំងប្រទេស។ ដូច្នេះ ខ្ញុំក៏មានការជឿជាក់ក្នុងការសរសេរសៀវភៅមួយក្បាលនេះឡើង។ ខ្ញុំគួរតែទុកការងារនេះដល់ម្នាក់ផ្សេងទៀតជាអ្នកធ្វើ ប៉ុន្តែខ្ញុំមានអារម្មណ៍ថា ខ្ញុំគួរតែធ្វើការងារនេះវិញប្រសើរជាងអត់ធ្វើអ្វីសោះ!

ខ្ញុំមិនបានប្រកាសថាខ្លួនខ្ញុំជាអ្នកល្អជាងគេ ក្នុងការសរសេរសៀវភៅបែបនេះនោះទេ។ អ្នកដទៃទៀតក៏បានសរសេរឡើងយ៉ាងល្អលើប្រធានបទដូចគ្នានេះដែរ ប៉ុន្តែខ្ញុំបានសម្គាល់ឃើញថា ពួកគេបានដាក់កម្រិតខ្លួនឯងចំពោះចំណុចខ្លះនៃការវែកញែកនោះ។ ហើយខ្ញុំបានគិតថា ខ្ញុំនឹងមិនគ្រាន់តែនិយាយពីអ្វីដែលព្រះគ្រីស្ទមិនបានធ្វើដោយការសុគតរបស់ទ្រង់ប៉ុណ្ណោះទេ ប៉ុន្តែត្រូវពន្យល់ឲ្យបានពេញលេញនូវអ្វីដែលទ្រង់បានធ្វើផងដែរ។

រយៈពេល៧ឆ្នាំដែលខ្ញុំបានសិក្សាប្រធានបទនេះ គឺសិក្សាទាំងនៅក្នុងព្រះគម្ពីរ និងនៅក្នុងសៀវភៅផ្សេងៗដទៃទៀតដែរ។ ដូច្នេះ តើខ្ញុំអាចស្នើសុំ សូមឲ្យបងប្អូនអានសៀវភៅនេះដោយប្រុងប្រយ័ត្នផងបានទេ? ប្រសិនបើអ្នកណាម្នាក់ ចង់បង្ហាញចំណុចនិមួយៗនៅក្នុងបរិបទនៃសៀវភៅនេះថាមិនត្រឹមត្រូវ នោះខ្ញុំអនុញ្ញាតដល់អ្នកនោះធ្វើ ដើម្បីបំពេញភាពជោគជ័យដ៏ស្រមើស្រមៃរបស់ពួកគេចុះ។ ប៉ុន្តែប្រសិនបើនរណាម្នាក់សិក្សាសៀវភៅនេះទាំងមូលដោយយកចិត្តទុកដាក់ នោះខ្ញុំ

គិតថា សៀវភៅនេះនឹងធ្វើឲ្យពួកគេមានការជឿជាក់ជាមិនខាន។

ខ្ញុំសង្ឃឹមថា សៀវភៅនេះនឹងផ្តល់ភាពពេញចិត្តពេញថ្លើមដល់អស់អ្នកដែលស្គាល់សេចក្តីពិតទាំងនេះ ដែលជាកំលាំងដល់អស់អ្នកដែលខ្សោយនៅក្នុងចំណោមនោះ។ លើសពីនោះទៀតគឺដើម្បីថ្វាយសិរីល្អដល់ព្រះអម្ចាស់ដែលការទាំងនោះជាសេចក្តីពិតរបស់ទ្រង់ ទោះបីខ្ញុំជាបាវបម្រើដ៏តូចទាបបំផុតរបស់ទ្រង់ក៏ដោយ។

ចន អូវ៉ិន ១៦៨៨

# សេចក្តីផ្តើម

*តើសៀវភៅនេះនិយាយអំពីអ្វី?*

ព្រះគម្ពីរថែងថា ការសុគតរបស់ព្រះយេស៊ូវគ្រីស្ទ គឺប្រៀបដូចជាការសងថ្លៃមួយ ដើម្បីដោះលែងមនុស្សឲ្យរួចពីអំពើបាប។ នោះមិនមានបញ្ហាអ្វីទេ ប៉ុន្តែដែលជាបញ្ហានោះគឺថា តើការសុគតរបស់ព្រះគ្រីស្ទបានដោះលែងមនុស្សទាំងអស់គ្រប់ៗរូបឲ្យរួចពីអំពើបាបឬទេ? ឬក៏ដោះលែងតែមនុស្សមួយចំនួន? ពួកគ្រីស្ទបរិស័ទក៏មានទស្សនៈរបស់ពួកគេរៀងៗខ្លួនដែរ។ អ្នកខ្លះនិយាយអញ្ចេះ អ្នកខ្លះនិយាយអញ្ចុះ។ ដូច្នេះ តើព្រះគម្ពីរនិយាយថាយ៉ាងដូចម្តេច? នោះគឺជាអ្វីដែលយើងត្រូវការស្វែងយល់។

ប្រសិនបើយើងនិយាយថា ការសុគតរបស់ព្រះគ្រីស្ទគឺសម្រាប់មនុស្សទាំងអស់គ្រប់ៗរូប នោះមានន័យថា ក្នុងពេលដំដែលនេះយើងមិនអាចនិយាយថាការសុគតរបស់ព្រះគ្រីស្ទគឺសម្រាប់អស់អ្នកដែលព្រះបានជ្រើសរើសតែប៉ុណ្ណោះទេ។ ប្រសិនបើព្រះគ្រីស្ទបានសុគតសម្រាប់មនុស្សទាំងអស់ នោះព្រះប្រហែលជាទ្រង់មិនត្រូវការជ្រើសរើសមនុស្សពិសេសមួយក្រុមទេ មែនទេ? ម្យ៉ាងវិញទៀត បើយើងនិយាយថា ព្រះបានជ្រើសរើសមនុស្សពិសេសមួយក្រុម (ដូចដែលព្រះគម្ពីរបានបង្រៀន) នោះវានឹងទៅជាឥតន័យ ដែលព្រះគ្រីស្ទត្រូវសុគតសម្រាប់មនុស្សទាំងអស់ មែនទេ?

ប្រសិនបើនិយាយថា ការសុគតរបស់ព្រះគ្រីស្ទគឺជាថ្លៃលោះ ឬការសងថ្លៃមួយសម្រាប់មនុស្សទាំងអស់ នោះមានន័យថា៖

១. មនុស្សទាំងអស់ច្បាស់ជាមានអំណាចក្នុងការទទួល ឬបដិសេធថ្លៃលោះសម្រាប់ខ្លួនរបស់ពួកគេ។

២. មនុស្សទាំងអស់ត្រូវបានលោះដោយសារព្រះគ្រីស្ទ មិនថាពួកគេស្គាល់ថ្លៃលោះនោះ ឬក៏អត់។

ការសុគតរបស់ព្រះគ្រីស្ទសម្រាប់មនុស្សទាំងអស់គ្រប់ៗគ្នា អាចជាការពិត ប្រសិនបើការលើកឡើងណាមួយខាងលើនេះពិត។ ប៉ុន្តែការលើកឡើងទីមួយ បានបដិសេធនឹងការបង្រៀនរបស់ព្រះគម្ពីរហើយ ដ្បិតមនុស្សដែលស្លាប់ដោយគ្មានសង្ឃឹមនៅក្នុងអំពើបាប មិនមានអំណាចក្នុងការចូលមកឯព្រះគ្រីស្ទទេ។ រីឯការលើកឡើងទីពីរ ក៏បានបដិសេធនឹងការបង្រៀនរបស់ព្រះគម្ពីរដែរ ដ្បិតមនុស្សខ្លះនឹងបាត់បង់ជារៀងរហូត។ ជាក់ស្តែង មានការលំបាកធ្ងន់ធ្ងរអំពីការដែលគេលើកឡើងថា ការសុគតរបស់ព្រះគ្រីស្ទគឺសម្រាប់មនុស្សទាំងអស់គ្រប់ៗគ្នា។

អញ្ចឹងចុះហេតុអ្វីបានជាមនុស្សមួយចំនួននិយាយថា ការសុគតរបស់ព្រះគ្រីស្ទគឺសម្រាប់មនុស្សគ្រប់ទាំងអស់ទៅវិញ? វាហាក់ដូចជាមានហេតុផលដែលអាចទៅរួចប្រាំ៖

១. វាហាក់ដូចជាធ្វើឲ្យព្រះជាម្ចាស់ត្រូវបានគេ “ចាប់អារម្មណ៍” កាន់តែខ្លាំងឡើង ប្រសិនបើគេនិយាយថា ការសុគតរបស់ព្រះគ្រីស្ទគឺសម្រាប់មនុស្សទាំងអស់គ្រប់ៗគ្នា។

២. វាហាក់ដូចជាធ្វើឲ្យសេចក្តីស្រឡាញ់របស់ព្រះកាន់តែ “ធំជាងមុន” ប្រសិនបើពួកគេនិយាយថា ទ្រង់ស្រឡាញ់មនុស្សទាំងអស់ស្មើៗគ្នា។

៣. វាហាក់ដូចជាធ្វើឲ្យការសុគតរបស់ព្រះគ្រីស្ទកាន់តែ “មានតម្លៃ” ប្រសិនបើ ពួកគេអាចនិយាយថា ការសុគតរបស់ព្រះគ្រីស្ទជាការសងថ្លៃមួយសម្រាប់អំពើបាបរបស់មនុស្សទាំងអស់។

៤. ព្រះគម្ពីរហាក់ដូចជាប្រើពាក្យ “ទាំងអស់” និង “លោកិយ” សំដៅលើ “មនុស្សទាំងអស់”។

៥. អ្នកខ្លះអាចនឹងគ្រាន់តែនិយាយថា ការសុគតរបស់ព្រះគ្រីស្ទគឺសម្រាប់មនុស្សទាំងអស់ ដូច្នេះគេអាចរួមបញ្ចូលទាំងពួកគេដែរ ទោះបីជាពួកគេមិនចង់ផ្លាស់ប្រែរបៀប ទមិទ្យល្មើស ដែលពួកគេកំពុងតែរស់នៅក៏ដោយ។

នៅក្នុងសៀវភៅនេះ៖

យើងនឹងឃើញពីមូលហេតុខុសឆ្គងទាំងប្រាំនេះ ហើយនិងអ្វីដែលព្រះគម្ពីរបង្រៀនអំពីគោលបំណងនៃការសុគតរបស់ព្រះយេស៊ូវគ្រីស្ទ។

# ផ្នែកទី ១

*គោលបំណងរបស់ព្រះជាម្ចាស់ក្នុងការចាត់ព្រះយេស៊ូវឲ្យមកសុគត*

**ជំពូក**

១. ការណែនាំបញ្ហា

២. អ្នកណា? របៀបណា? ហើយការនោះគឺជាអ្វី?

៣. ព្រះវរបិតា ជាអ្នកផ្ដើមនៃសេចក្ដីសង្គ្រោះរបស់យើង

៤. ព្រះរាជបុត្រា ជាអ្នកផ្ដើមនៃសេចក្ដីសង្គ្រោះរបស់យើង

៥. ព្រះវិញ្ញាណ ជាអ្នកផ្ដើមនៃសេចក្ដីសង្គ្រោះរបស់យើង

៦. កិច្ចការរបស់ព្រះគ្រីស្ទ គឺជាមធ្យោបាយដែលប្រើដើម្បីឲ្យយើងទទួល បាន សេចក្ដីសង្គ្រោះ

៧. ការថ្វាយជង្វាយនៃរូបអង្គព្រះគ្រីស្ទ និងការអង្វរជំនួសរបស់ទ្រង់ គឺ ជាមធ្យោបាយតែមួយគត់ ដើម្បីឲ្យសេចក្ដីសង្គ្រោះរបស់យើងបាន សម្រេច

(ផ្នែកទី២ សិក្សាលំអិតនូវអ្វីដែលព្រះគ្រីស្ទទទួលបានយ៉ាងពិតប្រាកដ ដោយការសុគតរបស់ទ្រង់)

# ជំពូក ១

*ការណែនាំបញ្ញា*

ព្រះគ្រីស្ទផ្ទាល់បានមានបន្ទូលដល់យើង ពីមូលហេតុដែលទ្រង់បានយាងមកក្នុងលោកិយនេះ។ ទ្រង់បានមានបន្ទូលថា "ដ្បិតកូនមនុស្សបានមក ដើម្បីនឹងរក ហើយជួយសង្គ្រោះដល់មនុស្សបាត់បង់" (លូកា ១៩:១០)។ ហើយទ្រង់ក៏មានបន្ទូលដែរថា កូនមនុស្សបានមក "នឹងឲ្យជីវិតខ្លួនទុកជាថ្លៃលោះដល់មនុស្សជាច្រើន" (ម៉ាកុស ១០:៤៥)។

សាវ័ក ប៉ុល ក៏បានបញ្ជាក់យ៉ាងច្បាស់ ពីមូលហេតុដែលទ្រង់យាងមកក្នុងលោកិយនេះផងដែរថា "ដែលទ្រង់បានប្រគល់ព្រះអង្គទ្រង់ទៅ ដោយព្រោះបាបយើងរាល់គ្នាដើម្បីនឹងប្រោស ឲ្យយើងបានរួចពីលោកិយដ៏អាក្រក់សព្វថ្ងៃនេះ" (កាឡាទី ១:៤)។ "ព្រះយេស៊ូវគ្រីស្ទទ្រង់បានយាងមកក្នុងលោកិយ ដើម្បីនឹងជួយសង្គ្រោះមនុស្សមានបាប" (១ធីម៉ូថេ ១:១៥)។ "ដែលទ្រង់បានថ្វាយព្រះអង្គទ្រង់ជំនួសយើងរាល់គ្នា ដើម្បីនឹងលោះយើងឲ្យរួចពីគ្រប់ទាំងសេចក្តីទទឹងច្បាប់ ហើយនិងសម្អាតមនុស្សមួយពួក ទុកដាច់ជារាស្ត្ររបស់ផងទ្រង់ ដែលឧស្សាហ៍ធ្វើការល្អ" (ទីតុស ២:១៤)។

តាមរយៈព្រះបន្ទូលខាងលើនេះ វាបានបញ្ជាក់យ៉ាងច្បាស់ថា គោលបំណងនៃការសុគតរបស់ទ្រង់គឺ៖

- ដើម្បីសង្គ្រោះមនុស្សឲ្យរួចពីបាប
- ដើម្បីប្រោសមនុស្សឲ្យរួចពីលោកិយដ៏អាក្រក់នេះ
- ដើម្បីធ្វើឲ្យមនុស្សបានបរិសុទ្ធ
- ដើម្បីបង្កើតមនុស្សដែលធ្វើការល្អ

បទគម្ពីរផ្សេងទៀតពន្យល់ពីអ្វីដែលព្រះយេស៊ូវគ្រីស្ទ បានធ្វើនៅក្នុងការសុគតរបស់ទ្រង់។ មានការប្រាំយ៉ាងដែលយើងធ្វើការកត់សម្គាល់ដូចខាង ក្រោមៈ

១. មនុស្សបានជាមេត្រីនឹងព្រះ ដោយសារការសុគតរបស់ទ្រង់ (រ៉ូម ៥:១)

២. មនុស្សទទួលការអត់ទោស និងការរាប់ជាសុចរិត ដោយសារការសុគតរបស់ទ្រង់ (រ៉ូម ៣:២៤)

៣. មនុស្សត្រូវបានធ្វើឲ្យស្អាត ហើយបរិសុទ្ធ ដោយសារការសុគតរបស់ទ្រង់ (ហេព្រើរ ៩:១៤)

៤. មនុស្សត្រូវបានយកមកចិញ្ចឹមជាកូនរបស់ព្រះ ដោយសារការសុគតរបស់ទ្រង់ (កាឡាទី ៤:៤-៥)

៥. មនុស្សបានទទួលសិរីរុងរឿង និងជីវិតអស់កល្បជានិច្ច ដោយសារការសុគតរបស់ទ្រង់ (ហេព្រើរ ៩:១៥)

យោងតាមភស្តុតាងខាងលើ ការបង្រៀនរបស់ព្រះគម្ពីរបង្ហាញយ៉ាងច្បាស់ថា ការសុគតរបស់ព្រះគ្រីស្ទគឺដើម្បីនាំឲ្យមនុស្សបានទទួលនូវការអត់ទោសពេលបច្ចុប្បន្ននេះ និងសិរីរុងរឿងដែលនឹងត្រូវមក។ ដូច្នេះប្រសិនបើព្រះគ្រីស្ទបានសុគតសម្រាប់មនុស្សទាំងអស់គ្រប់ៗគ្នា នោះមានន័យថាឥឡូវនេះមនុស្សទាំងអស់សុទ្ធតែបានរួចពីបាប ហើយបានទទួលការអត់ទោសបាប ព្រមទាំងត្រូវបានដំកើងឡើងហើយ ឬមួយក៏ព្រះគ្រីស្ទបានបរាជ័យក្នុងគោលបំណងរបស់ទ្រង់។

តាមរយៈបទពិសោធន៍ប្រចាំថ្ងៃរបស់មនុស្ស យើងដឹងថា ចំណុចទីមួយមិនពិតទេ។ រីឯការលើកឡើងទីពីរ ដែលថាព្រះគ្រីស្ទបានទទួលបរាជ័យ នោះគឺជាការត្មះតិះដៀលដល់ព្រះជាម្ចាស់ទៅវិញ។

ដើម្បីឲ្យរួចផុតពីការទទួលយកបញ្ហាណាមួយ នៃគំនិតទាំងពីរខាងលើនេះពួកអ្នកដែលនិយាយថាព្រះគ្រីស្ទបានសុគតសម្រាប់មនុស្សទាំងអស់ បាននិយាយថា វា

មិនមែនជាគោលបំណងរបស់ព្រះជាម្ចាស់ទេ ដែលមនុស្សទាំងអស់បានទទួលអត្ថប្រយោជន៍នោះ។ ពួកគេនិយាយថា អត្ថប្រយោជន៍នោះគឺសម្រាប់តែអស់អ្នកណាដែលបង្កើតសេចក្តីជំនឿមួយ ដើម្បីជឿដល់ព្រះគ្រីស្ទប៉ុណ្ណោះ។ កិច្ចការនៃសេចក្តីជំនឿនេះ គឺជាអ្វីមួយដែលមនុស្សទាំងនោះធ្វើដោយខ្លួនឯង នោះហើយដែលធ្វើឲ្យពួកគេមានលក្ខណៈខុសពីមនុស្សដទៃទៀត។ (ប្រសិនបើសេចក្តីជំនឿត្រូវបានទទួលមកដោយសារការសុគតរបស់ព្រះគ្រីស្ទ ហើយប្រសិនបើទ្រង់សុគតសម្រាប់មនុស្សទាំងអស់មែន នោះមានន័យថា មនុស្សទាំងអស់សុទ្ធតែមានសេចក្តីជំនឿហើយ!)។ ចំពោះខ្ញុំ ការលើកឡើងនេះហាក់ដូចជា ធ្វើឲ្យអ្វីដែលព្រះគ្រីស្ទបានទទួលមកដោយសារការសុគតរបស់ទ្រង់ មិនសូវមានតម្លៃទៅវិញ ដូច្នេះខ្ញុំសូមជំទាស់នឹងការលើកឡើងនេះ ដោយបង្ហាញថាអ្វីដែលព្រះគម្ពីរបង្រៀនគឺខុសពីការលើកឡើងនោះ។

## ជំពូក ២

*អ្នកណា? របៀបណា? ហើយការនោះគឺជាអ្វី?*

មានពាក្យបីដែលយើងនឹងប្រើច្រើនឯងនៅក្នុងសៀវភៅនេះ។ ហើយសៀវភៅនេះនឹងជួយណែនាំពីពាក្យទាំងនេះដោយត្រួសៗ ដូចតទៅនេះ៖ នៅពេលដែលសកម្មភាពណាមួយកើតឡើង គឺមានអ្នកផ្តើមសកម្មភាពម្នាក់(អ្នកធ្វើអំពើ) ហើយនិងមានការប្រើប្រាស់មធ្យោបាយ(របៀបឲ្យវាបានសម្រេច) ព្រមទាំងមានគោលបំណងមួយ (អ្វីមួយដែលជាលទ្ធផលចុងក្រោយ)។

យើងជ្រើសរើសវិធីក្នុងការធ្វើអ្វីមួយ (មធ្យោបាយ) ដោយយោងទៅតាមអ្វីមួយ

ដែលយើងចង់បាន (គោលបំណង)។ ដូច្នេះយើងអាចនិយាយបានថា គោលបំណង គឺជាហេតុផលសម្រាប់មធ្យោបាយ។ ប្រសិនបើយើងបានជ្រើសរើសមធ្យោបាយត្រឹមត្រូវ នោះគោលបំណងគឺជាក់លាក់ ។ ដូច្នេះយើងអាចនិយាយបានថា មធ្យោបាយគឺជាបុព្វហេតុនៃគោលបំណង។ ជាការពិតណាស់ ប្រសិនបើអ្នកផ្តើម បានជ្រើសរើសមធ្យោបាយដ៏ត្រឹមត្រូវក្នុងការធ្វើអ្វីមួយ នោះគាត់នឹងមិនអាចបរាជ័យឡើយ!

ឥឡូវនេះ យើងអាចប្រើប្រាស់គោលការណ៍នេះទៅលើការពិភាក្សារបស់យើងនៅក្នុងសៀវភៅនេះ។ ជាដំបូងយើងគួរដឹងថា អ្នកផ្តើមដែលចង់ប្រោសលោះយើងជានរណាសិន។ បន្ទាប់មកយើងនឹងឃើញអ្វីដែលជាមធ្យោបាយសម្រាប់ប្រោសលោះយើង។ ហើយនៅចុងបញ្ចប់ (នៅផ្នែកទីពីរ) យើងនឹងឃើញថា អ្វីជាលទ្ធផលនៃមធ្យោបាយ ដែលបានប្រើប្រាស់នោះ។

យោងតាមព្រះគម្ពីរ អ្នកផ្តើមដែលចង់សង្គ្រោះយើងគឺជាព្រះត្រៃឯក។ ហើយគ្រប់ទាំងបុព្វហេតុឯទៃទៀត នោះគ្រាន់តែជាឧបករណ៍ដែលនៅក្នុងព្រះហស្តរបស់ទ្រង់ប៉ុណ្ណោះ (កិច្ចការ ៤:២៨)។ អ្នកផ្តើមដ៏ចម្បងនោះគឺជាព្រះត្រៃឯក។ ចូរយើងសិក្សាការនេះក្នុងសេចក្តីលម្អិតបន្ថែមទៀត...។

## ជំពូក ៣

*ព្រះវរបិតា ជាអ្នកផ្តើមនៃសេចក្តីសង្គ្រោះរបស់យើង*

ចំពោះសំណួរដែលសួរថា តើព្រះវរបិតាជាអ្នកផ្តើមសេចក្តីសង្គ្រោះ របស់យើងដោយរបៀបណា? ខ្ញុំសូមឆ្លើយថា មានពីររបៀបគឺ៖ ព្រះវរបិតាជាអ្នកចាត់

ព្រះរាជបុត្រាឲ្យមកសុគត ហើយព្រះវរបិតាបានដាក់ទោសព្រះគ្រីស្ទ ដោយព្រោះបាបរបស់យើងរាល់គ្នា។ យើងអាចពិនិត្យមើល ការទាំងពីរនេះ ឲ្យកាន់តែលម្អិតនៅខាងក្រោម៖

១. មានបទគម្ពីរជាច្រើនបានបញ្ជាក់យ៉ាងច្បាស់ថា ព្រះវរបិតាបានចាត់ព្រះរាជបុត្រាឲ្យមកក្នុងលោកិយនេះ។ ឧទាហរណ៍៖ “តែលុះវេលាកំណត់បានមកដល់ នោះព្រះទ្រង់បានចាត់ព្រះរាជបុត្រាទ្រង់ឲ្យមកប្រសូតពីស្ត្រីម្នាក់ក្រោមអំណាចនៃក្រឹត្យវិន័យ ដើម្បីឲ្យយើងបានទទួលសគុណទុកជាកូនចិញ្ចឹម” (កាឡាទី ៤:៤-៥)។ ការចាត់ព្រះរាជបុត្រាឲ្យមក បានពាក់ព័ន្ធនឹងព្រះវរបិតាក្នុងការបីយ៉ាងគឺ៖

ក. ទ្រង់មានគោលបំណងតាំងពីដើមរៀងមក នៅក្នុងគំនិតរបស់ ទ្រង់ (១ពេត្រុស ១: ២០)។

ខ. ទ្រង់បានប្រទានគ្រប់ទាំងសមត្ថភាពដល់ព្រះរាជបុត្រា ដែលទ្រង់បានចាត់ឲ្យទៅធ្វើការ (យ៉ូហាន ៣: ៣៤-៣៥)*។

គ. ទ្រង់បានសន្យាជាមួយព្រះរាជបុត្រាទ្រង់ថា ប្រទានគ្រប់ទាំង ជំនួយដែលត្រូវការ ដើម្បីឲ្យការងារនេះបានសម្រេចជោគជ័យ (កិច្ចការ ៤: ១០-១១)។

២. មានបទព្រះគម្ពីរជាច្រើន បានបញ្ជាក់យ៉ាងច្បាស់ថា ព្រះវរបិតា បានដាក់ទោសព្រះយេស៊ូវគ្រីស្ទ ដោយព្រោះអំពើបាបរបស់យើង។ ឧទាហរណ៍ “ដ្បិតឯព្រះអង្គដែលមិនបានស្គាល់បាបសោះ នោះព្រះទ្រង់បានធ្វើឲ្យត្រឡប់ជាតួបាប ជំនួសយើងរាល់គ្នាវិញ ដើម្បីឲ្យយើងរាល់គ្នាបានត្រឡប់ទៅជាសេចក្តីសុចរិតរបស់ព្រះដោយនូវព្រះអម្ចាស់នោះឯង” (២កូរិនថូស ៥: ២១)។ គេអាចនិយាយបានថាព្រះគ្រីស្ទបានរងទុក្ខហើយសុគតជំនួសយើងរាល់គ្នា។ អញ្ចឹង តើជាការចំឡែកឬទេដែលព្រះយេស៊ូវគួររងទុក្ខជំនួសអស់អ្នកដែលនឹងត្រូវរងទុក្ខដោយសារអំពើបាបរបស់ពួកគេផ្ទាល់ខ្លួននោះ?

យើងអាចដាក់បញ្ហាបានយ៉ាងដូច្នេះថា ព្រះគ្រីស្ទបានរងទុក្ខសម្រាប់៖

- គ្រប់ទាំងអំពើបាបរបស់មនុស្សទាំងអស់គ្រប់ៗរូប ឬក៏
- គ្រប់ទាំងអំពើបាបរបស់មនុស្សមួយចំនួន ឬក៏
- អំពើបាបខ្លះនៃមនុស្សទាំងអស់។

**ក្នុងនាមជាព្រះរាជបុត្រានៃព្រះ ទ្រង់បានគ្រប់លក្ខណ៍ជាព្រះរួចស្រេចទៅហើយ ប៉ុន្តែ ក្នុងនាមជាកូនមនុស្ស ព្រះជាម្ចាស់ត្រូវប្រទានអំណោយទាននានាដែលទ្រង់ត្រូវការជាចាំបាច់។*

ប្រសិនបើឃ្លាចុងក្រោយខាងលើនេះជាការពិត នោះមានន័យថា មនុស្សទាំងអស់នៅមានបាបខ្លះនៅឡើយ ហើយយ៉ាងនោះគ្មាននរណាម្នាក់អាចទទួលបានការប្រោសលោះទេ។

ប្រសិនឃ្លាទីមួយជាការពិត ចុះហេតុអ្វីបានជាមនុស្សទាំងអស់មិនរួចពីអំពើបាប? យើងអាចនិយាយថា ដោយព្រោះតែការមិនជឿរបស់ពួកគេ។ ប៉ុន្តែខ្ញុំសួរថា តើការមិនជឿជាអំពើបាបឬ? ប្រសិនបើវាមិនមែនជាអំពើបាបទេ ចុះហេតុអ្វីបានជាមនុស្សត្រូវទទួលទោសដោយព្រោះវាទៅវិញ? ហើយប្រសិនបើការមិនជឿជាអំពើបាបមែន នោះវាត្រូវតែស្ថិតនៅក្នុងចំណោមអំពើបាប ដែលព្រះគ្រីស្ទបានសុគតជំនួសនោះហើយ។ ដូច្នេះឃ្លាទីមួយ គឺមិនអាចពិតបានទេ!

ដូច្នេះវាបង្ហាញយ៉ាងច្បាស់ថា ឃ្លាដែលនៅសល់តែមួយប៉ុណ្ណោះ ដែលអាចទៅរួច គឺថាព្រះគ្រីស្ទបានទទួលអំពើបាបទាំងអស់របស់មនុស្សមួយចំនួន គឺជាពួកដែលទ្រង់បានជ្រើសរើសប៉ុណ្ណោះ។ អ្វីដែលខ្ញុំជឿនេះ គឺជាសេចក្តីបង្រៀនរបស់ព្រះគម្ពីរ។

(ផ្នែកទីបួននៃសៀវភៅនេះ នឹងមានការទាក់ទងជាមួយបទគម្ពីរដែលប្រើពាក្យ

“លោកិយ” និង “ទាំងអស់”)។

## ជំពូក ៤

*ព្រះរាជបុត្រា ជាអ្នកផ្ដើមនៃសេចក្ដីសង្គ្រោះរបស់យើង*

ដោយព្រោះព្រះរាជបុត្រា យល់ព្រមដោយស្ម័គ្រព្រះហឫទ័យធ្វើតាមផែនការរបស់ព្រះវរបិតា នោះយើងអាចនិយាយបានថា ទ្រង់ក៏ជាអ្នកផ្ដើមនៃសេចក្ដីសង្គ្រោះរបស់យើងដែរ។ ព្រះយេស៊ូវបានមានបន្ទូលថា “ឯអាហារខ្ញុំ គឺត្រង់ដែលខ្ញុំធ្វើតាមព្រះហឫទ័យនៃព្រះដែលចាត់ឲ្យខ្ញុំមក ព្រមទាំងបង្ហើយការរបស់ទ្រង់នោះឯង” (យ៉ូហាន ៤:៣៤)។ មានរបៀបបីយ៉ាង ដែលព្រះគ្រីស្ទ បានបង្ហាញពីការស្ម័គ្រព្រះហឫទ័យរបស់ទ្រង់ ដើម្បីធ្វើជាអ្នកផ្ដើមគឺ៖

១. ទ្រង់ស្ម័គ្រព្រះហឫទ័យ លះចោលសិរីល្អនៃនិស្ស័យជាព្រះរបស់ទ្រង់ មកយកកំណើតជាមនុស្សម្នាក់។ “ដូច្នេះ ដែលកូនចៅបានប្រកបដោយសាច់ឈាមព្រមគ្នា នោះទ្រង់ក៏ទទួលចំណែកជាសាច់ឈាមដូច្នោះដែរ” (ហេព្រើរ ២:១៤)។ ចូរចងចាំថា ការដែលទ្រង់ធ្វើដូច្នេះ គឺមិនមែនដោយព្រោះមនុស្សជាតិទាំងមូល ដែលកើតពីសាច់ឈាមនោះទេ ប៉ុន្តែដោយព្រោះមនុស្សដែលជា “ពួកកូនចៅ ដែលព្រះបានប្រទានមកទូលបង្គំ”(ហេព្រើរ ២: ១៣) ដែលជាមនុស្សវិញ។ ការសព្វព្រះហឫទ័យរបស់ទ្រង់ គឺទាក់ទងទៅនឹងកូនទាំងនោះវិញ គឺមិនមែនទាក់ទងទៅនឹងមនុស្សជាតិទាំងអស់ទេ។

២. ទ្រង់ស្ម័គ្រព្រះហឫទ័យ ថ្វាយអង្គទ្រង់ទុកជាឯង្វាយមួយ។ ពិតមែនហើយ ទ្រង់បានរងទុក្ខជាច្រើនយ៉ាងអសកម្ម។ ប៉ុន្តែ ជាការពិតផងដែរ ដែលទ្រង់បានថ្វាយ

អង្គទ្រង់ សម្រាប់ការឈឺចាប់ទាំងនោះយ៉ាងសកម្ម និងដោយស្ម័គ្រព្រះហឫទ័យ។ ប្រសិនបើគ្មានការស្ម័គ្រព្រះហឫទ័យនោះទេ ការទទួលរងទុក្ខទាំងនោះក៏ឥតមានតម្លៃដែរ។ ដូច្នេះទ្រង់អាចនឹងមានបន្ទូលដោយពិតត្រង់ថា “ព្រះវរបិតាស្រឡាញ់ខ្ញុំ ពីព្រោះខ្ញុំដាក់ជីវិតចុះ...គ្មានអ្នកណាឯកយកជីវិតពីខ្ញុំបានទេ គឺខ្ញុំដាក់ជីវិតចុះដោយខ្លួនខ្ញុំ” (យ៉ូហាន ១០: ១៧-១៨)។

៣. សេចក្តីអធិស្ឋានរបស់ទ្រង់សម្រាប់កូនទ្រង់ បានបង្ហាញពីការស្ម័គ្រព្រះហឫទ័យ ដើម្បីធ្វើជាអ្នកផ្តើមនៃសេចក្តីសង្គ្រោះរបស់ពួកគេ។ ឥឡូវនេះ ព្រះគ្រីស្ទបានចូលទៅក្នុងកន្លែងបរិសុទ្ធនៃនគរស្ថានសួគ៌(ហេព្រើរ ៩: ១១-១២)។ កិច្ចការរបស់ទ្រង់នៅទីនោះ គឺជាការទូលអង្វរជំនួសយើង (សេចក្តីអធិស្ឋាន)។ ចូរចងចាំថា ទ្រង់មិនមែនអធិស្ឋានឲ្យលោកិយទេ (យ៉ូហាន ១៧:៩) ប៉ុន្តែសម្រាប់អស់អ្នកដែលទ្រង់បានសុគតជំនួសវិញ (រ៉ូម ៨: ៣៤)។ ទ្រង់សូមឲ្យអស់អ្នកដែលព្រះបានប្រទានមកទ្រង់ បានមកឯកន្លែងទ្រង់ដែរ ដើម្បីឲ្យគេបានឃើញសិរីល្អរបស់ទ្រង់ (យ៉ូហាន ១៧:២៤)។ ដូច្នេះវាបញ្ជាក់យ៉ាងច្បាស់ថា ទ្រង់មិនសុគតសម្រាប់មនុស្សទាំងអស់ទេ!

## ជំពូក ៥

### *ព្រះវិញ្ញាណ ជាអ្នកផ្តើមនៃសេចក្តីសង្គ្រោះរបស់យើង*

ព្រះគម្ពីរបានថែងអំពីការបីយ៉ាង ដែលព្រះវិញ្ញាណបរិសុទ្ធធ្វើការជាមួយព្រះវរបិតា និងព្រះរាជបុត្រា ក្នុងការប្រោសលោះយើងរាល់គ្នា។ សកម្មភាពទាំងនេះបង្ហាញថា ទ្រង់ក៏ជាអ្នកផ្តើមនៃសេចក្តីសង្គ្រោះរបស់យើងរាល់គ្នាដែរ គឺ៖

១. រូបកាយជាមនុស្សរបស់ព្រះរាជបុត្រា គឺត្រូវបានបង្កើតឡើងដោយព្រះវិញ្ញាណបរិសុទ្ធនៅក្នុងនាងម៉ារា។ "នាងមានគភ៌ដោយព្រះវិញ្ញាណបរិសុទ្ធ"(ម៉ាថាយ ១:១៨)។

២. ព្រះគម្ពីរចែងថា នៅពេលដែលព្រះរាជបុត្រាបានថ្វាយអង្គទ្រង់ជាយញ្ញបូជា គឺទ្រង់ធ្វើតាមរយៈព្រះវិញ្ញាណបរិសុទ្ធ "ព្រះគ្រីស្ទ ដែលទ្រង់ថ្វាយព្រះអង្គទ្រង់ ឥតសៅហ្មងដល់ព្រះ ដោយសារព្រះវិញ្ញាណដ៏គង់នៅអស់កល្បជានិច្ច" (ហេព្រើរ ៩:១៤)។ តាមបទគម្ពីរនេះ បានបញ្ជាក់យ៉ាងច្បាស់ថា ព្រះវិញ្ញាណជាឧបករណ៍ដែលធ្វើឲ្យដង្វាយនោះអាចកើតឡើងបាន។

៣. មានសេចក្ដីចែងទុកយ៉ាងច្បាស់នៅក្នុងព្រះគម្ពីរ ដែលបង្ហាញថា កិច្ចការនៃការប្រោសព្រះគ្រីស្ទឲ្យរស់ពីសុគតឡើងវិញ គឺជាកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ។ "ទ្រង់ត្រូវគេធ្វើគុតខាងសាច់ឈាម តែបានព្រះវិញ្ញាណប្រោសឲ្យរស់វិញ" (១ពេត្រុស ៣:១៨)។

ជាការពិតណាស់ ព្រះវិញ្ញាណបរិសុទ្ធមានការសំខាន់ៗជាច្រើនក្នុងការចូលរួមធ្វើការជាមួយព្រះវរបិតា និងព្រះរាជបុត្រា ក្នុងគោលបំណងប្រោសលោះដល់យើងរាល់គ្នា។

យើងបានឃើញមកហើយថា អង្គនិមួយៗនៃព្រះត្រៃឯក អាចហៅថា ជាអ្នកផ្ដើមនៃសេចក្ដីប្រោសលោះរបស់យើង។ គោលបំណងនៃការសិក្សារបស់យើងមានសារៈសំខាន់ណាស់ដែលយើងចងចាំថា ទោះបីជាយើងបានឃើញពីភាពខុសគ្នារវាងកិច្ចការនៃអង្គនិមួយៗក៏ដោយ ប៉ុន្តែមិនមានន័យថា អ្នកផ្ដើមនៃសេចក្ដីសង្គ្រោះរបស់យើងមានរហូតដល់ទៅបីអង្គនោះទេ។ មានតែមួយប៉ុណ្ណោះ ត្បិតព្រះមានតែមួយប៉ុណ្ណោះ។ ដូច្នេះយើងអាចនិយាយបានថា ព្រះត្រៃឯកទាំងមូល គឺជាអ្នកផ្ដើមនៃសេចក្ដីសង្គ្រោះរបស់យើង។

# ជំពូក ៦

## *កិច្ចការរបស់ព្រះគ្រីស្ទ គឺជាមធ្យោបាយ ដែលប្រើដើម្បីឲ្យបានសេចក្ដីសង្គ្រោះរបស់យើង*

ដូចជាយើងបានឃើញនៅជំពូក២ហើយ អ្នកផ្ដើមធ្វើអ្វីមួយ តែងតែប្រើប្រាស់មធ្យោបាយ ដើម្បីឲ្យបានទទួលលទ្ធផលជាក់លាក់មួយ ដែលគាត់មាននៅក្នុងនិម្មិតរបស់គាត់។ ហើយនៅក្នុងកិច្ចការជាក់ស្ដែងនៃសេចក្ដីសង្គ្រោះរបស់យើងមានសកម្មភាពពីរដែលព្រះគ្រីស្ទបានធ្វើ។ (ត្រង់កន្លែងនេះ ខ្ញុំមិនកំពុងតែគិតពីផែនការអស់កល្ប ដែលធ្វើឲ្យសេចក្ដីសង្គ្រោះរបស់យើងអាចកើតឡើងនោះទេ ប៉ុន្តែខ្ញុំកំពុងតែគិតពីការបង្កបង្កើតរបស់វា នៅក្នុងសម័យកាលប្រវត្តិសាស្ត្រវិញ)។ កិច្ចការខាងប្រវត្តិសាស្ត្រទាំងពីរនេះគឺ៖

១. ដង្វាយអង្គទ្រង់នៅក្នុងអតីតកាល និង

២. ការអង្វរជំនួសរបស់ទ្រង់សម្រាប់យើង នៅបច្ចុប្បន្ននេះ

នៅក្នុងដង្វាយអង្គរបស់ព្រះគ្រីស្ទ ខ្ញុំនិយាយបញ្ចូលទាំងការស្ម័គ្រព្រះទ័យរបស់ទ្រង់ ដើម្បីរងទុក្ខក្នុងគ្រប់ការទាំងឡាយដែលពាក់ព័ន្ធនៅក្នុងការយាងមកសុគតរបស់ទ្រង់ ដូចជា ការលះចោលសិរីល្អរបស់ទ្រង់ ការមកចាប់កំណើតនឹងស្ត្រីម្នាក់ កិច្ចការនានានៃការបន្ទាបខ្លួននិងការស្ដាប់បង្គាប់របស់ទ្រង់ចំពោះបំណងព្រះហឫទ័យព្រះវរបិតាតាមរយៈព្រះជន្ម ហើយនិងការសុគតនៅលើឈើឆ្កាងរបស់ទ្រង់។

រីឯនៅក្នុងការអង្វរជំនួសរបស់ព្រះគ្រីស្ទសម្រាប់យើង ខ្ញុំក៏បញ្ចូលទាំងការរស់ឡើងវិញ និងការយាងទៅស្ថានសួគ៌របស់ទ្រង់ផងដែរ ដ្បិតទាំងនេះជាមូលដ្ឋានគ្រឹះនៃការអង្វរជំនួសរបស់ទ្រង់។ បើគ្មានការទាំងពីរនេះទេ ក៏គ្មានការ

អង្វរជំនួសដែរ។

យើងនឹងមើលសេចក្តីលម្អិតបន្ថែមទៀតនៃការទាំងពីរនេះ នៅជំពូកក្រោយទៀត ប៉ុន្តែឥឡូវនេះខ្ញុំចង់បង្ហាញយោបល់ខ្លះសិន។ កិច្ចការទាំងពីរនេះ មានបំណងតែមួយ។ ដង្វាយ និងការអង្វរជំនួស គឺស្ថិតនៅក្នុងលំដាប់លំដោយនិមួយៗដើម្បីឲ្យ “កូនជាច្រើនមកក្នុងសិរីល្អ” (ហេព្រើរ២:១០)។ អត្ថប្រយោជន៍នានាតាមរយៈកិច្ចការទាំងពីរនេះ គឺមានបំណងសម្រាប់ពួករាស្ត្រដដែលនោះឯង គឺទ្រង់អធិស្ឋានសម្រាប់ពួកអ្នកដែលទ្រង់សុគតជំនួស (យ៉ូហាន ១៧:៩) ។ យើងដឹងថា ការអង្វរជំនួសរបស់ទ្រង់ ត្រូវតែបានទទួលជោគជ័យ “ទ្រង់បានអនុញ្ញាតតាមទូលបង្គំ”(យ៉ូហាន ១១:៤១)។ ដូច្នេះអស់អ្នកដែលទ្រង់បានសុគតជំនួស ត្រូវតែទទួលបានគ្រប់ទាំងការល្អ ដែលបានមកដោយការសុគតរបស់ទ្រង់ ។ ការនោះបំផ្លាញអស់រលីង នូវការបង្រៀនថា ព្រះគ្រីស្ទបានសុគតសម្រាប់មនុស្សទាំងអស់!

## ជំពូក ៧

*ការថ្វាយដង្វាយនៃរូបអង្គព្រះគ្រីស្ទ និងការអង្វរជំនួសរបស់ទ្រង់ គឺជាមធ្យោបាយតែមួយគត់ ដើម្បីឲ្យសេចក្តីសង្គ្រោះរបស់យើងបានសម្រេច*

មានសារៈសំខាន់ណាស់ ក្នុងការកត់សម្គាល់នៅក្នុងព្រះគម្ពីរ អំពីរបៀបដែលការថ្វាយដង្វាយនៃរូបអង្គព្រះគ្រីស្ទ និងការអង្វរជំនួសរបស់ទ្រង់ បានផ្សាភ្ជាប់គ្នាទៅវិញទៅមក។ ឧទាហរណ៍៖

ព្រះគ្រីស្ទរាប់ជាសុចរិត ដល់អស់អ្នកដែលទ្រង់បានទទួលរងទោសចំពោះអំពើទុច្ចរិតរបស់ពួកគេ (អេសាយ ៥៣:១១)។

ព្រះគ្រីស្ទអង្វរជំនួសដល់អស់អ្នក ដែលទ្រង់បានទទួលរងទោសចំពោះអំពើបាបរបស់គេ (អេសាយ ៥៣:១២)។

ព្រះគ្រីស្ទបានរស់ពីសុគតឡើងវិញ ដើម្បីរាប់ជាសុចរិតដល់អស់អ្នកដែលទ្រង់បានសុគតជំនួស (រ៉ូម ៤: ២៥)។

ព្រះគ្រីស្ទបានសុគតសម្រាប់រាស្ត្រជ្រើសរើសរបស់ព្រះ ហើយសព្វថ្ងៃនេះទ្រង់អធិស្ឋានសម្រាប់ពួកគេ (រ៉ូម ៨:៣៣-៣៤)។

ការទាំងនេះបញ្ជាក់យ៉ាងច្បាស់ថា ព្រះគ្រីស្ទមិនបានសុគតសម្រាប់មនុស្សទាំងអស់ទេ ប្រសិនបើទ្រង់បានសុគតសម្រាប់មនុស្សទាំងអស់មែន នោះមនុស្សគ្រប់រូបនឹងបានរាប់ជាសុចរិត តែយើងដឹងយ៉ាងច្បាស់ហើយថា មិនមែនមនុស្សទាំងអស់សុទ្ធតែបានរាប់ជាសុចរិតនោះទេ។

ការថ្វាយយញ្ញបូជា និងការអធិស្ឋាន គឺជាកាតព្វកិច្ចដែលតម្រូវឲ្យសង្ឃម្នាក់។ ប្រសិនបើសង្ឃនោះបរាជ័យក្នុងផ្នែកណាមួយ គាត់ក៏បរាជ័យក្នុងការធ្វើជាសង្ឃស្មោះត្រង់ម្នាក់សម្រាប់ប្រជាជនរបស់គាត់ដែរ។ ព្រះយេស៊ូវគ្រីស្ទជាដង្វាយ (ដង្វាយលោះបាប) និងជាអ្នកនិយាយជំនួស (អ្នកតំណាង) របស់យើងរាល់គ្នា (១យ៉ូហាន ២:១-២)។ ទ្រង់បានថ្វាយព្រះលោហិត (ហេព្រើរ ៩:១១-១៤) ហើយអង្វរជំនួសសម្រាប់យើងរាល់គ្នា (ហេព្រើរ ៧:២៥)។ ដោយព្រោះទ្រង់ជាសង្ឃស្មោះត្រង់មួយអង្គ ទ្រង់ត្រូវតែបំពេញកាតព្វកិច្ចទាំងពីរនេះដោយគ្រប់លក្ខណ៍។ ដ្បិតព្រះជាម្ចាស់តែងសណ្ដាប់សេចក្ដីអធិស្ឋានរបស់ទ្រង់ជានិច្ច យ៉ាងនោះទ្រង់មិនអាចកំពុងតែអង្វរជំនួសមនុស្សទាំងអស់បានឡើយ ដ្បិតមនុស្សទាំងអស់មិនសុទ្ធតែបានសង្គ្រោះនោះទេ។ ដូច្នេះការនេះបញ្ជាក់យ៉ាងច្បាស់ថា ព្រះគ្រីស្ទក៏មិនអាចសុគតជំនួសមនុស្សទាំងអស់បានដែរ។

យើងក៏គួរចងចាំពីរបៀប ដែលព្រះគ្រីស្ទកំពុងតែអង្វរជំនួសសម្រាប់យើងនាពេល

បច្ចុប្បន្ននេះដែរ។ ព្រះគម្ពីរបានថែងពីរបៀបនោះថា គឺដោយសារការថ្វាយព្រះលោហិតរបស់ទ្រង់នៅក្នុងនគរស្ថានសួគ៌ (ហេព្រើរ ៩:១១-១២ និង ២៤)។ និយាយឲ្យចំទៅ ទ្រង់អង្វរជំនួសដោយការថ្វាយការរងទុក្ខរបស់ទ្រង់ដល់ព្រះវរបិតា។ កិច្ចការពីរយ៉ាង ការរងទុក្ខ និងការអង្វរជំនួស ត្រូវតែទាក់ទងទៅនឹងបុគ្គលដដែល បើមិនដូច្នេះទេ វានឹងទៅជាឥតប្រយោជន៍ ក្នុងការដែលប្រើកិច្ចការមួយទុកជាមូលដ្ឋានសម្រាប់កិច្ចការមួយទៀត។ ព្រះគ្រីស្ទផ្ទាល់បានភ្ជាប់ការសុគតនិងការអង្វរជំនួសរបស់ទ្រង់បញ្ចូលគ្នា ទុកជាមធ្យោបាយមួយនៃការប្រោសលោះរបស់យើង ដូចជានៅក្នុងសេចក្តីអធិស្ឋានរបស់ទ្រង់ក្នុងគម្ពីរយ៉ូហានជំពូក៧។ នៅក្នុងសេចក្តីអធិស្ឋាននេះ ទ្រង់សំដៅទៅលើការថ្វាយអង្គទ្រង់ទៅក្នុងការសុគតហើយនិងទៅក្នុងសេចក្តីអធិស្ឋាន សម្រាប់រាស្ត្រដែលព្រះវរបិតាបានប្រទានមកឲ្យទ្រង់។ យើងមិនអាចបំបែកកិច្ចការទាំងពីរនេះបានទេ ប្រសិនបើព្រះគ្រីស្ទផ្ទាល់បានចងភ្ជាប់ហើយនោះ។ ប្រសិនបើមានមួយគ្មានមួយ នោះនឹងទៅជាឥតប្រយោជន៍ ដូចជាសាវ័កប៉ុលបានវែកញែកហើយថា “បើព្រះគ្រីស្ទមិនបានរស់ឡើងវិញមែននោះ (ក៏ទ្រង់មិនកំពុងអង្វរជំនួសនៅពេលបច្ចុប្បន្ននេះដែរ) សេចក្តីជំនឿរបស់អ្នករាល់គ្នា ក៏ជាការឥតអំពើ អ្នករាល់គ្នានៅក្នុងអំពើបាបនៅឡើយ” (១កូរិនថូស ១៥:១៧)។

ដូច្នេះគ្មានការដឹងប្រាកដនៃសេចក្តីសង្រ្គោះសម្រាប់យើងទេ ប្រសិនបើយើងបំបែកការសុគតរបស់ព្រះគ្រីស្ទ ចេញពីការអង្វរជំនួសរបស់ទ្រង់។ តើវាជាការល្អយ៉ាងដូចម្តេចបាន ដែលយើងនិយាយថាព្រះគ្រីស្ទបានសុគតជំនួសយើងក្នុងអតីតកាល ហើយទ្រង់មិនអង្វរជំនួសសម្រាប់យើងនៅពេលបច្ចុប្បន្ននេះទេនោះ? មានតែទ្រង់រាប់យើងជាសុចរិតនៅបច្ចុប្បន្ននេះប៉ុណ្ណោះ ទើបយើងមានសុវត្ថិភាពពីការផ្តន្ទាទោសនៃអំពើបាបរបស់យើងបាន។ ខ្ញុំអាចនៅតែទទួលការផ្តន្ទាទោស ប្រសិនបើព្រះគ្រីស្ទមិនអង្វរជំនួសខ្ញុំទេនោះ។ ដូច្នេះការនេះបញ្ជាក់

យ៉ាងច្បាស់ថា ការអង្វរជំនួសរបស់ទ្រង់ត្រូវតែសម្រាប់មនុស្សដដែល ដែលទ្រង់បានសុគតជំនួស ហើយដូច្នេះទ្រង់មិនអាចសុគតសម្រាប់មនុស្សទាំងអស់បានទេ!

# ផ្នែកទី ២

*គោលបំណងពិតនៃការសុគតរបស់ព្រះគ្រីស្ទ*

*ហើយនិងអ្វីដែលទ្រង់សម្រេចបាន*

**ជំពូក**

១. និយមន័យមួយចំនួន

២. តើការសុគតរបស់ព្រះគ្រីស្ទសម្រាប់ជាសេចក្ដីល្អរបស់នរណា?

៣. តើអ្វីទៅជាគោលបំណងនៃការសុគតរបស់ព្រះគ្រីស្ទ?

៤. តើការសុគតរបស់ព្រះគ្រីស្ទ ធ្វើឲ្យសេចក្ដីសង្គ្រោះ ជាលទ្ធភាពមួយ ឬក៏ ភាពប្រាកដច្បាស់មួយ?

៥. ហេតុផលពួកអ្នកដែលព្រះគ្រីស្ទបានសុគតជំនួសទាំងអស់ ត្រូវតែ បាន ទទួលសេចក្ដីសង្គ្រោះជាប្រាកដ

# ជំពូក ១

## *និយមន័យមួយចំនួន*

នៅក្នុងផ្នែកទី១ ជំពូក២ យើងបានឃើញពីរបៀបនៃការមួយសម្រេចទៅបាន គ្រប់គ្រងលើលទ្ធផលដែលនឹងកើតមាន។ ដើម្បីឲ្យមានភាពប្រាកដច្បាស់ថា លទ្ធផលដែលអ្នកចង់បានពិតជាកើតឡើងនោះ គឺត្រូវតែប្រើមធ្យោបាយដើម្បីធ្វើការអ្វីមួយ តាមរបៀបដែលត្រឹមត្រូវដើម្បីធ្វើឲ្យមានភាពប្រាកដច្បាស់ពីគោលបំណងដែលនឹងសម្រេចបាន។ ព្រះគម្ពីរធ្វើឲ្យមានភាពប្រាកដច្បាស់ថាព្រះ (ព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ) មានបំណងប្រោសលោះមនុស្សប្រុស និងមនុស្សស្រី។ កិច្ចការរបស់ព្រះគ្រីស្ទគឺជាមធ្យោបាយ ដែលកំពុងត្រូវបានប្រើប្រាស់ដើម្បីធ្វើការងារនោះ។ ដោយព្រោះ ព្រះតែងតែធ្វើការ តាមរបៀបដែលត្រឹមត្រូវជានិច្ច នោះយើងត្រូវតែនិយាយថា អស់អ្នកដែលបានទទួលការប្រោសលោះពិតប្រាកដ គឺជាអស់អ្នកដែលទ្រង់មានបំណងនឹងប្រោសលោះ ឬព្រះនឹងទទួលបរាជ័យក្នុងការធ្វើឲ្យសម្រេចនូវគោលបំណងរបស់ទ្រង់ ជាមិនខាន។

ឥឡូវនេះ គេអាចនិយាយថា មានគោលបំណងពីរនៅក្នុងការសុគតរបស់ព្រះគ្រីស្ទ គឺគោលបំណងចម្បងសំខាន់ទីមួយ និងគោលបំណងចម្បងសំខាន់ទីពីរ។ គោលបំណងចម្បងទីមួយនៃការសុគតរបស់ព្រះគ្រីស្ទ គឺដើម្បីថ្វាយសិរីល្អដល់ព្រះ។ នៅក្នុងអ្វីៗដែលទ្រង់ធ្វើ ព្រះមានបំណងជាមុន ដើម្បីសម្ដែងសិរីល្អរបស់ទ្រង់ផ្ទាល់។ អ្វីៗគ្រប់យ៉ាង ដែលកើតមានឡើង គឺដើម្បីនាំសិរីល្អមកឯព្រះជាចម្បងជានិច្ច (អេភេសូរ ១:១២ ភីលីព ២:១១ រ៉ូម ១១:៣៦)។

ប៉ុន្តែការសុគតរបស់ព្រះគ្រីស្ទ ក៏មានគោលបំណងចម្បងទីពីរដែរគឺដើម្បីសង្គ្រោះមនុស្សប្រុសស្រីឲ្យរួចពីអំពើបាបរបស់ពួកគេ ហើយនាំពួកគេទៅឯព្រះ។ ដូច្នេះខ្ញុំចង់បង្ហាញបងប្អូនថា ការសុគតរបស់ព្រះគ្រីស្ទបានទិញអស់អ្នកដែលទ្រង់

បានសុគតជំនួសរួចហើយ។ ការនេះពិតជាចាំបាច់ណាស់ ដើម្បីឲ្យពួកគេបាន សប្បាយរីករាយនឹងសេចក្តីសង្រ្គោះមួយដែលគ្មានការខកចិត្ត។

## ជំពូក ២

*តើការសុគតរបស់ព្រះគ្រីស្ទសម្រាប់ជាសេចក្តីល្អរបស់នរណា?*

ជាការពិតណាស់ យើងចាំបាច់ត្រូវដឹងយ៉ាងច្បាស់ថា តើនរណាទទួល អត្ថប្រយោជន៍ពីការសុគតរបស់ព្រះគ្រីស្ទ។ មានលទ្ធភាពដែលអាចកើតមាន៣គឺៈ

ក. វាអាចនឹងផ្តល់អត្ថប្រយោជន៍ដល់ព្រះវរបិតា ឬក៏

ខ. វាអាចនឹងផ្តល់អត្ថប្រយោជន៍ដល់ទ្រង់ផ្ទាល់ ឬក៏

គ. វាអាចនឹងជាអត្ថប្រយោជន៍របស់យើង

ចូរចងចាំថា នៅពេលនេះខ្ញុំកំពុងតែនិយាយពីគោលបំណងចម្បងទីពីរនៃការសុគតរបស់ព្រះគ្រីស្ទ ហើយនៅក្នុងគំនិតនេះយើងអាចបង្ហាញថា ការសុគតរបស់ព្រះគ្រីស្ទគឺមិនមែនដើម្បីផ្តល់អត្ថប្រយោជន៍ដល់ព្រះវរបិតានោះទេ។

ជួនកាលគេវែកញែកថា ព្រះគ្រីស្ទបានសុគតដើម្បីបង្កើតឲ្យមានលទ្ធភាពមួយដើម្បីឲ្យព្រះបានអត់ទោសដល់អ្នកមានបាប នោះមានន័យថា ព្រះមិនអាចអត់ទោសឲ្យយើងបានទេ។ ការវែកញែកបែបនេះចង់សំដៅថា គោលបំណងចម្បងទីពីរនៃការសុគតរបស់ព្រះគ្រីស្ទ គឺដើម្បីផ្តល់អត្ថប្រយោជន៍ដល់ព្រះវរបិតា។ ទស្សនៈនេះមិនពិតហើយល្ងីល្ងើទៀត ដោយព្រោះមានហេតុផលដូចខាងក្រោមៈ

១. វាមានន័យថា ព្រះគ្រីស្ទបានសុគតដើម្បីកុំឲ្យព្រះវរបិតារារាំងទ្រង់ក្នុងការធ្វើអ្វី

ដែលទ្រង់ (ព្រះគ្រីស្ទ) សព្វព្រះហឫទ័យចង់ធ្វើ (ឧទាហរណ៍៖ ការអត់ទោសដល់អ្នកមានបាប) ជាជាងសុគតដើម្បីឲ្យយើងរួចពីបាប។ ប៉ុន្តែគ្រប់កន្លែងនៅក្នុងព្រះគម្ពីរ និយាយយ៉ាងច្បាស់ថា ព្រះគ្រីស្ទសុគតដើម្បីដោះយើងឲ្យរួចពីបាប។

២. វាមានន័យថា គ្មានអ្នកណាម្នាក់អាចនឹងទទួលបានសេចក្តីសង្គ្រោះពីអំពើបាបបានទេ។ ប្រសិនបើ ព្រះគ្រីស្ទគ្រាន់តែបានទទួលសេរីភាពពីព្រះវរបិតា ដើម្បីអត់ទោសដល់អស់អ្នកមានបាប នោះមានន័យថាព្រះវរបិតាក៏អាច ឬក៏មិនអាចប្រើប្រាស់សេរីភាពនោះបានដែរ! ដូច្នេះការសុគតរបស់ព្រះគ្រីស្ទ នៅតែមិនអាចទទួលបាននូវសេចក្តីសង្គ្រោះសម្រាប់យើងដដែល។ ប៉ុន្តែព្រះគម្ពីរនិយាយយ៉ាងច្បាស់ថា ព្រះគ្រីស្ទបានមកដើម្បីនឹងសង្គ្រោះមនុស្សបាត់បង់។

តទៅនេះ យើងអាចបង្ហាញយ៉ាងច្បាស់ថា ការសុគតរបស់ព្រះគ្រីស្ទគឺមិនមែនដើម្បីជាអត្ថប្រយោជន៍សម្រាប់ទ្រង់ផ្ទាល់នោះទេ។

១. ដោយព្រោះព្រះគ្រីស្ទជាព្រះ ទ្រង់មានគ្រប់ទាំងសិរីល្អ និងអំណាចដែលទ្រង់អាចមានរួចទៅហើយ។ ដូច្នេះនៅជិតចុងបញ្ចប់នៃព្រះជន្មរបស់ទ្រង់នៅលើផែនដីនេះ ទ្រង់មិនបានសូមសិរីល្អណាផ្សេងទៀត ក្រៅពីសិរីល្អដែលទ្រង់មានស្រាប់កាលពីមុននោះទេ (យ៉ូហាន ១៧:៥)។ ហេតុនេះទ្រង់មិនចាំបាច់មកសុគត ដើម្បីឲ្យបានទទួលអត្ថប្រយោជន៍ថ្មីណាផ្សេងទៀត សម្រាប់ទ្រង់ផ្ទាល់នោះទេ។

២. ជួនកាលគេវែកញែកយ៉ាងដូច្នេះថា ដោយការសុគតរបស់ទ្រង់ ព្រះគ្រីស្ទបានទទួលបានសិទ្ធិ ធ្វើជាចៅក្រមលើមនុស្សទាំងអស់។ ប៉ុន្តែប្រសិនបើ គោលបំណងនៃការសុគតរបស់ទ្រង់ ដើម្បីទទួលអំណាចដើម្បីជំនុំជម្រះមនុស្សមួយចំនួន នោះទ្រង់មិនអាចសុគតដើម្បីសង្គ្រោះពួកគេបានឡើយ! ដូច្នេះប្រសិនបើយើងទទួលយកនូវការវែកញែកនេះ យើងមិនអាចប្រើប្រាស់វាដើម្បីបង្ហាញថា ព្រះគ្រីស្ទបានសុគតដើម្បីសង្គ្រោះអ្នកជឿទាំងអស់បានឡើយ។

ដូច្នេះយើងសន្និដ្ឋានថា ការសុគតរបស់ព្រះគ្រីស្ទត្រូវតែមានគោលបំណងដើម្បីផ្តល់អត្ថប្រយោជន៍ដល់យើង។ ការសុគតរបស់ទ្រង់មិនមែនជាលទ្ធភាពមួយដើម្បីឲ្យព្រះវរបិតាអាចសង្គ្រោះយើងនោះទេ។ ហើយវាក៏មិនមែនដើម្បីឲ្យបានទទួលអត្ថប្រយោជន៍ថ្មីថែមទៀត សម្រាប់ព្រះគ្រីស្ទផ្ទាល់នោះដែរ។ សរុបសេចក្តីមក ការសុគតរបស់ព្រះគ្រីស្ទ គឺដើម្បីទទួលការល្អគ្រប់យ៉ាងដែលបានសន្យាដោយការព្រមព្រៀងជាមួយព្រះវរបិតាទ្រង់ ដើម្បីឲ្យអស់អ្នកដែលទ្រង់បានសុគតជំនួស បានទទួលអត្ថប្រយោជន៍។ ដូច្នេះ ទ្រង់សុគតសម្រាប់អស់អ្នកណាដែលទទួលអត្ថប្រយោជន៍ទាំងនោះតែប៉ុណ្ណោះ។ យើងត្រូវពិនិត្យមើលអ្វីខ្លះដែលព្រះគម្ពីរនិយាយអំពីការល្អទាំងនោះ។ ហើយឥឡូវនេះ ចូរយើងមើលពីអត្ថប្រយោជន៍ទាំងនេះនៅក្នុងបទគម្ពីរ។

## ជំពូក ៣

*តើអ្វីជាគោលបំណងនៃការសុគតរបស់ព្រះគ្រីស្ទ?*

យើងបាននិយាយត្រួសៗរួចមកហើយនូវអ្វីដែលព្រះគម្ពីរបានបង្រៀន អំពីមូលហេតុដែលព្រះគ្រីស្ទសុគត(ផ្នែកទី១ ជំពូក១)។ ឥឡូវនេះក្នុងខណៈដែលយើងរុករកប្រធានបទទាំងមូលជាទូទៅ យើងត្រូវតែពិនិត្យមើលឲ្យបានលម្អិតលើបទគម្ពីរដែលនិយាយពីគោលបំណងដែលត្រូវសម្រេច ដោយការសុគតរបស់ព្រះគ្រីស្ទ។ ខ្ញុំនឹងធ្វើការនេះដោយការពិនិត្យទៅលើខគម្ពីរបីក្រុម។

ទីមួយ មានខគម្ពីរនានា ដែលបង្ហាញពីអ្វីដែលព្រះមានបំណងធ្វើ តាមរយៈការសុគតរបស់ព្រះគ្រីស្ទ។ ខ្ញុំបានជ្រើសរើសបទគម្ពីរ៨ខ សម្រាប់យើងពិនិត្យមើល

តែក៏មានខគម្ពីរជាច្រើនទៀតដែលយើងអាចប្រើបានដែរ។

១. លូកា ១៩:១០ “ដ្បិតកូនមនុស្ស បានមកដើម្បីរកហើយជួយសង្គ្រោះដល់មនុស្សបាត់បង់”។ ដូច្នេះ ខនេះបង្ហាញយ៉ាងច្បាស់ថា ព្រះពិតជាមានបំណងដើម្បីសង្គ្រោះអ្នកមានបាបដែលបាត់បង់ ដោយការសុគតរបស់ព្រះគ្រីស្ទប្រាកដមែន។

២. ម៉ាថាយ ១:២១ “...អ្នកត្រូវថ្វាយព្រះនាមថា យេស៊ូវ ព្រោះបុត្រនោះនឹងជួយសង្គ្រោះរាស្ត្រទ្រង់ ឲ្យរួចពីបាប”។ ដូច្នេះ អ្វីក៏ដោយដែលចាំបាច់ដើម្បីសង្គ្រោះមនុស្សមានបាប ត្រូវតែបានសម្រេចឡើងដោយព្រះគ្រីស្ទ។

៣. ១ធីម៉ូថេ ១:១៥ “ព្រះគ្រីស្ទយេស៊ូវទ្រង់បានយាងមកក្នុងលោកិយ ដើម្បីនឹងជួយសង្គ្រោះមនុស្សមានបាប”។ ការនេះមិនឲ្យយើងស្មានថា ព្រះគ្រីស្ទ បានមកដើម្បីគ្រាន់តែធ្វើឲ្យសេចក្តីសង្គ្រោះសម្រាប់មនុស្សមានបាបអាចទៅរួចនោះទេ តែទ្រង់យាងមកដើម្បីសង្គ្រោះពួកគេតែម្តង។

៤. ហេព្រើរ ២:១៤-១៥ “...ដើម្បីឲ្យបានបំផ្លាញអានោះ ដែលមានអំណាចលើសេចក្តីស្លាប់ គឺជាអារក្ស ដោយទ្រង់សុគត ហើយឲ្យបានប្រោសដល់ពួកអ្នកនោះដែលជាប់ជាបាវបម្រើ...” ។ តើមានអ្វីដែលច្បាស់ជាងនេះទៀត? ជាការពិតណាស់ ព្រះគ្រីស្ទបានយាងមកដើម្បីប្រោសដល់មនុស្សមានបាប។

៥. អេភេសូរ ៥:២៥-២៧ “ព្រះគ្រីស្ទបានស្រឡាញ់ដល់ពួកជំនុំ ហើយបានប្រគល់ព្រះអង្គជំនួសផង ដើម្បីឲ្យទ្រង់បានញែកពួកជំនុំជាបរិសុទ្ធ...ប្រយោជន៍នឹងថ្វាយពួកជំនុំនេះ ដល់ព្រះអង្គទ្រង់ទុកជាពួកជំនុំដ៏ឧត្តម...”។ ខ្ញុំគិតថា វាមិនអាចទៅរួចទេដែលនិយាយថា ព្រះវិញ្ញាណបរិសុទ្ធបានធ្វើការនៅត្រង់បទគម្ពីរនេះ។ ព្រះគ្រីស្ទបានសុគត ដើម្បីធ្វើឲ្យបានបរិសុទ្ធ ញែកជាបរិសុទ្ធ និងដំកើងដល់ពួកជំនុំ។

៦. យ៉ូហាន ១៧:១៩ “ឯទូលបង្គំក៏បានញែកខ្លួនជាបរិសុទ្ធ...ដើម្បីឲ្យគេបានញែកចេញជាបរិសុទ្ធ ដោយសារសេចក្តីពិតដែរ” ។ ពិតមែនហើយ តើអ្នកឮព្រះអង្គ

សង្គ្រោះកំពុងតែប្រកាសដោយផ្ទាល់ ពីគោលបំណងនៃការសុគតរបស់ទ្រង់ដែរឬទេ? ទ្រង់បានសុគត គឺដើម្បីឲ្យមនុស្សមួយចំនួន (មិនមែនមនុស្សទាំងអស់ទេ ដ្បិតទ្រង់មិនបានអធិស្ឋានសម្រាប់ការយ៉ាងដូច្នេះទេ-នៅខ៩)បានញែកជាបរិសុទ្ធពិតប្រាកដ (ឬធ្វើឲ្យបានបរិសុទ្ធ)។

៧. កាឡាទី ១:៤ "...ដែលទ្រង់បានប្រគល់ព្រះអង្គទ្រង់ទៅ ដោយព្រោះបាបយើងរាល់គ្នា ដើម្បីនឹងប្រោសយើង"។ ត្រង់នេះជាថ្មីម្តងទៀតហើយ ដែលបទគម្ពីរនិយាយពីគោលបំណង នៃការសុគតរបស់ព្រះគ្រីស្ទដ៏ពិតប្រាកដ គឺដើម្បីលោះយើងរាល់គ្នា។

៨. ២កូរិនថូស ៥:២១ "ដ្បិតឯទ្រង់ដែលមិនបានស្គាល់បាបសោះ នោះព្រះទ្រង់បានធ្វើឲ្យត្រឡប់ជាតួបាប ជំនួសយើងរាល់គ្នាវិញ ដើម្បីឲ្យយើងរាល់គ្នាបានត្រឡប់ទៅជាសេចក្តីសុចរិតរបស់ព្រះ ដោយនូវព្រះនាមនោះឯង"។ ដូច្នេះយើងដឹងថា ព្រះគ្រីស្ទបានយាងមកដើម្បីឲ្យអ្នកមានបាបបានសុចរិត។

យោងតាមខទាំងអស់នេះ វាបង្ហាញឲ្យឃើញយ៉ាងច្បាស់ថា ការសុគតរបស់ព្រះគ្រីស្ទមានគោលបំណងដើម្បីសង្គ្រោះ ប្រោស ញែកជាបរិសុទ្ធ និងធ្វើឲ្យបានសុចរិត សម្រាប់ពួកអ្នកដែលទ្រង់សុគតជំនួស។ ខ្ញុំសូមសួរថា តើមនុស្សទូទៅទាំងអស់សុទ្ធតែបានទទួលសេចក្តីសង្គ្រោះ ទទួលការញែកជាបរិសុទ្ធ ហើយបានទទួលការរាប់ជាសុចរិតដែរឬទេ? ឬមួយក៏ព្រះគ្រីស្ទបរាជ័យក្នុងការសម្រេចគោលបំណងរបស់ទ្រង់? សូមបងប្អូនវិនិច្ឆ័យដោយខ្លួនឯងចុះ ថាតើព្រះគ្រីស្ទបានសុគតសម្រាប់មនុស្សទាំងអស់ ឬក៏ សម្រាប់តែអស់អ្នកដែលទទួលបានសេចក្តីសង្គ្រោះ និងសេចក្តីសុចរិតប៉ុណ្ណោះទេ!

ទីពីរ មានខគម្ពីរជាច្រើន មិននិយាយត្រឹមតែពីគោលបំណងនៃការសុគតរបស់ព្រះគ្រីស្ទប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអ្វីៗដែលបានទទួលមកដោយសារការសុគតនោះផងដែរ។ ខាងក្រោមនេះខ្ញុំបានជ្រើសរើសបទគម្ពីរចំនួន៦៖

១. ហេព្រើរ ៩: ១២-១៤ “ដោយយកព្រះលោហិតនៃអង្គទ្រង់...ទាំងបានសេចក្តីប្រោសលោះ នៅអស់កល្បជានិច្ច...និង...សម្អាតទាំងបញ្ញាចិត្តអ្នករាល់គ្នាពីអស់ទាំងការស្លាប់ផង” ។ ត្រង់នេះមានលទ្ធផលភ្លាមៗពីរនៃការសុគតរបស់ព្រះគ្រីស្ទ គឺសេចក្តីប្រោសលោះអស់កល្ប និង បញ្ញាចិត្តឥតសៅហ្មង។ អស់អ្នកណាដែលមានលទ្ធផលទាំងនេះ គឺជាអ្នកដែលព្រះគ្រីស្ទបានសុគតជំនួសហើយ។

២. ហេព្រើរ ១:៣ នៅពេល “ដែលបានសម្អាតអំពើបាប របស់យើងរាល់គ្នាទាំងប៉ុន្មាន នោះក៏គង់នៅខាងស្តាំនៃបុទ្ធានុភាពនៅលើស្ថានដ៏ខ្ពស់”។ ដូច្នេះពួកអ្នកដែលព្រះគ្រីស្ទបានសុគតជំនួស ទទួលបាននូវការសម្អាតខាងឯវិញ្ញាណមួយ ។

៣. ១ពេត្រុស ២:២៤ “ទ្រង់បានផ្ទុកអំពើបាបរបស់យើងរាល់គ្នា នៅលើរូបអង្គទ្រង់”។ នៅទីនេះយើងបានការប្រកាសពីអ្វីដែលព្រះគ្រីស្ទបានធ្វើ គឺទ្រង់បានផ្ទុកអំពើបាបរបស់យើងនៅលើឈើឆ្កាង។

៤. កូលុស ១:២១-២២ “ឥឡូវនេះវិញ ទ្រង់បានផ្សះផ្សាក្នុងរូបសាច់ទ្រង់...”។ ដូច្នេះសណ្ឋានពិតប្រាកដនៃសេចក្តីមេត្រី ត្រូវបានទទួល រវាងអស់អ្នកដែលទ្រង់បានសុគតជំនួស និង ព្រះវរបិតា។

៥. វិវរណៈ ៥:៩-១០ “យកក្រាំងនេះ ហើយនិងបកត្រាផង ដ្បិតទ្រង់បានត្រូវគេធ្វើគុត ហើយទ្រង់បានលោះយើងរាល់គ្នា ដោយព្រះលោហិតទ្រង់ចេញពីគ្រប់ទាំងពូជ...គ្រប់សាសន៍ ថ្វាយដល់ព្រះនៃយើងរាល់គ្នាឡើងជានគរហើយជាពួកសង្ឃ”។ ត្រង់នេះបង្ហាញយ៉ាងច្បាស់ថា មិនមែន ជាការពិតសម្រាប់មនុស្សទាំងអស់ទេ ប៉ុន្តែវាពិពណ៌នាពីការពិតចំពោះអស់អ្នកដែលព្រះគ្រីស្ទបានសុគតជំនួសវិញ។

៦. យ៉ូហាន ១០:២៨ “ខ្ញុំឲ្យជីវិតអស់កល្បរៀងទៅដល់វា...”។ ព្រះផ្សាល់បានពន្យល់ថា ប្រទានជីវិតដល់ “ចៀមរបស់ទ្រង់” (ខ ២៧)។ ជីវិតខាងព្រលឹងវិញ្ញាណដែលពួកអ្នកជឿពេញចិត្ត គឺជាជីវិតដែលបានមកដោយសារការសុគតរបស់

ព្រះគ្រីស្ទ ។

យោងតាមខគម្ពីរទាំង៦នេះ (ហើយនិងខដែលអាចយកមកប្រើជាច្រើនទៀត) យើងអាចនិយាយបានដូចខាងក្រោមថា ប្រសិនបើ ការសុគតរបស់ព្រះគ្រីស្ទ ពិតជាបានទទួលនូវសេចក្តីប្រោសលោះ ការសម្អាត ការធ្វើឲ្យបរិសុទ្ធ ការទទួលរងអំពើបាប ការផ្សះផ្សា ជីវិតអស់កល្ប និងភាពជាពលរដ្ឋនៅក្នុងនគរមួយ នោះទ្រង់ច្បាស់ជាសុគតសម្រាប់អស់អ្នកដែលបានទទួលសេចក្តីទាំងនោះតែប៉ុណ្ណោះ។ ដូចជាបានបញ្ជាក់យ៉ាងច្បាស់ហើយថា វាមិនពិតទេដែល មនុស្សទាំងអស់មានសេចក្តីទាំងនោះ។ ដូច្នេះសេចក្តីសង្គ្រោះសម្រាប់មនុស្សទាំងអស់ មិនអាចជាគោលបំណងនៃការសុគតរបស់ព្រះគ្រីស្ទបានឡើយ។

ទីបី មានខគម្ពីរមួយចំនួនផងដែរ ដែលពិពណ៌នាអំពីអស់អ្នកដែលព្រះគ្រីស្ទបានសុគតជំនួស។ ជាញឹកញាប់ខគម្ពីរទាំងនោះពិពណ៌នាថា “មនុស្សជាច្រើន” ដូចជានៅគម្ពីរអេសាយ ៥៣:១១ ម៉ាកុស ១០:៤៥ ហេព្រើរ ២:១០។ ប៉ុន្តែនៅកន្លែងផ្សេងទៀត ពាក្យថា “មនុស្សជាច្រើន” ត្រូវបានពិពណ៌នាថាជា៖

| | |
|---|---|
| ចៀមរបស់ព្រះគ្រីស្ទ | យ៉ូហាន ១០:១៥ |
| កូននៃព្រះ | យ៉ូហាន ១១:៥២ |
| កូនដែលព្រះបានប្រទានដល់ទ្រង់ | យ៉ូហាន ១៧:១១<br>ហេព្រើរ ២:១៣ |
| រាស្ត្រជ្រើសរើសរបស់ទ្រង់ | រ៉ូម ៨: ៣៣ |
| មនុស្សដែលទ្រង់ស្គាល់ជាមុន | រ៉ូម ១១: ២ |
| ពួកជំនុំរបស់ទ្រង់ | កិច្ចការ ២០: ២៨ |
| អស់អ្នកដែលទ្រង់បានទទួលបាបជំនួស | ហេព្រើរ ៩:២៨ |

ជាការពិតណាស់ ការពិពណ៌នាទាំងអស់នេះ គឺមិនពិតសម្រាប់មនុស្សទាំងអស់នោះទេ។ ដូច្នេះយើងឃើញពីគោលបំណងនៃការសុគតរបស់ព្រះគ្រីស្ទ ដូចជាបាននិយាយនៅក្នុងព្រះគម្ពីរហើយថា វាមិនអាចជាសេចក្ដីសង្គ្រោះសម្រាប់មនុស្សទាំងអស់បានទេ។

## ជំពូក ៨

*តើការសុគតរបស់ព្រះគ្រីស្ទ ធ្វើឲ្យសេចក្ដីសង្គ្រោះ ជាលទ្ធភាពមួយ ឬ ភាពជាក់ច្បាស់មួយ?*

មនុស្សមួយចំនួនបានវែកញែកថា ការសុគតរបស់ព្រះគ្រីស្ទបានទទួលសេចក្ដីប្រោសលោះគ្រប់គ្រាន់សម្រាប់មនុស្សទាំងអស់ ប្រសិនបើពួកគេគ្រាន់តែជឿ។ តែទោះជាយ៉ាងណាក៏ដោយ អត្ថប្រយោជន៍នេះបានផ្ដល់ឲ្យមនុស្សតែមួយចំនួនប៉ុណ្ណោះ ពីព្រោះមានមនុស្សតែមួយចំនួនប៉ុណ្ណោះដែលជឿ។ គេនិយាយថា ព្រះគ្រីស្ទទទួលបានសេចក្ដីសង្គ្រោះមួយដែលគ្រប់គ្រាន់សម្រាប់មនុស្សទាំងអស់ ប៉ុន្តែការសង្គ្រោះនោះ សង្គ្រោះបានតែមនុស្សមួយចំនួនប៉ុណ្ណោះ។

ជាការពិតណាស់ ការបង់ថ្លៃដើម្បីលោះទាសករម្នាក់ គឺមិនដូចគ្នាទៅនឹងការដោះលែងទាសករម្នាក់ឲ្យមានសេរីភាពនោះទេ។ ការទទួលសេចក្ដីសង្គ្រោះ និងការផ្ដល់សេចក្ដីសង្គ្រោះ ក៏មិនប្រាកដថាដូចគ្នានោះដែរ។ ប៉ុន្តែមានការជាច្រើន

ដែលគេត្រូវតែយល់ផងដែរថា៖

១. ការទទួលសេចក្តីសង្គ្រោះរបស់យើងពីព្រះគ្រីស្ទ ហើយនិងការដែលទ្រង់ប្រទានសេចក្តីសង្គ្រោះនោះមកយើង អាចជាកិច្ចការពីរផ្សេងគ្នា ដូច្នេះគេមិនអាចវែកញែកថា វាទាក់ទងទៅនឹងមនុស្សពីរក្រុមផ្សេងគ្នាបានឡើយ។ ព្រះគ្រីស្ទមិនមានគោលបំណងពីរនៅក្នុងការសុគតរបស់ទ្រង់ឡើយ!

២. បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដែលព្រះគ្រីស្ទគួរទទួលបានសេចក្តីសង្គ្រោះសម្រាប់មនុស្សមានបាប នោះមិនផ្អែកទៅលើល័ក្ខខ័ណ្ឌដែលមនុស្សមានបាបបានជឿនោះទេ។ បំណងព្រះហឫទ័យរបស់ព្រះ គ្មានល័ក្ខខ័ណ្ឌ ចំពោះសេចក្តីសង្គ្រោះគួរបានទទួល និងសេចក្តីសង្គ្រោះគួរផ្តល់ឲ្យឡើយ ។

៣. ការទទួលសេចក្តីសង្គ្រោះរបស់យើង គឺមានល័ក្ខខ័ណ្ឌនៃសេចក្តីជំនឿរបស់យើង។ ប៉ុន្តែសេចក្តីជំនឿនោះ គឺជាអ្វីដែលព្រះជាម្ចាស់បានប្រទានមកយើងដោយគ្មានល័ក្ខខ័ណ្ឌវិញ។ នេះគឺជាអ្វីដែលខ្ញុំនឹងបង្ហាញនៅពេលខាងមុខនេះ។

៤. អស់អ្នកណាដែលព្រះគ្រីស្ទរកបានអត្ថប្រយោជន៍ឲ្យ ដោយការសុគតរបស់ទ្រង់ហើយ ពួកគេច្បាស់ជាទទួលបាននូវអត្ថប្រយោជន៍នោះជាមិនខាន។ ការទាំងនេះពីព្រោះតែ៖

ក. ប្រសិនបើ ព្រះគ្រីស្ទគ្រាន់តែរកបានអត្ថប្រយោជន៍ទាំងនោះ តែបែរជាមិនអាចផ្តល់ឲ្យពួកគេវិញនោះ នោះមានន័យថាការសុគត របស់ទ្រង់ប្រហែលជាមិនអាចនឹងសង្គ្រោះនរណាម្នាក់បានឡើយ!

ខ. តើព្រះបានតាំងព្រះអង្គសង្គ្រោះមួយអង្គមក ដោយគ្មានការសម្រេចព្រះហឫទ័យថា គួរតែសង្គ្រោះនរណាឬអី? តើទ្រង់បានតាំងមធ្យោបាយមួយមក ដោយគ្មានគោលបំណងពិតប្រាកដទេឬអី ? ទេ ការទាំងនោះផ្ទុយទៅនឹងការបង្រៀនរបស់ព្រះគម្ពីរហើយ!

គ. ប្រសិនបើការមួយ ទ្រង់រកបានមកសម្រាប់ខ្ញុំ ជាការពិតវាត្រូវតែ ជារបស់ខ្ញុំដោយពេញសិទ្ធិ ហើយអ្វីក៏ដោយដែលជារបស់ផងខ្ញុំ ដោយពេញសិទ្ធិ នោះវាត្រូវតែជារបស់ផងខ្ញុំជាប្រាកដមែន ។ ដូច្នេះ សេចក្តីសង្គ្រោះដែលព្រះគ្រីស្ទរកបាន ត្រូវតែជារបស់ អស់អ្នកដែល ទ្រង់បានរកឲ្យ។ គេនិយាយថា “មែនហើយ ប៉ុន្តែវាជារបស់ពួកគេ មែន បើក្នុងល័ក្ខខ័ណ្ឌដែលពួកគេជឿ”។ ខ្ញុំក៏ឆ្លើយតបម្តងទៀត ថា “ប៉ុន្តែសេចក្តីជំនឿដែលបានមក ក៏ដោយសារព្រះ ដែរ”។

ឃ. បទគម្ពីរ តែងតែផ្សាភ្ជាប់ជាមួយពួកអ្នកដែលព្រះគ្រីស្ទបានរក សេចក្តីប្រោសលោះឲ្យ ហើយនិង ជាមួយពួកអ្នកដែលទ្រង់ប្រើ ប្រាស់សេចក្តីប្រោសលោះនោះ ។

១. អេសាយ ៥៣:៥ ចែងថា ព្រះគ្រីស្ទប្រោសឲ្យជា ដល់អស់អ្នក ដែលទ្រង់បានរងរបួសជំនួស។

២. អេសាយ ៥៣:១១ ព្រះគ្រីស្ទរាប់ជាសុចរិតដល់អស់អ្នកដែលទ្រង់បានផ្ទុកអំពើបាបជំនួស ។

៣. រ៉ូម ៨:២៥ ព្រះគ្រីស្ទរាប់ជាសុចរិតដល់អស់អ្នក ដែលទ្រង់បានប្រោស។

៤. រ៉ូម ៨:៣២-៣៤. ព្រះប្រទានអ្វីៗគ្រប់ទាំងអស់ ដល់អ្នកដែលព្រះគ្រីស្ទបានសុគតជំនួស។

ឥឡូវនេះ អស់អ្នកណាដែលព្រះគ្រីស្ទបានសុគតជំនួសហើយ មិនអាចទទួលការផ្តន្ទាទោសទេ។

បច្ចុប្បន្ននេះ ព្រះគ្រីស្ទអធិស្ឋានសម្រាប់អស់អ្នកដែលទ្រង់បានសុគតជំនួស។

ឆ្លងតាមការរែកញែកទាំងនេះ យើងដឹងយ៉ាងច្បាស់ថា អស់អ្នកដែលព្រះគ្រីស្ទរកសេចក្ដីប្រោសលោះឲ្យ ទ្រង់ពិតជាប្រទានវាមកពួកគេមែន។ សេចក្ដីសង្គ្រោះដោយការសុគតរបស់ព្រះគ្រីស្ទ គឺមិនត្រូវបានធ្វើឲ្យអាចកើតឡើងសម្រាប់មនុស្សទាំងអស់នោះទេ តាមពិតទៅ គឺសម្រាប់អស់អ្នកដែលទ្រង់ប្រទានវាមកប៉ុណ្ណោះ។

ឥឡូវនេះ សូមឲ្យខ្ញុំលើកការបួនចំណុច ដែលនិយាយពីបញ្ហានេះ ។ អំពីចំណុចនិមួយៗខាងលើនេះ ខ្ញុំនឹងនិយាយបន្ថែមទៀត នៅពេលក្រោយក្នុងសៀវភៅនេះ។

១. ព្រះបានចាត់ព្រះគ្រីស្ទមកសុគត ដោយព្រោះតែសេចក្ដីស្រឡាញ់ដ៏នៅអស់កល្បជានិច្ចរបស់ទ្រង់ចំពោះរាស្ត្រជ្រើសរើសរបស់ទ្រង់ ។

២. តម្លៃនៃការសុគតរបស់ព្រះគ្រីស្ទ គឺមិនអាចវាស់វែងបានទេ ហើយវាគ្រប់គ្រាន់សម្រាប់អ្វីៗគ្រប់យ៉ាង ដែលទ្រង់សព្វព្រះហឫទ័យចង់សម្រេច។

៣. គោលបំណងរបស់ព្រះវរបិតា គឺដើម្បីយកកូនៗពីសាសន៍ជាច្រើន មកថ្វាយសិរីល្អដល់ទ្រង់ និយាយឲ្យចំទៅគឺ ទ្រង់បានសម្រេចព្រះហឫទ័យបង្កើតសេចក្ដីសញ្ញាថ្មីមួយជាមួយពួករើសតាំងរបស់ទ្រង់។

៤. អ្វីគ្រប់យ៉ាងដែលបានទិញមកដោយការសុគតរបស់ព្រះយេស៊ូវសម្រាប់មនុស្សទាំងឡាយ នឹងពិតជាក្លាយមកជារបស់ពួកគេនៅពេលកំណត់មួយជាមិនខាន។ ដោយព្រោះទ្រង់រកវាបានមកសម្រាប់ពួកគេ នោះមានន័យថា ព្រះគ្រីស្ទមានហេតុផលត្រឹមត្រូវ ដែលការនោះគួរកើតឡើងយ៉ាងដូច្នេះ ។

*កំណត់ចំណាំបន្ថែម*

ប្រសិនបើយើងប្រកាន់ទស្សនៈថា ការសុគតរបស់ព្រះគ្រីស្ទអាចទៅរួចសម្រាប់មនុស្សទាំងអស់ តែតាមពិតអាចសង្គ្រោះបានពួកអ្នកជឿប៉ុណ្ណោះ នោះយើងច្បាស់

ជានិយាយថា៖

១. ព្រះជាម្ចាស់គួរតែសង្គ្រោះមនុស្សទាំងអស់។ យើងសូមបដិសេធការនេះព្រោះថាព្រះទ្រង់ត្រូវការអ្វីដែលទ្រង់សព្វព្រះហឫទ័យចង់ធ្វើប៉ុណ្ណោះ។

២. ព្រះជាម្ចាស់មិនអាចធ្វើអ្វីដែលទ្រង់សព្វព្រះទ័យបានទេ ប្រសិនបើមនុស្សមិនបានបំពេញល័ក្ខខ័ណ្ឌ។ យើងសូមបដិសេធការនេះ ព្រោះថា វាធ្វើឲ្យខូចសិរីល្អនៃព្រះ។

៣. សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ អាចនឹងសម្តែងមកឲ្យឃើញកាន់តែប្រសើរជាង បើទ្រង់ស្រឡាញ់ដល់មនុស្សទាំងអស់ជាជាងស្រឡាញ់ដល់មនុស្សតែមួយចំនួន។ យើងសូមបដិសេធការនេះ ហើយយើងនឹងវែកញែកការនេះឲ្យកាន់តែពេញលេញថែមទៀត នៅផ្នែកទី៤ ជំពូក២ និងជំពូក៤។

៤. ទ្រង់បានចាត់ព្រះរាជបុត្រាឲ្យមកសុគត ពីព្រោះទ្រង់ស្រឡាញ់មនុស្សទាំងអស់ស្មើៗគ្នា។ យើងសូមបដិសេធការនេះ ទុកជាការមួយដែលខុសពីបទគម្ពីរ។ មានបទគម្ពីរជាច្រើន ពិពណ៌នាមនុស្សដែលមិនមែនជាកម្មបទនៃសេចក្តីស្រឡាញ់ដែលទ្រង់ចាត់ព្រះគ្រីស្ទឲ្យមកសុគត។ ឧទាហរណ៍៖ សុភាសិត ១៦:៤ កិច្ចការ ១:២៥ រ៉ូម ៩:១១-១៣; ១ថែស្សាឡូនិច ៥:៩; ២ពេត្រុស ២:១២ យូដាស ៤។

៥. យើងកំពុងតែនិយាយថា សេចក្តីជំនឿដែលជាល័ក្ខខ័ណ្ឌនៃការទទួលសេចក្តីសង្គ្រោះ មិនត្រូវបានទទួលមកសម្រាប់យើងដោយសារការសុគតរបស់ព្រះគ្រីស្ទទេ។ ព្រះគម្ពីរបង្រៀនថា សេចក្តីជំនឿនេះគឺជាអត្ថប្រយោជន៍មួយនៃអត្ថប្រយោជន៍នានា ដែលព្រះគ្រីស្ទរកបានមកសម្រាប់យើងរាល់គ្នា។

៦. យើងកំពុងតែនិយាយថា ការសុគតរបស់ទ្រង់ ព្រះគ្រីស្ទជាអ្នកជំនួសសម្រាប់មនុស្សទាំងអស់ហើយ។ យើងសូមបដិសេធការនេះ ដ្បិតប្រសិនបើ ព្រះគ្រីស្ទជាអ្នកជំនួសសម្រាប់មនុស្សទាំងអស់ នោះមានន័យថា មនុស្សទាំងអស់សុទ្ធតែបាន

ទទួលសេចក្ដីសង្រ្គោះគ្រប់ៗគ្នាហើយ។

៧. យើងកំពុងតែនិយាយថា ការសុគតរបស់ព្រះគ្រីស្ទសម្រាប់ពួកអ្នកដែលព្រះវរបិតាបានស្គាល់ នឹងមិនអាចបានទទួលសេចក្ដីសង្រ្គោះ។ ព្រះវរបិតាបានជ្រាបអ្វីៗគ្រប់យ៉ាងជាមុន។ ខ្ញុំឃើញថាគ្មានអ្វីដែលយើងបានទទួលពីការវែកញែកនេះសោះ!

## ជំពូក៥

*ហេតុផល ដែលពួកអ្នកព្រះគ្រីស្ទបានសុគតជំនួស*

*ត្រូវតែបានសង្រ្គោះជាពិតប្រាកដ*

ខ្ញុំនឹងផ្ដល់ឲ្យមួយជំពូកទៀតដើម្បីបង្ហាញថា កំហុសនៃគំនិតដែលថាការសុគតរបស់ព្រះគ្រីស្ទគឺជាការគ្រប់គ្រាន់សម្រាប់ការសង្រ្គោះដល់មនុស្សទាំងអស់ ប៉ុន្តែតាមពិតសង្រ្គោះបានតែមនុស្សមួយចំនួន(“គ្រប់គ្រាន់សម្រាប់មនុស្សទាំងអស់មានប្រសិទ្ធភាពសម្រាប់មនុស្សមួយចំនួន”)។ ការរកបាន ការផ្ដល់ឲ្យ និងសេចក្ដីប្រោសលោះ គឺមានភាពផ្សេងពីគ្នា ប៉ុន្តែពួកវាមិនអាចដាច់ចេញពីគ្នាបានឡើយ។

ខ្ញុំសូមវែកញែកថា ប្រសិនបើអ្វីណាមួយ ដែលទ្រង់រកបានមកសម្រាប់នរណាម្នាក់ហើយ នោះវាមិនអាចនឹងមិនប្រាកដថា វាមិនមែនជារបស់ទ្រង់នោះទេ។ ទ្រង់នឹងមិនមានបន្ទូលថា “វាប្រហែលជារបស់ខ្ញុំ” នោះឡើយ ។ ដូច្នេះ អ្វីក៏ដោយ ដែលព្រះគ្រីស្ទបានរកបានដោយការសុគតរបស់ទ្រង់ ត្រូវតែជាកម្មសិទ្ធិរបស់ពួកអ្នកដែលទ្រង់បានប្រទានឲ្យ។

វាអាចនឹងប្រឆាំងនឹងហេតុផលដែលគេមានជាញឹកញាប់ ដែលតែងតែវែក

ញែកថា ព្រះមានបំណងព្រះហឫទ័យឲ្យព្រះគ្រីស្ទសុគតសម្រាប់នរណាម្នាក់ ប៉ុន្តែបុគ្គលនោះមិនបានទទួលអត្ថប្រយោជន៍នោះទៅវិញ។

វាអាចនឹងមិនសមហេតុផលទេ ដែលថ្លៃលោះមួយត្រូវបានសង សម្រាប់លោះពួកទាសករហើយ តែបែរជាទាសករទាំងនោះមិនបានទទួលការដោះលែងនោះ! ហើយយើងដឹងថា ការសុគតរបស់ព្រះគ្រីស្ទ គឺជាថ្លៃលោះ (ម៉ាថាយ ២០:២៨)។

ឥឡូវនេះអ្នកខ្លះបានវែកញែកថា វាពិតប្រាកដមែនហើយដែលថា អ្វីដែលទ្រង់ប្រទានមកនរណាម្នាក់ គឺជារបស់ទ្រង់ដោយស្របច្បាប់ ប៉ុន្តែប្រហែលជាអាចនឹងប្រទានមកសម្រាប់អ្នកនោះ ដោយល័ក្ខខ័ណ្ឌជាក់លាក់ផ្សេងៗ។ ហើយពួកគេនិយាយទៀតថា ល័ក្ខខ័ណ្ឌដែលយើងអាចទទួលបាននូវអត្ថប្រយោជន៍ដែលព្រះគ្រីស្ទរកបានមកនោះ គឺជាការដែលយើងមិនបដិសេធនឹងការប្រោសលោះដែលព្រះបានប្រទានមក ឬក៏យើងបានស្រែកហៅទៅកាន់ការអញ្ជើញរបស់ដំណឹងល្អ ឬក៏ជាការដែលយើងមានជំនឿ ។ ខ្ញុំសូមប្រឆាំងការវែកញែកនេះ ហើយខ្ញុំសូមមានយោបល់ដូចខាងក្រោមនេះវិញ៖

១. ប្រសិនបើគោលបំណងរបស់ព្រះ គឺដើម្បីប្រោសលោះនរណាម្នាក់ ហើយនោះទ្រង់នឹងធ្វើឡើងដោយស្មោះត្រង់ ។ ហើយប្រសិនបើ ព្រះគ្រីស្ទបានសុគត ដើម្បីសង្គ្រោះមនុស្សទាំងអស់ ដោយមានល័ក្ខខ័ណ្ឌជាក់លាក់ណាមួយមែន នោះមានន័យថា មនុស្សទាំងអស់គ្រប់រូប ត្រូវតែស្គាល់ពីល័ក្ខខ័ណ្ឌទាំងនោះហើយ។ គោលបំណងដើម្បីសង្គ្រោះនេះមិនអាចស្មោះត្រង់បានទេ ប្រសិនបើអ្នកខ្លះមិនបានដឹងពីល័ក្ខខ័ណ្ឌទាំងនោះ។ ចុះចំណែកអស់អ្នកដែលមិនដែលឮសោះនោះនឹងយ៉ាងម៉េចវិញ?

២. ល័ក្ខខ័ណ្ឌដែលតម្រូវ ដើម្បីឲ្យរកបានអត្ថប្រយោជន៍នៃការសុគតរបស់ព្រះគ្រីស្ទ ត្រូវតែស្ថិតនៅក្នុងក្របខ័ណ្ឌអំណាចនៃការប្រព្រឹត្តិរបស់យើង ឬក៏មិន

មែនដូច្នោះទេ ។ ប្រសិនបើវាពិតមែន នោះមានន័យថាមនុស្សទាំងអស់មានអំណាចដើម្បីជឿ តែនោះមិនត្រឹមត្រូវទេ។ ប្រសិនបើមិនមែនវិញ មានន័យថា ច្បាស់ជាព្រះប្រោសប្រទានអំណាចនោះមក ឬក៏មិនមែនដូច្នោះទេ។ ប្រសិនបើទ្រង់ប្រោសប្រទានអំណាចនោះមកមែន ហេតុអ្វីបានជាមនុស្សទាំងអស់មិនបានទទួលសេចក្តីសង្គ្រោះ? ហើយប្រសិនបើទ្រង់មិនបានប្រោសប្រទានវាមកទេ ទ្រង់មិនអាចស្នើល័ក្ខខ័ណ្ឌបានឡើយ ឬក៏ទ្រង់មិនស្មោះត្រង់ក្នុងការទាមទារអ្វីមួយពីយើង ដ្បិតការនោះមានតែទ្រង់ប៉ុណ្ណោះដែលអាចប្រទានវាមកយើងបាន។ វាប្រៀបដូចជាមនុស្សម្នាក់ដែលសន្យាថា នឹងឲ្យលុយចំនួន១០០០ដុល្លារដល់បុរសពិការភ្នែកម្នាក់ ប្រសិនបើគាត់អាចមើលឃើញបាន។

៣. សេចក្តីជំនឿ (ល័ក្ខខ័ណ្ឌនៃសេចក្តីសង្គ្រោះដ៏ពោរពេញដោយសេចក្តីអំណររបស់យើង) គឺត្រូវរកបានមកសម្រាប់យើង ដោយការសុគតរបស់ព្រះគ្រីស្ទ ឬក៏មិនមែនទេ ។ ប្រសិនបើវាពិតជារកបានដោយការនោះមែន មានន័យថាមនុស្សទាំងអស់សុទ្ធតែមានវា ដ្បិតពួកគេនិយាយថា ព្រះគ្រីស្ទសុគតសម្រាប់មនុស្សទាំងអស់។ តែប្រសិនបើព្រះគ្រីស្ទមិនរកបានសេចក្តីជំនឿសំរាប់យើងទេ នោះមានន័យថា ផ្នែកដ៏សំខាន់បំផុតនៃសេចក្តីសង្គ្រោះរបស់យើង មិនពឹងផ្អែកលើព្រះគ្រីស្ទទាល់តែសោះ! ការនេះវាធ្វើឲ្យបាត់បង់សិរីល្អរបស់ព្រះគ្រីស្ទ។ ហើយការនេះផ្ទុយទៅនឹងអ្វីដែលបទគម្ពីរបង្រៀនថា សេចក្តីជំនឿគឺជាអំណោយទានរបស់ព្រះ (ភីលីព ១:២៩ អេភេសូរ ២:៨)។

៤. ដែលគេអះអាងថា ព្រះគ្រីស្ទបានសុគតសម្រាប់មនុស្សទាំងអស់ ប៉ុន្តែមានតែអស់អ្នកដែលបានបំពេញល័ក្ខខ័ណ្ឌជាក់លាក់ប៉ុណ្ណោះ ដែលអាចបានទទួលសេចក្តីសង្គ្រោះ នោះធ្វើឲ្យទ្រង់ក្លាយទៅជាអ្នកសង្រ្គបសង្រ្គមត្រឹមតែពាក់កណ្តាលប៉ុណ្ណោះ។ គេនិយាយថា ទ្រង់បានរកបានសេចក្តីសង្គ្រោះសម្រាប់មនុស្សទាំងអស់។ ប៉ុន្តែខ្ញុំនិយាយថា តើវាមានប្រយោជន៍អ្វី ប្រសិនបើទ្រង់មិនបានបំពេញ

លក្ខខណ្ឌទាំងនោះ!

ដូច្នេះសូមឲ្យខ្ញុំសរុបសេចក្តីចុះ ។ អ្វីដែលព្រះគ្រីស្ទបានទទួល មិនអាចបំបែកចេញពីអស់អ្នកដែលព្រះគ្រីស្ទបានសុគតជំនួសបានឡើយ។ ព្រះគ្រីស្ទបានសុគត មិនមែនមានន័យថា មនុស្សនោះស័ក្តិសមទទួលបានសេចក្តីសង្គ្រោះ បើគាត់ជឿនោះទេ ប៉ុន្តែទ្រង់បានសុគតសម្រាប់អស់អ្នកដែលជារាស្ត្រជ្រើសរើសរបស់ព្រះវិញ។ នេះហើយជាមូលហេតុដែលពួកគេគួរទទួលជឿ។ គ្មានកន្លែងណាមួយដែលបានចែងនៅក្នុងព្រះគម្ពីរ ហើយវាក៏មិនអាចបង្ហាញឲ្យសមហេតុផលបានដែរថា ព្រះគ្រីស្ទបានសុគតសម្រាប់យើង ប្រសិនបើយើងជឿ។ ការនោះអាចនឹងធ្វើឲ្យសេចក្តីជំនឿរបស់យើង ជាបុព្វហេតុនៃអ្វីមួយដែលមិនពិតទៅវិញ។ តើការប្រព្រឹត្តិរបស់យើងអាចនឹងធ្វើឲ្យការសុគតរបស់ទ្រង់ក្លាយជាការមួយសម្រាប់យើងឬ! ប៉ុន្តែព្រះគ្រីស្ទបានសុគតសម្រាប់យើង យ៉ាងនោះបានជាយើងអាចនឹងជឿទ្រង់បាន។

ឥឡូវនេះ ដោយព្រោះយើងបានពិនិត្យមើលយ៉ាងពេញលេញនៅក្នុងផ្នែកទីមួយនិងទីពីរហើយ នោះយើងអាចដំណើរការសិក្សាពីភស្តុតាងមួយចំនួនទៀតដែលគាំទ្រសេចក្តីពិតអំពីអ្វីដែលខ្ញុំនិយាយ។ ការដែលយើងធ្វើដូច្នេះ ខ្ញុំចង់ឲ្យលោកអ្នកចងចាំក្នុងចិត្តនូវចំណុចដ៏សំខាន់ៗ ដែលយើងបានធ្វើរហូតដល់ពេលនេះ។

# ផ្នែកទី ៣

*ការវែកញែកទាំង ១៦ចំណុច ដែលបង្ហាញថាព្រះគ្រីស្ទមិនបានសុគតដើម្បីឲ្យបាន ការសង្គ្រោះសម្រាប់មនុស្សទាំងអស់*

**ជំពូក**

១. ការវែកញែកពីរដែលមានមូលដ្ឋានលើនិស្ស័យនៃសញ្ញាថ្មី

២. ការវែកញែកបីដែលមានមូលដ្ឋានលើការពិពណ៌នារបស់ព្រះគម្ពីរ អំពី សេចក្តីសង្គ្រោះ

៣. ការវែកញែកពីរដែលមានមូលដ្ឋានលើនិស្ស័យនៃកិច្ចការរបស់ព្រះគ្រីស្ទ

៤. ការវែកញែកបី ដែលមានមូលដ្ឋានលើ ភាពបរិសុទ្ធ និងសេចក្តីជំនឿ

៥. ការវែកញែកមួយដែលមានមូលដ្ឋានលើអត្ថន័យនៃពាក្យថា "ការប្រោសលោះ"

៦. ការវែកញែកមួយដែលមានមូលដ្ឋានលើអត្ថន័យនៃពាក្យថា "សម្រួបសម្រួម"

៧. ការវែកញែកមួយដែលមានមូលដ្ឋានលើអត្ថន័យនៃពាក្យថា "ការញែក ជាបរិសុទ្ធ"

៨. ការវែកញែកពីរដែលមានមូលដ្ឋានលើតម្លៃនៃការសុគតរបស់ព្រះគ្រីស្ទ

៩. ការវែកញែកទូទៅមួយអំពីបទគម្ពីរនានា

## ជំពូក ១

*ការវែកញែកពីរចំណុច ដែលមានមូលដ្ឋានលើនិស្ស័យនៃសញ្ញាថ្មី*

*ការវែកញែកទី១-* នៅព្រះគម្ពីរ ម៉ាថាយ២៦:២៨ ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទបានមានបន្ទូលថា "ឈាមរបស់ខ្ញុំ គឺជាឈាមនៃសញ្ញាថ្មី"។ "សញ្ញា" ថ្មីនេះ គឺជាកិច្ចព្រមព្រៀងថ្មីឬកិច្ចសន្យាថ្មី ដែលព្រះបានធ្វើឡើង ដើម្បីសង្គ្រោះមនុស្ស។ ដោយការសុគតរបស់ព្រះគ្រីស្ទ ព្រះលោហិតទ្រង់ដែលបានហូរ គឺជាតម្លៃនៃកិច្ចព្រមព្រៀងនោះ។ ហើយការនោះទាក់ទងចំពោះតែអស់អ្នកណាដែលជាប់កិច្ចព្រមព្រៀងនោះប៉ុណ្ណោះ។

កិច្ចព្រមព្រៀងថ្មីនេះ គឺខុសពីកិច្ចព្រមព្រៀងចាស់ដែលព្រះបានធ្វើជាមួយមនុស្ស ។ តាមរយៈកិច្ចព្រមព្រៀងចាស់ (ឬសេចក្តីសញ្ញា) ព្រះបានសន្យាថានឹងសង្គ្រោះអស់អ្នកដែលកាន់តាមក្រឹត្យវិន័យរបស់ទ្រង់៖ "មនុស្សណាដែលបានប្រព្រឹត្តិតាម សេចក្តីទាំងនោះ នឹងរស់នៅដោយសារការខ្លួនប្រព្រឹត្តិនោះឯង" (រ៉ូម ១០:៣ លេវីវិន័យ ១៨:៥)។ ប៉ុន្តែពីព្រោះមនុស្សជាអ្នកមានបាប នោះពួកគេមិនអាចកាន់តាមក្រឹត្យវិន័យរបស់ព្រះបានឡើយ។ ដូច្នេះកិច្ចព្រមព្រៀងចាស់មិនមានប្រយោជន៍ទៀតទេ ។

នៅក្នុងកិច្ចព្រមព្រៀងថ្មី ព្រះបានសន្យាថា ដាក់ក្រឹត្យវិន័យនេះនៅក្នុងគំនិតរបស់ពួកគេ ដែលទ្រង់បានសរសេរក្រឹត្យវិន័យទាំងនោះ នៅក្នុងចិត្តរបស់ពួកគេ (ហេព្រើរ ៨:១០)។ អញ្ចឹងហើយបានជាវាបង្ហាញយ៉ាងច្បាស់ថា កិច្ចព្រមព្រៀងនេះអាចទាក់ទងចំពោះតែអស់អ្នកដែលព្រះបានធ្វើការនេះ នៅក្នុងចិត្តរបស់ពួកគេប៉ុណ្ណោះ។ ពិតមែនហើយ ព្រះមិនធ្វើការនេះ សម្រាប់មនុស្សទាំងអស់នោះទេ។ មនុស្សទាំងអស់មិនអាចរាប់បញ្ចូលនៅក្នុងកិច្ចព្រមព្រៀងដែលព្រះគ្រីស្ទបានសុគតបានទេ ។

មនុស្សមួយចំនួនបានវែកញែកថា ព្រះនឹងសរសេរក្រឹត្យវិន័យរបស់ទ្រង់នៅក្នុងចិត្តរបស់យើង ប្រសិនបើយើងគ្រាន់តែជឿប៉ុណ្ណោះ។ ប៉ុន្តែ សេចក្តីជំនឿ និងក្រឹត្យវិន័យដែលព្រះបានកត់ទុកនៅក្នុងចិត្តរបស់ពួកយើង គឺដូចតែគ្នាទេ! គេនិយាយថា៖ “ប្រសិនបើក្រឹត្យវិន័យរបស់ទ្រង់នៅក្នុងចិត្តរបស់យើង (ឧទាហរណ៍៖ នៅក្នុងគ្រប់អ្នកជឿទាំងអស់) នោះព្រះសន្យាថានឹងសរសេរក្រឹត្យវិន័យរបស់ទ្រង់នៅក្នុងចិត្តរបស់យើង” នោះមិនសមហេតុផលទាល់តែសោះ!

និស្ស័យនៃសញ្ញាថ្មីធ្វើឲ្យដឹងច្បាស់ថា ការសុគតរបស់ព្រះគ្រីស្ទ គឺមិនសម្រាប់មនុស្សទាំងអស់ទេ។

*ការវែកញែកទី២-* ដំណឹងល្អ- មានន័យថា គឺជាដំណឹងល្អអំពីសញ្ញាថ្មី ដែលវាមាននៅក្នុងលោកិយនេះចាប់តាំងពីសម័យព្រះគ្រីស្ទមក។ ប៉ុន្តែ មិនមែនគ្រប់ប្រជាជាតិដែលបានរស់នៅក្នុងផែនដីនេះ សុទ្ធតែបានយល់ដឹងពីវានោះទេ។ ប្រសិនបើ ព្រះមានបំណងចង់ឲ្យការសុគតរបស់ព្រះគ្រីស្ទគួរសង្គ្រោះដល់មនុស្សទាំងអស់ក្នុងល័ក្ខខ័ណ្ឌដែលពួកគេជឿ នោះទ្រង់គួរតែធ្វើឲ្យមនុស្សទាំងអស់បានដឹងពីដំណឹងល្អនេះ។

ប្រសិនបើ ព្រះមិនបានរៀបចំឲ្យមនុស្សទាំងអស់បានឮពីដំណឹងល្អនោះវាច្បាស់ជាអាចទៅរួច ដែលមនុស្សបានទទួលសេចក្តីសង្គ្រោះដោយមិនបាច់មានជំនឿ និងការយល់ដឹងពីដំណឹងល្អ ឬមួយក៏គោលបំណងដើម្បីសង្គ្រោះមនុស្សទាំងអស់បានទទួលបរាជ័យ ព្រោះមនុស្សទាំងអស់មិនបានឮពីដំណឹងល្អ។ ចំណុចដំបូងនោះមិនអាចជាការពិតបានទេ ដ្បិតសេចក្តីជំនឿគឺជាផ្នែកមួយនៃសេចក្តីសង្គ្រោះ (សូមមើលនៅផ្នែកទី២ ជំពូក៥)។ ហើយចំណុចបន្ទាប់ក៏មិនអាចជាការពិតបានដែរ តើនោះជានិស្ស័យនៃប្រាជ្ញាញាណរបស់ព្រះឬ? តើព្រះបានចាត់ព្រះគ្រីស្ទមកសុគត ដើម្បីឲ្យមនុស្សទាំងអស់បានសង្គ្រោះ តែមិនបានធ្វើឲ្យមនុស្ស

ទាំងអស់ពីវាឬអី? តើសេចក្ដីល្អនៃព្រះបានបង្ហាញមកក្នុងអាកប្បកិរិយាយ៉ាងដូច្នេះឬអី?

វាប្រៀបបីដូចជាគ្រូពេទ្យម្នាក់និយាយថា គាត់មានថ្នាំដែលអាចព្យាបាលជំងឺរបស់មនុស្សទាំងអស់បាន ប៉ុន្តែគាត់មានគោលបំណងលាក់លៀមមិនឲ្យមនុស្សជាច្រើនបានដឹង។ នៅក្នុងករណីនេះ តើអ្នកអាចវែកញែកបានឬទេថា តើគ្រូពេទ្យនោះពិតជាមានបំណងព្យាបាលជំងឺមនុស្សទាំងអស់ពិតប្រាកដមែនឬទេ?

មានបទគម្ពីរជាច្រើនបានបង្ហាញយ៉ាងច្បាស់ថា មនុស្សរាប់លាននាក់មិនដែលឮសូម្បីតែមួយម៉ាត់ពីព្រះគ្រីស្ទ។ ហើយយើងមិនអាចផ្ដល់ហេតុផលណាផ្សេងទៀត ជាជាងហេតុផលដែលព្រះគ្រីស្ទបានផ្ដល់មកដោយផ្ទាល់នោះទេ។ “ហ្នឹងហើយព្រះវរបិតាអើយ ដ្បិតទ្រង់បានសព្វព្រះហឫទ័យយ៉ាងដូច្នេះ” (ម៉ាថាយ ១១:២៦)។ បទគម្ពីរនានាដូចជា ទំនុកដំកើង ១៤៧:១៩-២០; កិច្ចការ ១៤:១៦; កិច្ចការ ១៦:៦-៧ បានបញ្ជាក់ពីការពិតនៃបទពិសោធន៍ដែលយើងមានដូចៗគ្នាគឺថា ព្រះជាម្ចាស់មិនបានបង្កើតឲ្យមានការរៀបចំណាមួយ ដើម្បីធានាឲ្យមនុស្សទាំងអស់បានឮពីដំណឹងល្អទេ។ យើងត្រូវតែសន្និដ្ឋានថា ព្រះមិនមានគោលបំណងដើម្បីសង្គ្រោះមនុស្សទាំងអស់ទេ។

## ជំពូក ២

## *ការវែកញែកបី ចំណុចដែលមានមូលដ្ឋានលើការពិពណ៌នារបស់ព្រះគម្ពីរអំពីសេចក្ដីសង្គ្រោះ*

*ការវែកញែកទី១-* បទគម្ពីរពិពណ៌នាពីអ្វីដែលព្រះគ្រីស្ទរកបាន ដោយការសុគត

របស់ទ្រង់គឺជា “ការប្រោសលោះដ៏អស់កល្បជានិច្ច”។ (នេះគឺជាការប្រោសពីអំពើបាប ពីសេចក្តីស្លាប់ និងពីស្ថាននរករបស់យើងជារៀងរហូត)។ អញ្ចឹង ប្រសិនបើព្រះពរនេះ ត្រូវបានទិញមកសម្រាប់មនុស្សទាំងអស់ នោះមានន័យថា មនុស្សទាំងអស់បានទទួលការប្រោសលោះដ៏នៅអស់កល្បនេះដោយស្វ័យប្រវត្តិ ឬក៏វាត្រូវបានរកមកសម្រាប់មនុស្សទាំងអស់ ដោយការបំពេញតាមល័ក្ខខ័ណ្ឌជាក់លាក់នានា។ នៅក្នុងបទពិសោធរបស់យើង វាមិនពិតទេ ដែលមនុស្សទាំងអស់មានសេចក្តីប្រោសលោះអស់កល្បជានិច្ចនោះ។ ដូច្នេះ តើការប្រោសលោះអស់កល្បជានិច្ចនេះ អាចរកបានដោយការបំពេញល័ក្ខខ័ណ្ឌជាក់លាក់នានាឬ?

ខ្ញុំសួរថា តើព្រះគ្រីស្ទបានបំពេញគ្រប់ល័ក្ខខ័ណ្ឌទាំងអស់នោះសម្រាប់យើង ឬក៏ការបំពេញល័ក្ខខ័ណ្ឌទាំងនេះជារបស់ផងយើង ប្រសិនបើយើងគ្រាន់តែបំពេញល័ក្ខខ័ណ្ឌបន្ថែមនោះ?

ចំណុចទីមួយខាងលើ ដែលនិយាយថាព្រះគ្រីស្ទពិតជាបំពេញគ្រប់ល័ក្ខខ័ណ្ឌទាំងអស់សម្រាប់ការប្រោសលោះអស់កល្បដែលត្រូវប្រទានមក នោះអាចនឹងមានន័យថា មនុស្សទាំងអស់ពិតជាមានសេចក្តីប្រោសលោះនេះគ្រប់ៗគ្នា។ ដូចជាយើងបានដឹងហើយថា ការនោះវាមិនឯកភាពគ្នាទៅនឹងបទពិសោធន៍របស់មនុស្សទេ! យើងត្រូវតែនិយាយថា ប្រសិនបើព្រះគ្រីស្ទមិនបានបំពេញល័ក្ខខ័ណ្ឌ សម្រាប់មនុស្សទាំងអស់ឲ្យបានសេចក្តីប្រោសលោះទេ នោះមានន័យថាទ្រង់ត្រូវបំពេញល័ក្ខខ័ណ្ឌទាំងនោះ សម្រាប់តែអ្នកដែលបំពេញល័ក្ខខ័ណ្ឌបន្ថែមនោះប៉ុណ្ណោះឬយ៉ាងម៉េច។ ដូច្នេះ យើងរកច្រកចេញមិនបាន គឺកំពុងតែធ្វើឲ្យល័ក្ខខ័ណ្ឌដែលត្រូវបំពេញទាំងអស់នោះ ផ្អែកទៅលើល័ក្ខខ័ណ្ឌផ្សេងទៀតដែលកំពុងតែបំពេញទៅវិញ! ការវែកញែកខាងលើនេះបង្ហាញថា វាមិនសមហេតុផលទេដែលគេស្មានថាព្រះគ្រីស្ទបានសុគត ដើម្បីឲ្យបានទទួលសេចក្តីសង្គ្រោះអស់កល្បសម្រាប់មនុស្សទាំងអស់នោះ។ ប្រសិនបើគេនៅតែទាមទារថា ការប្រោសលោះអស់កល្ប អាចរក

បានដោយការបំពេញល័ក្ខខ័ណ្ឌជាក់លាក់នានា ដូច្នេះ តើមនុស្សទាំងអស់គួរតែយល់ដឹងពីល័ក្ខខ័ណ្ឌទាំងនោះគ្រប់ៗគ្នាឬទេ? ប៉ុន្តែមនុស្សជាច្រើន បានទទួលការរារាំងមិនឲ្យមានចំណេះដឹងពីការបំពេញល័ក្ខខ័ណ្ឌទាំងនេះ ដូចជាយើងបានឃើញនៅផ្នែកទី៣ ជំពូក១ស្រាប់ហើយ។

លើសពីនេះទៅទៀត ប្រសិនបើ ការរកឲ្យបានការប្រោសលោះអស់កល្បនោះ ផ្អែកទៅលើការបំពេញល័ក្ខខ័ណ្ឌរបស់មនុស្ស នោះអាចមានន័យថាពួកគេមានអំណាច ឬមិនមានអំណាចដើម្បីធ្វើការនោះ។ ប្រសិនបើពួកគេអាចបំពេញល័ក្ខខ័ណ្ឌចាំបាច់ទាំងនោះបាន នោះយើងត្រូវតែនិយាយថា មនុស្សទាំងអស់អាចជឿជំណឹងល្អបានដោយសមត្ថភាពផ្ទាល់ខ្លួនរបស់ពួកគេ។ ប៉ុន្តែនេះគឺជាអ្វីដែលផ្ទុយទៅនឹងបទគម្ពីរ ដ្បិតបទគម្ពីរបង្ហាញថា មនុស្សបានស្លាប់ក្នុងអំពើបាបហើយដូចនេះពួកគេមិនអាចបំពេញតាមល័ក្ខខ័ណ្ឌណាមួយបានឡើយ។

ប្រសិនបើគេយល់ព្រមថា មនុស្សមិនមានសមត្ថភាពផ្ទាល់ដើម្បីបំពេញល័ក្ខខ័ណ្ឌឲ្យបានទទួលការប្រោសលោះអស់កល្ប អញ្ចឹងមានតែព្រះជាម្ចាស់មានផែនការប្រទានសមត្ថភាពនេះដល់ពួកគេ ឬក៏ទ្រង់មិនមានគំរោងធ្វើយ៉ាងដូច្នោះទេ។ ប្រសិនបើទ្រង់ធ្វើផែនការអញ្ចឹងមែន ចុះហេតុអ្វីបានជាទ្រង់មិនធ្វើឲ្យមនុស្សទាំងអស់បានទទួលសេចក្តីសង្គ្រោះគ្រប់ៗគ្នាដែរទៅ?

ប្រសិនបើ ព្រះជាម្ចាស់មិនមានបំណងព្រះហឫទ័យប្រទានសមត្ថភាពឲ្យមនុស្សទាំងអស់បានជឿទេ ប៉ុន្តែបែរជាព្រះគ្រីស្ទបានសុគត ដើម្បីឲ្យមនុស្សទាំងអស់បានទទួលនូវការប្រោសលោះអស់កល្បជានិច្ចវិញ នោះមានន័យថា ព្រះទាមទារឲ្យមនុស្ស ហ្វឹកហាត់សមត្ថភាពដែលទ្រង់បដិសេធមិនប្រទានមក។ តើការនេះជាភាពល្ងីល្ងើណាស់មែនទេ? គេនិយាយនេះប្រៀបដូចជា ព្រះបានសន្យាថានឹងប្រទានអំណាចឲ្យមនុស្សស្លាប់ម្នាក់ ដើម្បីឲ្យគាត់ធ្វើឲ្យខ្លួនគាត់បានរស់ឡើងវិញ នៅខណៈពេលដែលទ្រង់មិនមានបំណងនឹងប្រទានអំណាចដែលបានសន្យានោះមក យ៉ាង

ដូច្នេះដែរ។

*ការវែកញែកទី៤*- ព្រះគម្ពីរ បានពិពណ៌នាពីពួកអ្នកដែលព្រះគ្រីស្ទបានសុគតជំនួស យ៉ាងប្រុងប្រយ័ត្ន។ ព្រះគម្ពីរប្រាប់យើងថា មនុស្សជាតិអាចចែកចេញជាពីរក្រុម ហើយនៅក្នុងនោះមានតែមួយក្រុមប៉ុណ្ណោះ ដែលព្រះគ្រីស្ទបានសុគតជំនួស។

បទគម្ពីរខាងក្រោមបង្ហាញថា ព្រះបានបែងចែកមនុស្សជាតិជាពីរផ្នែក៖

ម៉ាថាយ ២៥:១២ និង ៣២

យ៉ូហាន ១០:១៤ និង ២៦

យ៉ូហាន ១៧:៩

រ៉ូម ៩:១១-២៣

១ថែស្សាឡូនីច ៥:៩

យើងដឹងថា មានមនុស្សដែលព្រះស្រឡាញ់ ហើយនិងមានមនុស្សដែលទ្រង់ស្អប់ មានមនុស្សដែលទ្រង់ស្គាល់ ហើយនិងមានមនុស្សដែលទ្រង់មិនស្គាល់។

បទគម្ពីរផ្សេងទៀតបញ្ជាក់យ៉ាងច្បាស់ថា ព្រះគ្រីស្ទបានសុគតសម្រាប់តែមនុស្សមួយក្រុមប៉ុណ្ណោះក្នុងចំណោមក្រុមទាំងពីរនេះ។ បទគម្ពីរប្រាប់យើងថា ទ្រង់សុគតសម្រាប់៖

| | |
|---|---|
| រាស្ត្ររបស់ទ្រង់ | ម៉ាថាយ ១:២១ |
| ចៀមរបស់ទ្រង់ | យ៉ូហាន ១០:១១ និង ១៤ |
| ពួកជំនុំរបស់ទ្រង់ | កិច្ចការ ២០:២៨ |
| ពួកជ្រើសរើសរបស់ទ្រង់ | រ៉ូម ៨:៣២-៣៤ |
| កូនរបស់ទ្រង់ | ហេព្រើរ ២:១៣ |

ជាការពិតណាស់ តើនេះយើងមិនអាចសរុបសេចក្តីមកថា ព្រះគ្រីស្ទមិនបានសុគត សម្រាប់មនុស្សដែលមិនមែនជារាស្ត្ររបស់ទ្រង់ ឬចៀមរបស់ទ្រង់ ឬក៏ ពួកជំនុំរបស់ទ្រង់ទេឬអី? ដូច្នេះទ្រង់មិនអាចសុគតសម្រាប់មនុស្សទាំងអស់បានទេ។

*ការវែកញែកទី៥-* យើងមិនគួរពិពណ៌នាពីសេចក្តីសង្រ្គោះនៅក្នុងរបៀបមួយដែលផ្សេងពីព្រះគម្ពីរឡើយ។ ហើយនៅក្នុងព្រះគម្ពីរ គ្មានកន្លែងណាមួយដែលនិយាយថា ព្រះគ្រីស្ទបានសុគត "សម្រាប់មនុស្សទាំងអស់" ទេ។ ព្រះគម្ពីរចែងថា ព្រះគ្រីស្ទប្រទានព្រះជន្មរបស់ទ្រង់ទុកជា "ថ្លៃលោះសម្រាប់មនុស្សទាំងអស់" ប៉ុន្តែវាមិនអាចបង្ហាញថា លើសពីចំនួន "ចៀមទាំងអស់របស់ទ្រង់" ឬ"ពួកជ្រើសរើសទាំងអស់របស់ព្រះ" បានឡើយ។ ប្រសិនបងប្អូនពិនិត្យមើលដោយប្រុងប្រយ័ត្ន បទគម្ពីរណាមួយដែលប្រើពាក្យថា "ទាំងអស់" ហើយត្រួតពិនិត្យមើលនៅក្នុងបរិបទរបស់វា ភ្លាមនោះបងប្អូននឹងដឹងច្បាស់ថា គ្មានកន្លែងណាមួយនៅក្នុងព្រះគម្ពីរ និយាយថាព្រះគ្រីស្ទបានសុគតសម្រាប់មនុស្សទាំងអស់នោះទេ។

(នៅក្នុងផ្នែកទី៤ ជំពូក៣និង៤ យើងនឹងពិចារណាលំអិតលើបទគម្ពីរជាច្រើន ដែលប្រើពាក្យថា "លោកិយ" និង "ទាំងអស់" ដែលទាក់ទងជាមួយនឹងការសុគតរបស់ព្រះគ្រីស្ទ)។

## ជំពូក ៣

## *ការវែកញែកពីរ ចំណុចដែលមានមូលដ្ឋានលើនិស្ស័យ នៃកិច្ចការរបស់ព្រះគ្រីស្ទ*

*ការវែកញែកទី៦-* មានបទគម្ពីរជាច្រើន និយាយពីព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទថា ទ្រង់បានធ្វើឲ្យអង្គទ្រង់ផ្ទាល់ទទួលខុសជំនួសអ្នកដទៃទៀតនៅពេលដែលទ្រង់បានសុគត។ ឧទាហរណ៍៖

ទ្រង់បានសុគតជំនួសយើង រ៉ូម ៥:៨

ទ្រង់ត្រូវបណ្ដាសាជំនួសយើង កាឡាទី ៣:១៣

ទ្រង់បានត្រឡប់ជាតួបាបជំនួសយើង ២កូរិនថូស ៥:២១

ឃ្លាខាងលើទាំងអស់នេះបង្ហាញយ៉ាងច្បាស់ថា ព្រះគ្រីស្ទបានធ្វើការងារ ជាអ្នកទទួលជំនួសអ្នកឯទៃ។

ឥឡូវនេះ ប្រសិនបើទ្រង់បានសុគតជំនួសអ្នកឯទៃហើយ នោះមានន័យថា ពួកអ្នកដែលទ្រង់បានទទួលជំនួស ត្រូវតែរួចពីសេចក្ដីក្រោធ និងការជំនុំជម្រះរបស់ព្រះជាម្ចាស់។ (ព្រះជាម្ចាស់មិនអាចដាក់ទណ្ឌកម្មដល់ព្រះគ្រីស្ទផង ហើយនិងដល់អស់អ្នកដែលទ្រង់បានទទួលជំនួសផងនោះទេ!) ប៉ុន្តែវាបង្ហាញយ៉ាងច្បាស់ថា មនុស្សទាំងអស់មិនបានរួចពីសេចក្ដីក្រោធរបស់ព្រះទេ (សូមមើល យ៉ូហាន ៣:៣៦)។ ដូច្នេះព្រះគ្រីស្ទមិនអាចជាអ្នកជំនួសសម្រាប់មនុស្សទាំងអស់បានទេ។

ប្រសិនបើយើងនៅតែទាមទារថាព្រះគ្រីស្ទពិតជាបានសុគត ដើម្បីធ្វើជាអ្នកជំនួសសម្រាប់មនុស្សទាំងអស់មែន នោះយើងច្បាស់ជាសន្និដ្ឋានថាការសុគតរបស់ទ្រង់មិនមែនជាថ្លៃលោះល្អគ្រប់គ្រាន់ទេ ពីព្រោះមនុស្សទាំងអស់មិនបានទទួលការសង្គ្រោះឲ្យរួចពីបាប និងការជំនុំជម្រះ។

ពិតមែនហើយ ប្រសិនបើព្រះគ្រីស្ទពិតជាបានសុគតជំនួសមនុស្សទាំងអស់មែន នោះមានន័យថា ទ្រង់បានថ្វាយអង្គទ្រង់ទុកជាថ្លៃលោះសម្រាប់អំពើបាបទាំងអស់របស់ពួកគេ (ក្នុងករណីមនុស្សទាំងអស់បានទទួលសេចក្ដីសង្គ្រោះ) ឬក៏វាជាថ្លៃលោះមួយសម្រាប់អំពើបាបខ្លះរបស់ពួកគេប៉ុណ្ណោះ (ក្នុងករណីគ្មានអ្នកណាម្នាក់បានទទួលការសង្គ្រោះ ដោយព្រោះនៅសេសសល់អំពើបាបខ្លះទៀត)។ ប្រយោគទាំងពីរខាងលើនេះមិនពិតទាំងអស់ ដូចជាយើងបានឃើញនៅក្នុងសៀវភៅនេះស្រាប់ហើយ (ផ្នែកទី១ ជំពូក៣)។ វាបង្ហាញយ៉ាងច្បាស់ណាស់ថា

វាមិនអាចទៅរួចទេ ដែលយើងនិយាយថាព្រះគ្រីស្ទបានសុគតសម្រាប់មនុស្ស ទាំងអស់នោះ។

*ការវែកញែកទី៧-* ព្រះគម្ពីរពិពណ៌នាពីនិស្ស័យនៃការងារដែលព្រះយេស៊ូវគ្រីស្ទបាន ធ្វើ គឺការងារជាអ្នកសម្រុះសម្រួល និងការងារជាសង្ឃ“ទ្រង់ជាអ្នកកណ្តាលនៃ សញ្ញាថ្មី” (ហេព្រើរ ៩:១៥)។ ទ្រង់ធ្វើកិច្ចការជាអ្នកសម្រុះសម្រួលម្នាក់ ដោយ ទ្រង់ជាសង្ឃរបស់ពួកអ្នកដែលទ្រង់នាំមកឯព្រះជាម្ចាស់។ ពីបទពិសោធនិងពីព្រះ គម្ពីរ បង្ហាញយ៉ាងច្បាស់ថា ព្រះយេស៊ូវគ្រីស្ទមិនមែនជាសង្ឃរបស់មនុស្សទាំង អស់ទេ។ យើងបានពិភាក្សារឿងនេះនៅក្នុងផ្នែកទី២ ជំពូក២រួចមកហើយ។

## ជំពូក ៨

### *ការវែកញែកបី ចំណុចដែលមានមូលដ្ឋានលើ ភាពបរិសុទ្ធ និង សេចក្តីជំនឿ*

*ការវែកញែកទី៨-* ប្រសិនបើការសុគតរបស់ព្រះគ្រីស្ទជាមធ្យោបាយដែលពួកអ្នក ដែលទ្រង់បានសុគតជំនួស បានស្អាតពីអំពើបាបនិងបានបរិសុទ្ធមែន នោះមាន ន័យថាទ្រង់ត្រូវតែបានសុគតសម្រាប់ពួកអ្នកដែលបានស្អាត និងបានបរិសុទ្ធទាំង នោះប៉ុណ្ណោះ។ ជាការពិតដែលមនុស្សទាំងអស់មិនបានបរិសុទ្ធ។ ដូច្នេះព្រះគ្រីស្ទ មិនបានសុគតជំនួសមនុស្សទាំងអស់ទេ។

ប្រហែលខ្ញុំគួរបង្ហាញថា ការសុគតរបស់ព្រះគ្រីស្ទ គឺពិតជាមធ្យោបាយនៃ ការរកឲ្យបាននូវ ការសម្អាត និងសេចក្តីបរិសុទ្ធ។ ខ្ញុំសូមបង្ហាញការនេះជាពីរ របៀប៖

ទីមួយ គំរូនៃការថ្វាយបង្គំសម័យសញ្ញាចាស់ត្រូវបានរៀបចំឡើង ដើម្បីបង្រៀនសេចក្តីពិតអំពីការសុគតរបស់ព្រះគ្រីស្ទ ។ ដង្វាយជាឈាមនៅសម័យសញ្ញាចាស់ ពិតជាធ្វើឲ្យវាទៅរួច សម្រាប់ពួកអ្នកដែលឈាមនោះបានបូរជំនួស ដើម្បីឲ្យពួកគេដែលជាអ្នកថ្វាយបង្គំព្រះ អាចចូលមកឯព្រះបាន។ ដូច្នេះ តើព្រះលោហិតរបស់ព្រះគ្រីស្ទពិតជាបានសម្អាតពួកអ្នកដែលទ្រង់បានសុគតជំនួសពីអំពើបាបជាងអម្បាលម៉ានទៅទៀត? (ហេព្រើរ ៩:១៣-១៤)។

ទីពីរ មានខគម្ពីរជាច្រើនបាននិយាយយ៉ាងច្បាស់ថា ការសុគតរបស់ព្រះគ្រីស្ទពិតជាសម្រេចអ្វីៗដែលព្រះសព្វព្រះហឫទ័យចង់ធ្វើ។ រូបកាយនៃអំពើបាបត្រូវបានបំផ្លាញចោល យ៉ាងនោះបានជាយើងមិនគួរបម្រើអំពើបាបទៀត (រ៉ូម ៦:៦)។ យើងបានទទួលការប្រោសលោះតាមរយៈព្រះលោហិតរបស់ទ្រង់(កូល៉ុស ១:១៤)។ ទ្រង់បានថ្វាយអង្គទ្រង់ដើម្បីលោះយើង និងដើម្បីធ្វើឲ្យយើងបានបរិសុទ្ធ (ទីតុស ២:១៤)។ ខគម្ពីរទាំងនេះ និងខគម្ពីរជាច្រើនទៀត សុទ្ធតែទាមទារថា ភាពបរិសុទ្ធគឺជាលទ្ធផលជាក់លាក់នៅក្នុងជីវិតនៃពួកអ្នកដែលព្រះគ្រីស្ទបានសុគតជំនួស។ មនុស្សទាំងអស់មិនបានបរិសុទ្ធ ដោយព្រោះព្រះគ្រីស្ទមិនបានសុគតសម្រាប់មនុស្សទាំងអស់។

អ្នកខ្លះបានលើកឡើងដោយអំនួតថា ការសុគតរបស់ព្រះគ្រីស្ទមិនមែនគ្រាន់តែដោយព្រោះភាពបរិសុទ្ធប៉ុណ្ណោះទេ។ គេនិយាយថា ភាពបរិសុទ្ធនោះក្លាយជាភាពបរិសុទ្ធពិតប្រាកដ នៅពេលដែលព្រះវិញ្ញាណបរិសុទ្ធនាំវាមក ឬក៏បានទទួលវាមកនៅពេលណាដែលមានជំនឿវិញ។ ប៉ុន្តែការងារនៃព្រះវិញ្ញាណបរិសុទ្ធ និងអំណោយទាននៃសេចក្តីជំនឿ ក៏ជាលទ្ធផល ឬផលផ្លែនៃការសុគតរបស់ព្រះគ្រីស្ទផងដែរ! ដូច្នេះ ការលើកឡើងនេះ មិនអាចបំផ្លាស់ការពិតបានទេ ដែលថា ភាពបរិសុទ្ធពិតប្រាកដ គឺជាលទ្ធផលជាក់លាក់ ដែលមានតែនៅក្នុងជីវិតរបស់ពួកអ្នកដែលព្រះគ្រីស្ទបានសុគតជំនួសប៉ុណ្ណោះ។ ការពិតដែលថាក្រមផ្តល់ការអនុញ្ញាត

ហើយឆ្មាំគុកចាក់សោបើកទ្វារគុក នោះមិនមែនដោយសារតែអ្នកជំពាក់បំណុលនោះកំពុងតែត្រូវបានដោះលែងទេ គឺដោយសារមានម្នាក់បានសងបំណុលជំនួសគាត់វិញ។

*ការវែកញែកទី៩*- សេចក្តីជំនឿមានសារៈសំខាន់ណាស់ចំពោះសេចក្តីសង្រ្គោះ។ ការនេះបានបញ្ជាក់យ៉ាងច្បាស់ពីព្រះគម្ពីរ (ហេព្រើរ ១១:៦) ហើយមនុស្សជាច្រើនទទួលយកការពិតនោះ។ ប៉ុន្តែដូចជាយើងបានឃើញស្រាប់ហើយថា គ្រប់ការទាំងអស់ដែលចាំបាច់សម្រាប់សេចក្តីសង្រ្គោះ គឺជាព្រះគ្រីស្ទដែលទ្រង់រកវាបានមកសម្រាប់យើងរាល់គ្នា ។

ឥឡូវនេះ ប្រសិនបើសេចក្តីជំនឿដ៏មានសារៈសំខាន់នេះ ត្រូវរកបានមកសម្រាប់មនុស្សទាំងអស់ដោយព្រះគ្រីស្ទ នោះមានន័យថា វាជាសេចក្តីជំនឿដែលមានល័ក្ខខ័ណ្ឌខ្លះ ឬវាជាសេចក្តីជំនឿដែលគ្មានល័ក្ខខ័ណ្ឌ។ ប្រសិនបើវាមិនមានល័ក្ខខ័ណ្ឌ នោះមនុស្សទាំងអស់សុទ្ធតែមានវា។ ប៉ុន្តែនោះជាអ្វីដែលផ្ទុយនឹងបទពិសោធ ហើយខុសនឹងបទគម្ពីរ (២ថែស្សាឡូនីច ៣:២)។ ប្រសិនបើសេចក្តីជំនឿដែលបានប្រទានមកនោះមានល័ក្ខខ័ណ្ឌខ្លះ អញ្ចឹងខ្ញុំសូមសួរថា តើមានល័ក្ខខ័ណ្ឌអ្វី?

អ្នកខ្លះនិយាយថា សេចក្តីជំនឿបានប្រទានមកដោយមានល័ក្ខខ័ណ្ឌ គឺជាការដែលយើងមិនប្រកែកនឹងព្រះគុណរបស់ព្រះជាម្ចាស់ហ្នឹងឯង។ ប៉ុន្តែការដែលមិនប្រកែកនោះមានន័យថា ស្តាប់បង្គាប់វិញទេតើ។ ហើយការស្តាប់បង្គាប់មានន័យថា ជឿ។ ដូច្នេះសម្លាញ់ទាំងនេះពិតជាចង់និយាយថា “សេចក្តីជំនឿបានប្រទានមកដល់អស់អ្នកណាដែលជឿ”។ (ឧទាហរណ៍៖ ដូចជាពួកអ្នកដែលមានជំនឿ!)។ នេះគឺជាការដែលល្ងីល្ងើណាស់!

ម្យ៉ាងវិញទៀត អ្នកខ្លះវែកញែកថា សេចក្តីជំនឿគឺមិនត្រូវបានរកមកសម្រាប់យើងដោយការសុគតរបស់ព្រះគ្រីស្ទទេ។ អញ្ចឹង តើសេចក្តីជំនឿគឺជាសកម្មភាពមួយនៃ

បំណងចិត្តរបស់យើងឬ? ប៉ុន្តែការនោះ វាផ្ទុយនឹងអ្វីដែលខគម្ពីរជាច្រើនបានបង្រៀនទៅវិញ មិនតែប៉ុណ្ណោះ វាថែមទាំងមិនយកចិត្តទុកដាក់នឹងការពិតដែលថា អ្នកមិនជឿស្លាប់នៅក្នុងអំពើបាប ព្រមទាំងមិនអាចធ្វើកិច្ចការខាងព្រលឹងវិញ្ញាណបានផង (១កូរិនថូស២:១៤)។ ដូច្នេះខ្ញុំនឹងត្រលប់ទៅឯគោលជំហរដែលថា សេចក្តីជំនឿគឺរកបានមកដោយសារព្រះគ្រីស្ទវិញ។

សេចក្តីជំនឿគឺជាផ្នែកដ៏សំខាន់មួយនៃភាពបរិសុទ្ធ។ នៅក្នុងការវែកញែកទី៨ ខ្ញុំបានបង្ហាញហើយថា ភាពបរិសុទ្ធគឺត្រូវរកបានមកសម្រាប់យើងដោយសារការសុគតរបស់ព្រះគ្រីស្ទ។ ដូច្នេះទ្រង់ក៏រកបានសេចក្តីជំនឿសម្រាប់យើងផងដែរ។ ដើម្បីបដិសេធការនេះ គឺត្រូវនិយាយថាទ្រង់រកបានតែភាពបរិសុទ្ធខ្លះប៉ុណ្ណោះ ឧទាហរណ៍៖ ការខ្វះជំនឿ។ តែគ្មាននរណាម្នាក់លើកឡើងរឿងនេះមកនិយាយឲ្យម៉ត់ចត់ទេ។

លើសពីនោះទៅទៀត ព្រះបានជ្រើសរើសរាស្ត្ររបស់ទ្រង់។ យើងដឹងថា ដើម្បីឲ្យពួកគេអាចនឹងបានបរិសុទ្ធ ព្រះជាម្ចាស់ "បានជ្រើសរើសយើង...ប្រយោជន៍ឲ្យយើងរាល់គ្នាបានបរិសុទ្ធ" (អេភេសូរ ១:៤)។ នេះជាថ្មីម្តងទៀតហើយ ដែលព្រះគម្ពីរនិយាយថា សេចក្តីជំនឿគឺជាផ្នែកដ៏សំខាន់នៃភាពបរិសុទ្ធ។ នៅក្នុងការជ្រើសរើសរាស្ត្ររបស់ទ្រង់ឲ្យបានបរិសុទ្ធ ព្រះជាម្ចាស់ត្រូវតែជ្រើសរើសពួកគេឲ្យមានសេចក្តីជំនឿ។

វាគឺជាផ្នែកនៃកិច្ចព្រមព្រៀងរវាងព្រះវរបិតា និងព្រះរាជបុត្រា ថាឲ្យពួកអ្នកដែលព្រះគ្រីស្ទបានសុគតជំនួស នឹងបានទទួលព្រះពរដែលព្រះវរបិតាសព្វព្រះហឫទ័យប្រទានឲ្យពួកគេ។ សេចក្តីជំនឿគឺជាព្រះពរមួយដែលព្រះវរបិតាប្រទានមក (ហេព្រើរ ៨:១០-១១)។

បទគម្ពីរនិយាយយ៉ាងច្បាស់ថា សេចក្តីជំនឿត្រូវរកបានមកសម្រាប់យើងដោយសារព្រះយេស៊ូវគ្រីស្ទ ដែលទ្រង់ជា "មេផ្តើម ហើយជាមេសម្រេចសេចក្តី

ជំនឿរបស់យើង” (ហេព្រើរ ១២:២)។ ដូចជាយើងបានអាន ពីការរៀបរាប់នេះ និងការរៀបរាប់នៅក្នុងកថាខណ្ឌទាំងបីខាងលើរួចមកហើយ យើងឃើញថា ទាំងអស់នេះសុទ្ធតែបញ្ជាក់ថា ការសុគតរបស់ព្រះគ្រីស្ទរកបានសេចក្តីជំនឿមកសម្រាប់រាស្ត្ររបស់ផងទ្រង់។ ដោយព្រោះតែមនុស្សទាំងអស់មិនសុទ្ធតែមានសេចក្តីជំនឿ នោះមានន័យថាព្រះគ្រីស្ទមិនបានសុគតសម្រាប់មនុស្សទាំងអស់ឡើយ។

*ការវែកញែកទី១០-* តាមរបៀបជាច្រើន រាស្ត្រអ៊ីស្រាអែលគឺជាការឆ្លុះបញ្ចាំងមួយនៃពួកជំនុំសម័យសញ្ញាថ្មីរបស់ព្រះជាម្ចាស់ (១កូរិនថូស ១០:១១)។ ពួកសង្ឃ និងយញ្ញបូជារបស់ពួកគេ គឺជាគំរូពីអ្វីដែលព្រះយេស៊ូវគ្រីស្ទនឹងត្រូវយាងមកធ្វើសម្រាប់ពួកជំនុំរបស់ព្រះ។ ទីក្រុងយេរូសាឡឹមរបស់ពួកគេ ត្រូវបានប្រើប្រាស់ជារូបភាពមួយនៃនគរស្ថានសួគ៌របស់ពួកអ្នកជឿ (ហេព្រើរ ១២:២២)។ ជនជាតិអ៊ីស្រាអែលពិតប្រាកដ គឺជាអ្នកជឿ(យ៉ូហាន១:៤៧) ហើយអ្នកជឿពិត គឺរាស្ត្រអ៊ីស្រាអែល (កាឡាទី ៣:២៩)។ ដូច្នេះខ្ញុំសូមវែកញែកតាមរបៀបនេះថាៈ

ប្រសិនបើ ព្រះជាម្ចាស់បានជ្រើសរើសប្រទេសយូដាចេញពីប្រទេសនានាលើលោកិយមកនេះ គឺដើម្បីបង្ហាញពីការទាក់ទងជាមួយពួកជំនុំ នោះបញ្ជាក់ឲ្យឃើញយ៉ាងច្បាស់ថា ការសុគតរបស់ព្រះគ្រីស្ទគឺសម្រាប់តែពួកជំនុំប៉ុណ្ណោះ មិនសម្រាប់លោកិយទាំងមូលទេ។ របៀបដែលព្រះបានធ្វើចំពោះរាស្ត្រដែលទ្រង់ជ្រើសរើសនៅក្នុងសម័យសញ្ញាចាស់ គឺជាកត្តាមួយដែលបង្ហាញថា សេចក្តីសង្គ្រោះដែលព្រះគ្រីស្ទរកបាន គឺមិនសម្រាប់មនុស្សទាំងអស់ទេ គឺសម្រាប់តែរាស្ត្រជ្រើសរើសរបស់ទ្រង់ប៉ុណ្ណោះ។

## ជំពូក ៥

*ការវែកញែកផ្អែកលើអត្ថន័យនៃពាក្យថា "ការប្រោសលោះ"*

*ការវែកញែកទី១១-* របៀបដែលព្រះគម្ពីរពិពណ៌នាពីគោលលទ្ធិ (សេចក្ដីបង្រៀន)មួយ ត្រូវតែជួយយើងឲ្យយល់ពីគោលលទ្ធិនោះហើយ។ មានពាក្យមួយដែលព្រះគម្ពីរ ធ្លប់ពិពណ៌នាពីសេចក្ដីសង្គ្រោះដែលព្រះគ្រីស្ទរកបាន គឺពាក្យថា សេចក្ដីប្រោសលោះ។ ឧទាហរណ៍ "យើងរាល់គ្នាមានសេចក្ដីប្រោសលោះក្នុងព្រះរាជបុត្រានោះ គឺជាសេចក្ដីផ្ដាច់បាប ដោយសារព្រះលោហិតទ្រង់" (កូល៉ុស ១:១៤)។ ពាក្យនោះមានន័យថា "លែងមនុស្សម្នាក់ឲ្យមានសេរីភាពរួចពីការចាប់ខ្លួន ដោយសងថ្លៃ"។ បុគ្គលនោះមិនបានទទួលការប្រោសលោះទេ លុះត្រាតែគេដោះលែងគាត់។ ដូច្នេះពាក្យនេះបង្រៀនយើងថា ព្រះគ្រីស្ទមិនអាចរកបានសេចក្ដីប្រោសលោះសម្រាប់អស់អ្នកដែលមិនត្រូវបានដោះលែងនោះឡើយ។ សេចក្ដីប្រោសលោះជាសកល (គ្រាន់តែជាឈ្មោះដែលគេហៅ) ដែលទីបំផុតទុកឲ្យមនុស្សមួយចំនួនជាប់នៅក្នុងការចាប់ខ្លួនដដែលនោះ គឺវាផ្ទុយស្រឡះទៅនឹងពាក្យថា សេចក្ដីប្រោសលោះជាសកល។

ជាការពិតណាស់ នៅក្នុងខគម្ពីរខ្លះគេហៅព្រះលោហិតរបស់ព្រះគ្រីស្ទថាតម្លៃ និងថ្លៃលោះ (ឧទាហរណ៍៖ ម៉ាថាយ ២០:២៨)។ គោលបំណងនៃថ្លៃលោះមួយ គឺដើម្បីរកឲ្យបាននូវសេចក្ដីប្រោសលោះ សម្រាប់អស់អ្នកដែលត្រូវសងថ្លៃលោះនោះ។ ជាការដែលមិនសមហេតុផល ដែលគេបានបង់ថ្លៃលោះរួចហើយ តែបុគ្គលនោះនៅតែជាពិរុទ្ធជនទៀត។ ដូច្នេះ តើគេអាចវែកញែកថា ព្រះគ្រីស្ទបានសុគតជំនួសមនុស្សទាំងអស់សម្រេចបានឬទេ បើមនុស្សទាំងអស់មិនបានទទួលការសង្គ្រោះផងនោះ ? តាមពិតទៅមានតែអស់អ្នកដែលត្រូវបានដោះលែងពីអំពើបាប

ប៉ុណ្ណោះ ដែលជាពួកអ្នកដែលព្រះគ្រីស្ទបានសុគតជំនួស។ "សេចក្តីប្រោសលោះ" មិនអាច "ជាសកលទូទៅ" លើសពី "ពួករ៉ូម" ដែលអាចជា "ពួកកាតូលិក" នោះទេ ! (ពាក្យថា "កាតូលិក" ជាភាសាក្រិក មានន័យថា សកល)។ សេចក្តីប្រោសលោះត្រូវតែជាក់លាក់ ព្រោះមានតែមនុស្សមួយចំនួនប៉ុណ្ណោះត្រូវបានប្រោសលោះ។

## ជំពូក ៦

*ការវែកញែកមួយដែលផ្អែកលើអត្ថន័យនៃពាក្យ "ការផ្សះផ្សា"*

*ការវែកញែកទី ១២-* មានពាក្យមួយទៀតដែលព្រះគម្ពីរប្រើដើម្បីពិពណ៌នាពីអ្វីដែលព្រះគ្រីស្ទរកបានដោយការសុគតរបស់ទ្រង់គឺពាក្យថា ការផ្សះផ្សា "ខ្មាំងសត្រូវ...ទ្រង់បានផ្សះផ្សា..." (កូល៉ុស ១:២១-២២)។ ការផ្សះផ្សាគឺជាការស្តារមិត្តភាពឡើងវិញរវាងពីរភាគីដែលពីមុនជាខ្មាំងសត្រូវនឹងគ្នា។ ការសង្រ្គោះដែលនិយាយនៅក្នុងព្រះគម្ពីរ គឺមានន័យថា ព្រះបានជានាជាមួយនឹងយើង ហើយយើងបានជានាជាមួយនឹងព្រះ។ ការទាំងពីរនេះត្រូវតែពិត។ ការផ្សះផ្សានៃភាគីមួយនិងការផ្សះផ្សានៃភាគីមួយទៀត គឺជាការងារពីរដាច់ដោយឡែកពីគ្នា ប៉ុន្តែការងារទាំងពីរនេះត្រូវបានតម្រូវឲ្យមាន ដើម្បីបង្កើតឲ្យមានការផ្សះផ្សាពេញលេញមួយ។ ជារឿងល្ងីល្ងើណាស់ ដែលគេនិយាយថា ព្រះបានជានាជាមួយនឹងមនុស្សទាំងអស់ តាមរយៈការសុគតរបស់ព្រះគ្រីស្ទ។ ប៉ុន្តែមានតែមនុស្សមួយចំនួនប៉ុណ្ណោះដែលបានជានាជាមួយនឹងទ្រង់។ ខ្ញុំសង្ឃឹមថា គ្មាននរណាម្នាក់នឹងនិយាយថា ព្រះបានជានាជាមួយមនុស្សតាមរបៀបហ្នឹងទេ។ ការផ្សះផ្សាបែបនេះគឺជាការផ្សះផ្សាមួយ ដែលលោតជើងតែម្ខាង! មិនមានការផ្សះផ្សាត្រឹមត្រូវទេ លុះត្រាណាភាគីទាំងពីរបានជានានឹងគ្នា។

លទ្ធផលនៃការសុគតរបស់ព្រះគ្រីស្ទ បានផ្សះផ្សាព្រះនឹងមនុស្ស ហើយមនុស្សនឹងព្រះ។ “យើងបានជាមេត្រីនឹងព្រះវិញទៅហើយ ដោយព្រះរាជបុត្រាទ្រង់សុគត” (រ៉ូម ៥:១០) ហើយ “ព្រះអម្ចាស់នៃយើងរាល់គ្នា ដែលឥឡូវនេះយើងបានជាមេត្រីដោយសារទ្រង់ហើយ” (រ៉ូម ៥:១១)។ ការផ្សះផ្សាទាំងពីរនេះក៏បាននិយាយផងដែរនៅក្នុង ២កូរិនថូស ៥:១៩-២០ “ព្រះ...កំពុងផ្សះផ្សា...នឹងអង្គទ្រង់” ហើយ“យើង...បានជាមេត្រីនឹងព្រះ”។

ឥឡូវនេះ តើការផ្សះផ្សាទ្វេភាគីនេះអាច “បានជាមេត្រី” ដោយគិតថាការសុគតរបស់ព្រះគ្រីស្ទគឺសម្រាប់មនុស្សទាំងអស់ម្ដេចបាន! ខ្ញុំមិនអាចយល់បានទាល់តែសោះ! ដ្បិត ប្រសិនបើមនុស្សទាំងអស់បានជាមេត្រីនឹងទ្រង់ដោយការសុគតរបស់ព្រះគ្រីស្ទមែន នោះនឹងបានជាមេត្រីនឹងគ្នាទាំងទ្វេភាគីហើយ ចុះហេតុអ្វីបានជាសេចក្ដីក្រោធរបស់ព្រះតែងនៅជាប់នឹងមនុស្សខ្លះទៅវិញ? (យ៉ូហាន ៣:៣៦)។ ជាការពិតណាស់ ព្រះគ្រីស្ទអាចសុគតសម្រាប់តែអស់អ្នកណាដែលបានជាមេត្រីប៉ុណ្ណោះ។

# ជំពូក ៧

## *ការវែកញែកមួយដែលមានមូលដ្ឋាន*
## *លើអត្ថន័យនៃពាក្យថា “ការធ្វើឲ្យស្កប់ចិត្ត”*

*ការវែកញែកទី ១៣-* ជាការពិតដែលពាក្យថា ការធ្វើឲ្យស្កប់ចិត្ត មិនត្រូវបានប្រើប្រាស់ក្នុងព្រះគម្ពីរភាសាអង់គ្លេស ដោយសំដៅទៅលើការសុគតរបស់ព្រះគ្រីស្ទ។ ប៉ុន្តែអ្វីដែលពាក្យនេះចង់និយាយ គឺដូចជា “ការសងថ្លៃពេញលេញមួយនូវអ្វីដែលស័ក្តិសមមួយដល់ម្ចាស់បំណុល ដោយកូនបំណុល”។ នេះគឺជាគំនិតមួយ ដែលត្រូវបានប្រើប្រាស់ជាញឹកញាប់នៅក្នុងព្រះគម្ពីរសញ្ញាថ្មី នៅពេលដែលនិយាយអំពីការសុគតរបស់ព្រះគ្រីស្ទ។

ក្នុងករណីនេះ មនុស្សជាកូនបំណុលរបស់ព្រះ ពីព្រោះពួកគេមិនបានកាន់តាមបញ្ញត្តរបស់ទ្រង់។ ការធ្វើឲ្យស្កប់ចិត្តនេះ គឺតម្រូវឲ្យសងសម្រាប់អំពើបាបរបស់យើង គឺជាសេចក្តីស្លាប់នោះឯង “ឈ្នួលរបស់អំពើបាប នោះជាសេចក្តីស្លាប់” (រ៉ូម ៦:២៣)។ ក្រឹត្យវិន័យរបស់ព្រះ គឺជាដើមចោទរបស់យើង ដែលបង្ហាញពីសេចក្តីយុត្តិធម៌ និងសេចក្តីពិតរបស់ព្រះ។ យើងជាប់ទោសជាអ្នកល្មើសច្បាប់ ដូច្នេះយើងសមតែស្លាប់។ សេចក្តីសង្គ្រោះអាចកើតឡើងបាន ប្រសិនបើព្រះគ្រីស្ទសងបំណុលរបស់យើង ហើយសេចក្តីយុត្តិធម៌របស់ព្រះក៏បានស្កប់ស្កល់ដែរ។ គេហៅការសុគតរបស់ទ្រង់ថាជា “ដង្វាយ” (អេភេសូរ ៥:២) ហើយជា “ដង្វាយធួននឹងបាប” (១យ៉ូហាន ២:២)។ ពាក្យថាដង្វាយមានន័យថា យញ្ញបូជានៃការសងថ្លៃមួយ ឬក៏យញ្ញបូជាមួយដើម្បីកែតម្រូវសម្រាប់អំពើបាបមួយ។ ដង្វាយឲ្យធួននឹងបាប មានន័យថា ជាដង្វាយមួយដើម្បីធ្វើឲ្យស្កប់ស្កល់ដល់សេចក្តីយុត្តិធម៌ដែលគេបានធ្វើខុស។ ដូច្នេះយើងអាចនឹងប្រើប្រាស់ពាក្យថា ការធ្វើឲ្យស្កប់ចិត្ត ដើម្បីពន្យល់ពីព្រះគម្ពីរទាំងមូលថា វាជាអត្ថន័យនៃការសុគតរបស់

ព្រះគ្រីស្ទ។

ឥឡូវនេះ ប្រសិនបើព្រះគ្រីស្ទបានបង្កើតឲ្យមាន ការធ្វើឲ្យស្កប់ចិត្តសម្រាប់មនុស្សទាំងអស់ដោយការសុគតរបស់ទ្រង់ នោះមានន័យថា ព្រះបានស្កប់ព្រះហឫទ័យពេញលេញជាមួយនឹងពួកគេហើយ។ ព្រះមិនអាចទាមទារការសងថ្លៃទីពីរដោយរបៀបណាមួយបានឡើយ។ អញ្ចឹង តើវាអាចកើតឡើងយ៉ាងដូចម្ដេចបាន ដែលថាព្រះគ្រីស្ទបានសុគតជំនួសមនុស្សទាំងអស់ ប៉ុន្តែបែរជាមានមនុស្សខ្លះរស់នៅ ហើយមនុស្សខ្លះស្លាប់ជាមនុស្សមានបាបក្រោមការផ្តន្ទាទោសនៃក្រឹត្យវិន័យរបស់ព្រះទៅវិញនោះ? ល្ហើយគេថាអញ្ចឹងក៏ថាទៅចុះ! តែខ្ញុំវិញនិយាយថា មានតែអ្នកដែលត្រូវបានដោះឲ្យរួចពីបំណុលនៅក្នុងជីវិតនេះប៉ុណ្ណោះដែលអាចជាអ្នកដែលព្រះគ្រីស្ទបានធ្វើឲ្យមានការស្កប់ចិត្តជំនួសបាន។

## ជំពូក ៨

*ការវែកញែកពីរចំណុចដែលមានមូលដ្ឋានលើតម្លៃនៃការសុគតរបស់ព្រះគ្រីស្ទ*

*ការវែកញែកទី១៤-* ព្រះគម្ពីរសញ្ញាថ្មីបាននិយាយជាញឹកញាប់ពីតម្លៃនៃការសុគតរបស់ព្រះគ្រីស្ទ។ ដោយតម្លៃនោះ ទ្រង់អាចទិញហើយរកបានការជាក់លាក់នានា។ ឧទាហរណ៍ដូចជា មានសេចក្តីថែងទុកមកថា សេចក្តីប្រោសលោះអស់កល្ប “គឺដោយយកព្រះលោហិតរបស់ទ្រង់វិញ” (ហេព្រើរ ៩:១២) ហើយថែងទៀតថា ពួកជំនុំរបស់ព្រះជាអ្នក “ដែលទ្រង់បានទិញដោយព្រះលោហិតព្រះអង្គទ្រង់” (កិច្ចការ ២០:២៨) ហើយគេហៅពួកគ្រីស្ទានថា “រាស្ត្រដ៏ជាកេរអាករ” (១ពេត្រុស ២:៩ English A.V.margin)។ ដោយការសុគតរបស់ទ្រង់ ព្រះគ្រីស្ទបានទិញការទាំង

អស់នោះមក សម្រាប់ពួកអ្នកដែលទ្រង់បានសុគតជំនួស។ ការទាំងអស់ដែលព្រះគម្ពីរបានចែង គឺជាលទ្ធផលនៃការសុគតរបស់ទ្រង់។ តម្លៃនៃការសុគតរបស់ទ្រង់បានទិញការប្រោសលោះឲ្យរួចពី អំណាចនៃអំពើបាប សេចក្ដីក្រោធរបស់ព្រះជាម្ចាស់ សេចក្ដីស្លាប់ អំណាចនៃសេចក្ដីអាក្រក់ បណ្ដាសាក្រឹត្យវិន័យ និងទោសនៃអំពើបាប។ តម្លៃនៃការសុគតរបស់ទ្រង់រកបាននូវ ការផ្សះផ្សាជាមួយនឹងព្រះ សេចក្ដីមេត្រី និងការប្រោសលោះដ៏នៅអស់កល្បជានិច្ច។ ឥឡូវនេះ ការទាំងអស់នេះគឺជាអំណោយទានដ៏ឥតគិតថ្លៃរបស់ព្រះ ពីព្រោះព្រះគ្រីស្ទបានទិញការទាំងអស់នោះមក។ ប្រសិនបើព្រះគ្រីស្ទបានសុគតសម្រាប់មនុស្សទាំងអស់ ចុះហេតុអ្វីបានជាមនុស្សទាំងអស់មិនបានទទួលការទាំងអស់នេះ? តើតម្លៃនៃការសុគតរបស់ទ្រង់មិនគ្រប់គ្រាន់ឬ? តើព្រះជាម្ចាស់អយុត្តិធម៌ឬ ដែលទ្រង់មិនបានប្រទាននូវអ្វីដែលព្រះគ្រីស្ទបានទិញមកសម្រាប់យើងនោះ។ នេះបង្ហាញយ៉ាងច្បាស់ណាស់ថា ព្រះគ្រីស្ទមិនអាចសុគតដើម្បីទិញការទាំងនេះសម្រាប់មនុស្សទាំងអស់បានទេ ប៉ុន្តែតាមពិតទៅ សម្រាប់តែពួកអ្នកដែលពេញចិត្តនឹងការទាំងនោះប៉ុណ្ណោះ។

*ការវែកញែកទី១៥*- មានឃ្លាជាច្រើនដែលបានប្រើប្រាស់ជាញឹកញាប់អំពីការសុគតរបស់ព្រះគ្រីស្ទដូចជា៖ សុគតសម្រាប់យើង ផ្ទុកអំពើបាបរបស់យើង ជាការធានារបស់យើង។ ឃ្លាទាំងនេះមានន័យយ៉ាងច្បាស់ណាស់ថា គឺជាព្រះគ្រីស្ទ។ នៅក្នុងការសុគតរបស់ទ្រង់ ព្រះគ្រីស្ទជាអ្នកជំនួសសម្រាប់អ្នកដទៃ ដើម្បីឲ្យពួកគេមានសេរីភាព។

នៅក្នុងការសុគតរបស់ទ្រង់ ប្រសិនបើព្រះគ្រីស្ទជាអ្នកជំនួសសម្រាប់អ្នកដទៃ តើចុះហេតុដូចម្ដេចបានជាពួកគេនៅតែស្លាប់ដោយការផ្ទុកអំពើបាបរបស់ខ្លួនឯងទៅវិញ? ព្រះគ្រីស្ទគួរតែមិនមែនជាអ្នកជំនួសសម្រាប់ពួកគេទេ។ ត្រង់នេះហើយដែលសបញ្ជាក់ឲ្យឃើញយ៉ាងច្បាស់ថា ទ្រង់មិនអាចសុគតសម្រាប់មនុស្ស

ទាំងអស់បានទេ។

ជាការពិតណាស់ ដែលនិយាយថាព្រះគ្រីស្ទបានសុគតជំនួសមនុស្សទាំងអស់ គឺជាមធ្យោបាយលឿនបំផុតដើម្បីបង្ហាញថា ទ្រង់មិនបានសុគតសម្រាប់អ្នកណាទាំងអស់។ ដ្បិតប្រសិនបើទ្រង់បានសុគតជំនួសមនុស្សទាំងអស់ តែមនុស្សទាំងអស់បែរជាមិនបានទទួលសេចក្តីសង្គ្រោះ នោះមានន័យថា ទ្រង់បរាជ័យក្នុងការសម្រេចគោលបំណងរបស់ទ្រង់។

## ជំពូក ៩

*ការវែកញែកទូទៅពីខគម្ពីរនានានៃបទគម្ពីរ*

*ការវែកញែកទី ១៦-* មានខគម្ពីរជាច្រើនដែលខ្ញុំអាចនឹងប្រើដើម្បីវែកញែកថា ព្រះគ្រីស្ទមិនបានសុគតសម្រាប់អំពើបាបរបស់មនុស្សទាំងអស់។ ខ្ញុំនឹងជ្រើសរើសតែ៩ចំណុចប៉ុណ្ណោះ ហើយបន្ទាប់មកនឹងបញ្ចប់ការវែកញែករបស់យើងនៅក្នុងផ្នែកនេះតែម្តង។

១. លោកុប្បត្តិ ៣:១៥ នេះជាខគម្ពីរដំបូងដែលព្រះបង្ហាញថា មានភាពខុសគ្នារវាងរាស្ត្ររបស់ព្រះ និងខ្មាំងសត្រូវរបស់ពួកគេ។ ដោយ “ពូជស្ត្រី” គឺសំដៅលើព្រះយេស៊ូវគ្រីស្ទ ហើយបន្ទាប់មកសំដៅលើអ្នកជឿព្រះគ្រីស្ទទាំងអស់។ (នេះបង្ហាញយ៉ាងច្បាស់ពីអ្វីដែលទំនាយពីពូជស្ត្រីបានសម្រេចនៅក្នុងព្រះគ្រីស្ទ និងនៅក្នុងរាស្ត្ររបស់ទ្រង់)។ ដោយ “ពូជពស់” សំដៅលើពួកអ្នកមិនជឿទាំងអស់នៃលោកិយនេះ (ចូរប្រៀបធៀប យ៉ូហាន ៨:៤៤)។ ដ្បិតព្រះបានសន្យាថា រវាងពូជស្ត្រី និងពូជពស់មានតែសេចក្តីខ្មាំងនឹងគ្នាប៉ុណ្ណោះ។ ការនេះបង្ហាញយ៉ាងច្បាស់ថា

ព្រះគ្រីស្ទដែលជាពូជស្ត្រី មិនបានសុគតសម្រាប់ពូជពស់ទេ!

២. ម៉ាថាយ ៧:២៣ ទ្រង់មានបន្ទូលថា មានមនុស្សដែលទ្រង់មិនដែលស្គាល់សោះ។ ប៉ុន្តែនៅកន្លែងមួយទៀត (យ៉ូហាន ១០:១៤-១៧) ទ្រង់មានបន្ទូលថា ទ្រង់ស្គាល់រាស្ត្ររបស់ទ្រង់ទាំងអស់ ។ ទ្រង់ជ្រាបយ៉ាងច្បាស់ពីពួកអ្នកដែលទ្រង់បានសុគតជំនួស។ ប្រសិនបើមានមនុស្សខ្លះទ្រង់មិនបានស្គាល់ នោះទ្រង់មិនអាចសុគតសម្រាប់ពួកគេបានទេ។

៣. ម៉ាថាយ ១១:២៥-២៧ ព្រះបន្ទូលត្រង់កន្លែងនេះ បញ្ជាក់យ៉ាងច្បាស់ថា មានមនុស្សខ្លះ ព្រះលោកមិនឲ្យឮដំណឹងល្អ។ ប្រសិនបើ បំណងព្រះហឫទ័យព្រះវរបិតានឹងមិនបើកសម្តែងដំណឹងល្អដល់ពួកគេ នោះព្រះគ្រីស្ទមិនអាចសុគតសម្រាប់ពួកគេបានឡើយ។ ហើយយើងគួរចំណាំថា នៅត្រង់នេះព្រះគ្រីស្ទថ្វាយការអរព្រះគុណដល់ព្រះវរបិតា សម្រាប់ការដែលទ្រង់ធ្វើឲ្យមានភាពខុសគ្នានេះនៅក្នុងចំណោមមនុស្ស គឺជាភាពខុសគ្នាមួយដែលមនុស្សខ្លះនៅតែបដិសេធមិនព្រមជឿ!

៤. យ៉ូហាន ១០:១១, ១៥-១៦ ២៧-២៨ បញ្ជាក់យ៉ាងច្បាស់ថា៖

ក. មនុស្សទាំងអស់មិនមែនសុទ្ធតែជាចៀមរបស់ព្រះគ្រីស្ទទេ។

ខ. ភាពខុសគ្នារវាងមនុស្សនឹងបានឃើញជាប្រាកដនៅថ្ងៃមួយ។

គ. ចៀមរបស់ព្រះគ្រីស្ទមានលក្ខណៈសម្គាល់ជា "អ្នកស្តាប់តាមសំឡេងរបស់ព្រះគ្រីស្ទ" តែអ្នកដទៃវិញ មិនស្តាប់តាមសំឡេងរបស់ទ្រង់ឡើយ។

ឃ. ចៀមជ្រើសរើស ដែលមិនទាន់មានលក្ខណៈសម្គាល់នៅឡើយ នឹងត្រូវបានស្គាល់ថាជា ("ចៀមផ្សេងទៀត")។

ង. ព្រះគ្រីស្ទមិនបានសុគតសម្រាប់មនុស្សទាំងអស់ទេ ប៉ុន្តែសម្រាប់ចៀមរបស់ទ្រង់ជាពិសេសវិញ។

ច. អស់អ្នកដែលព្រះគ្រីស្ទបានសុគតជំនួស គឺជាពួកអ្នកដែលព្រះវរបិតាបានប្រទានមកទ្រង់។ ដូច្នេះទ្រង់មិនអាចសុគតសម្រាប់ អស់អ្នកណាដែលព្រះវរបិតា មិនបានប្រទានមកទ្រង់នោះទេ។

៥. រ៉ូម ៨:៣២-៣៤ បង្ហាញយ៉ាងច្បាស់ថា ការសុគតរបស់ព្រះគ្រីស្ទជាកម្មសិទ្ធិរបស់ពួកជ្រើសរើសរបស់ព្រះប៉ុណ្ណោះ ហើយការអង្វរជំនួសរបស់ព្រះគ្រីស្ទក៏សម្រាប់តែពួកទាំងនោះដែរ។

៦. អេភេសូរ ១:៧ ខនេះយើងត្រូវតែនិយាយថា ប្រសិនព្រះលោហិតរបស់ព្រះគ្រីស្ទបានហូរសម្រាប់មនុស្សទាំងអស់ នោះមនុស្សទាំងអស់នឹងមានការប្រោសលោះ និងការអត់ទោស។ ប៉ុន្តែ វាបានបញ្ជាក់យ៉ាងច្បាស់ហើយថា មនុស្សទាំងអស់មិនមានការទាំងនេះទេ។

៧. ២កូរិនថូស ៥:២១ ដូច្នេះ ក្នុងការសុគតរបស់ទ្រង់ ព្រះគ្រីស្ទបានត្រឡប់ជាតួបាប សម្រាប់អ្នកដែលបានត្រឡប់ទៅជាសេចក្ដីសុចរិតនៃព្រះ ដោយនូវព្រះអង្គនោះឯង។ ប្រសិនបើទ្រង់ជាតួបាបសម្រាប់មនុស្សទាំងអស់ ចុះហេតុអ្វីបានជាមនុស្សទាំងអស់មិនបានត្រលប់ទៅជាសុចរិត?

៨. យ៉ូហាន ១៧:៩ ការអង្វរជំនួសរបស់ព្រះគ្រីស្ទមិនសម្រាប់មនុស្សទាំងអស់ទេ រីឯការសុគតរបស់ទ្រង់ក៏ដូច្នោះដែរ។ (សូមមើល ផ្នែកទី ២ ជំពូក ៤ និង ៥)។

៩. អេភេសូរ ៥:២៥ ព្រះគ្រីស្ទស្រឡាញ់ពួកជំនុំ ហើយនោះជាគំរូមួយដែលបុរសគួរស្រឡាញ់ប្រពន្ធខ្លួន។ ប៉ុន្តែប្រសិនបើព្រះគ្រីស្ទស្រឡាញ់អ្នកដទៃទៀតដូចជាពួកជំនុំរបស់ទ្រង់ ដោយសុគតសម្រាប់ពួកគេផងនោះ មានន័យថា បុរសៗពិតជាអាចស្រឡាញ់អ្នកដទៃទៀតក្រៅពីប្រពន្ធខ្លួនបានយ៉ាងដូច្នោះដែរ!

ខ្ញុំគិតថា ខ្ញុំអាចបន្ថែមការវែកញែកផ្សេងៗទៀតបាន ប៉ុន្តែបើពិនិត្យមើលទៅលើអ្វីដែលខ្ញុំបាននិយាយខាងដើមនេះ ខ្ញុំទុកចិត្តថាអ្វីៗដែលបានវែកញែកនោះ បានគ្រប់

គ្រាន់ដើម្បីឲ្យគេស្កប់ចិត្តបានហើយ ប៉ុន្តែអ្នកដែលរឹងចចេសនឹងមិនស្កប់ចិត្តទេ ទោះជាខ្ញុំខំបន្ថែមការវែកញែកទៀតក៏ដោយ។ អញ្ចឹងខ្ញុំសូមបញ្ចប់ការវែកញែករបស់ខ្ញុំតែត្រឹមនេះចុះ។

# ផ្នែកទី ៤

*ការវែកញែកដែលឆ្លើយតបទៅនឹងការប្រោសលោះជាសកល*

**ជំពូក**

១. ចម្លើយចំពោះហេតុផលទូទៅបួន ដែលគេផ្តល់ឲ្យជាញឹកញាប់សម្រាប់ ការប្រោសលោះជាសកល

២. ការពន្យល់សេចក្តីផ្តើមនៃខគម្ពីរនានាដែលប្រើប្រាស់ពាក្យ ថា លោកិយ

៣. ការសិក្សាលម្អិតនៃខគម្ពីរយ៉ូហាន ៣:១៦

៤. ការសិក្សាលម្អិតនៃខគម្ពីរយ៉ូហាន ២:១-២

៥. ការពន្យល់ត្រួសៗនៃអត្ថបទគម្ពីរចំនួន៦

៦. ការពន្យល់នៃខគម្ពីរនានាដែលប្រើពាក្យថា មនុស្សទាំងអស់ ឬក៏ មនុស្សគ្រប់គ្នា

៧. ការពន្យល់នៃខគម្ពីរនានាដែលហាក់ដូចជាវែកញែកថា អស់អ្នកដែលព្រះគ្រីស្ទបានសុគតជំនួសនៅតែអាចវិនាសបាន

៨. ការបង្ហាញពីការត្រិះរិះដែលនាំឲ្យភាន់ច្រឡំមួយចំនួន

# ជំពូក ១

*ចម្លើយទៅកាន់ហេតុផលទូទៅបួន ដែលគេផ្ដល់ឲ្យញឹកញាប់*

*សម្រាប់ការប្រោសលោះសកលមួយ*

*ហេតុផលទី១-* មានអត្ថបទគម្ពីរជាច្រើនដែលបានថែងពីអ្វីដែលព្រះគ្រីស្ទបានទទួលដោយការសុគត នៅក្នុងន័យទូទៅ និងមិនជាក់លាក់។ ដូច្នេះ គេបានវែកញែកថា ការសុគតរបស់ទ្រង់មិនអាចសម្រាប់គោលបំណងជាក់លាក់ ឬក៏មានកំណត់ទេ។

ឧទាហរណ៍៖ បទគម្ពីរថែងពីតម្លៃមិនអាចកំណត់បាននៃការសុគតរបស់ព្រះគ្រីស្ទ។ ព្រះគម្ពីរថែងពីការបង្ហូរ "ព្រះលោហិតព្រះអង្គទ្រង់" (កិច្ចការ ២០:២៨)។ ព្រះគម្ពីរថែងថា ការសុគតរបស់ព្រះគ្រីស្ទគឺជាដង្វាយ "ឥតសៅហ្មង" ដែលត្រូវបានថ្វាយតាមរយៈ "ព្រះវិញ្ញាណដ៏គង់នៅអស់កល្បជានិច្ច" (ហេព្រើរ ៩:១៤)។ ព្រះលោហិតរបស់ព្រះគ្រីស្ទត្រូវបានពិពណ៌នាថាជា "តម្លៃ" ដែលមានតម្លៃលើសជាងប្រាក់ ឬមាស (១ពេត្រុស ១:១៨)។ ឥឡូវ ប្រសិនបើការសុគតនៃព្រះរាជបុត្រានៃព្រះ ពិតជាមានតម្លៃឥតកាត់ថ្លៃបានដូច្នេះ តើវានៅតែមិនគ្រប់គ្រាន់សម្រាប់មនុស្សទាំងអស់ឬ?

យើងមិនបដិសេធថា ការសុគតរបស់ព្រះគ្រីស្ទជាតម្លៃគ្រប់គ្រាន់ដើម្បីប្រោសលោះមនុស្សទាំងអស់នោះទេ។ តែយើងចង់និយាយថា បទគម្ពីរបានថែងកាន់តែច្បាស់ថា ការសុគតរបស់ព្រះគ្រីស្ទគឺមិនដើម្បីទុកជាថ្លៃលោះសម្រាប់មនុស្សទាំងអស់ទេ។ ការវែកញែកនេះ នឹងពន្យល់ក្បោះក្បាយនៅជំពូកទី ២ ៣ ៤ ៥ និង៦។ អ្នកខ្លះអាចនឹងបដិសេធយ៉ាងដូច្នេះថា ប្រសិនបើព្រះគ្រីស្ទមិនបានសុគតសម្រាប់មនុស្សទាំងអស់ទេ អញ្ចឹងមានន័យថា ការប្រកាសដំណឹងល្អដល់មនុស្សទាំងអស់ដែលព្រះបានបង្គាប់មកយើងនោះ គឺជាការឥតប្រយោជន៍ (ម៉ាថាយ ២៨:១៩)។ ខ្ញុំសូម

ឆ្លើយតបនឹងចំណុចនេះថា៖

ក. មានមនុស្សខ្លះនៅក្នុងគ្រប់ជាតិសាសន៍បានទទួលការសង្គ្រោះ តែការនោះមិនអាចសម្រេចបានទេ លុះត្រាតែគេផ្សាយដំណឹងល្អទៅដល់គ្រប់ប្រជាជាតិ។

ខ. បច្ចុប្បន្ននេះ ដោយសារតែមិនមានអភ័យឯកសិទ្ធិពិសេសណា ទៀតសម្រាប់ជនជាតិយូដា នោះដំណឹងល្អត្រូវបានប្រកាសដល់ មនុស្សទាំងអស់ ដោយមិនមានការបែងចែកជាតិសាសន៍។

គ. ការត្រាស់ហៅឲ្យមនុស្សបានជឿ មិនមែនជាការត្រាស់ហៅមួយ នៅពេលដំបូង ដើម្បីឲ្យជឿថាព្រះគ្រីស្ទបានសុគតសម្រាប់ពួកគេ ជាពិសេសនោះទេ ប៉ុន្តែជាការត្រាស់ហៅមួយដើម្បីឲ្យជឿថា មិន មានអ្នកណាផ្សេងទៀតក្រៅពីព្រះគ្រីស្ទ ដែលសេចក្តីសង្គ្រោះត្រូវ បានប្រកាសមក តាមរយៈទ្រង់។

ឃ. អ្នកប្រកាសដំណឹងល្អ មិនអាចដឹងថានរណាមួយនៅក្នុងកន្លែង

ប្រជុំរបស់ពួកគេ ជារាស្ត្រជ្រើសរើសរបស់ព្រះបានឡើយ។ ដូច្នេះ ពួកគេត្រូវតែស្រែកហៅមនុស្សទាំងអស់ឲ្យបានជឿ ហើយសន្យាថា អស់ អ្នកណាដែលជឿនឹងបានទទួលការសង្គ្រោះ ដ្បិតមានភាព គ្រប់គ្រាន់នៅ ក្នុងការសុគតរបស់ព្រះគ្រីស្ទ ដើម្បីសង្គ្រោះអ្នកដែល ជឿ។

គំនិតទាំងនេះគួរបានគ្រប់គ្រាន់ ដើម្បីធ្វើឲ្យយើងដឹងច្បាស់ថា គេត្រូវផ្សាយដំណឹងល្អដល់មនុស្សទាំងអស់ ទោះបីជាមនុស្សទាំងអស់មិនបានទទួលការសង្គ្រោះក៏ដោយ។

(នៅសំណេរដើម ត្រង់ចំណុចនេះ លោក ចន អូវ៉ិន មានផ្នែកដ៏វែងមួយដែលនិយាយអំពីការប្រើប្រាស់ពាក្យថា “លោកិយ” និង “មនុស្សទាំងអស់” តែយើងបានយកទៅដាក់ក្នុងជំពូក ២ “លោកិយ” និង នៅជំពូក ៦ “មនុស្សទាំងអស់” វិញ)។

*ហេតុផលទី២-* ជួនកាលព្រះគម្ពីរហាក់ដូចជាវែកញែកថា មនុស្សមួយចំនួនដែលព្រះគ្រីស្ទបានសុគតជំនួសនោះ មិនបានទទួលការសង្គ្រោះពិតប្រាកដទេ។ ត្រង់ចំណុចនេះ គេបានវែកញែកថា ព្រះគ្រីស្ទបានសុគតសម្រាប់មនុស្សទាំងអស់ ប៉ុន្តែមានតែមួយចំនួនប៉ុណ្ណោះដែលបានសម្រេចនូវល័ក្ខខ័ណ្ឌត្រឹមត្រូវ។

យើងត្រូវតែយល់ថា ជាញឹកញាប់បទគម្ពីរពិពណ៌នាពីមនុស្សដោយលក្ខណៈរូបរាងខាងក្រៅ មិនដោយសភាពពិតខាងក្នុងរបស់ពួកគេទេ។ ឧទាហរណ៍៖ ក្រុងយេរូសាឡឹម គេហៅថា “ទីក្រុងបរិសុទ្ធ” (ម៉ាថាយ ២៧:៥៣)។ តែយើងដឹងថា ទីក្រុងយេរូសាឡឹម មិនពិតជាទីក្រុងបរិសុទ្ធនោះទេ។

ស្រដៀងគ្នានេះដែរ ជាញឹកញាប់បទគម្ពីរបានពិពណ៌នាពីមនុស្ស ដូចជាពាក្យថា “បរិសុទ្ធ” ឬ “អ្នកបរិសុទ្ធ” ឬក៏ពាក្យថា “អ្នករើសតាំង” ពីព្រោះពាក្យទាំងនេះទាក់ទងជាមួយនឹងសហាគមន៏នៃពួកអ្នកជឿ។ សាវ័ក ប៉ុល បាននិយាយអំពីអ្នកជឿនៅទីក្រុងភីលីពថា “គួរគប្បីឲ្យខ្ញុំគិតពីអ្នករាល់គ្នាដូច្នេះដែរ” (ភីលីព ១:៧)។ យើងមិនអាចសន្និដ្ឋានចំណុចនេះថា មនុស្សទាំងអស់ដែលសាវ័ក ប៉ុល បានសរសេរទៅកាន់នោះ សុទ្ធតែជាពួកអ្នកជឿនោះទេ។ សាវ័ក ប៉ុល បានវិនិច្ឆ័យពួកគេចេញពីការយល់ដឹងរបស់គាត់អំពីពួកគេតែប៉ុណ្ណោះ។ ដូច្នេះ ប្រសិនបើមានមនុស្សខ្លះបានដាច់ចេញ នោះយើងមិនអាចនិយាយថា ព្រះមានព្រះហឫទ័យចង់សង្គ្រោះមនុស្សទាំងអស់ តែតោងចាប់តែមនុស្សមួយចំនួន បានទេ។ អស់អ្នកណាដែលដាច់ចេញ នោះមិនមែនជាអ្នកជឿពិតប្រាកដទេ ទោះបីជាលក្ខណៈខាងក្រៅជាអ្នកជឿក៏ដោយ។ (ការវែកញែកនេះ គឺមានប្រសិទ្ធភាពពេញលេញជាងនៅជំពូក ៧)។

*ហេតុផលទី ៣-* ជួនកាល បទគម្ពីរបានវែកញែកថា សេចក្ដីសង្គ្រោះត្រូវបានផ្ដល់ឲ្យជាទូទៅដល់មនុស្សទាំងអស់ ប្រសិនបើពួកគេជឿ។ ត្រង់ចំណុចនេះ គេបានសន្និដ្ឋានថា ព្រះគ្រីស្ទបានសុគតសម្រាប់មនុស្សទាំងអស់។

ជាការពិតដែលបទគម្ពីរបានចែងថា សេចក្ដីជំនឿ និងសេចក្ដីសង្គ្រោះត្រូវនៅជាប់គ្នាជានិច្ច។ អស់អ្នកដែលជឿនឹងបានសង្គ្រោះ។ ប៉ុន្តែការនេះមិនមានន័យលើសពីពាក្យថា អ្នកជឿទាំងអស់ពិតជាបានទទួលការសង្គ្រោះពិតប្រាកដ នោះទេ។ តែវាមិនអាចមានន័យថា ព្រះចង់សង្គ្រោះមនុស្សទាំងអស់ ប្រសិនបើពួកគេជឿនោះទេ ពីព្រោះ

ក. តាមពិតទៅ ព្រះមិនបានប្រទានជីវិតអស់កល្បដល់មនុស្សទាំង អស់ទេដ្បិតមនុស្សជាតិមួយពួកធំមិនដែលបានឮពីដំណឹងល្អសោះ។

ខ. ការបង្គាប់ជាទូទៅរបស់ព្រះ មិនបានប្រាប់យើងពីគោលបំណង ជាក់លាក់របស់ទ្រង់ថាជាអ្វីនោះទេ។ ជាទូទៅ វាជាព្រះរាជបញ្ជា របស់ទ្រង់ដែលមនុស្សត្រូវតែស្ដាប់បង្គាប់តាមទ្រង់។ ប៉ុន្តែ ឧទាហរណ៍នៅ ក្នុងករណីពិសេស អំពីស្ដេចផារ៉ោន គោលបំណង របស់ព្រះគឺផ្សេងគ្នាពី ការបង្គាប់របស់ទ្រង់ ដ្បិតទ្រង់បានធ្វើឲ្យចិត្តរបស់ស្ដេចផារ៉ោនរឹងរូស នៅពេលដែលទ្រង់បានបង្គាប់ឲ្យគាត់ ស្ដាប់បង្គាប់ (និក្ខមនំ ៩:២១)។

គ. សេចក្ដីសន្យានៃដំណឹងល្អ បានបង្រៀនពីចំណងដែលមិនអាច ផ្ដាច់ពីគ្នាបាន រវាងសេចក្ដីជំនឿ និងសេចក្ដីសង្គ្រោះ។ ប៉ុន្តែ នេះមិន មានន័យថា ព្រះមានបំណងឲ្យមនុស្សទាំងអស់បានប្រែចិត្ត និងជឿ នោះទេ អញ្ចឹងតើអ្វីទៅជាគោលបំណងនៃការជ្រើសរើសរបស់ព្រះ? ប្រសិនបើ ទ្រង់មានបំណងដើម្បីសង្គ្រោះមនុស្សទាំងអស់ ចុះហេតុ អ្វី បានជាជ្រើសរើសតែមនុស្សមួយចំនួន? មួយវិញទៀត បើ ទ្រង់មាន បំណងដើម្បីសង្គ្រោះមនុស្សទាំងអស់ ចុះហេតុអ្វី បានជាទ្រង់សម្រេចគោលបំណងរបស់ទ្រង់មិនបាន? (វាគ្មាន ប្រយោជន៍ទេ ដែលគេវែកញែកថា ទ្រង់សម្រេចគោលបំណង របស់ទ្រង់មិនបាននោះ ពីព្រោះពួកគេមិនជឿ។ ទ្រង់ច្បាស់ជា បានជ្រាបជាមុនហើយថា ពួកគេនឹងមិនជឿ។ អញ្ចឹងចុះហេតុអ្វីបាន ជាគោលបំណងដែលទ្រង់បាន

ជ្រាបហើយ ទ្រង់មិនអាចសម្រេចបានទៅវិញ?)

ការពិតលើសពីនោះទៅទៀត អ្នកជឿ និងអ្នកមិនជឿបានរស់នៅលាយឡំជាមួយគ្នា ហើយអ្នកប្រកាសដំណឹងល្អមិនអាចប្រាប់ជាប្រាកដថា នរណាជារាស្ត្រជ្រើសរើស ហើយនរណាមិនមែនជារាស្ត្រជ្រើសរើសរបស់ព្រះបានទេ នេះមានន័យថា អ្នកប្រកាសដំណឹងល្អត្រូវតែប្រកាសជាទូទៅដល់មនុស្សទាំងអស់។ ការនេះមិនមានន័យថា សេចក្តីសន្យានៃដំណឹងល្អ ត្រូវបានធ្វើឡើងជាទូទៅដល់មនុស្សទាំងអស់ទេ ប៉ុន្តែគ្រាន់តែត្រូវបានប្រកាសដល់មនុស្សទាំងអស់ប៉ុណ្ណោះ។ ដោយព្រោះគេត្រូវទទួលព្រះគ្រីស្ទដោយសេចក្តីជំនឿ និងដោយព្រោះសេចក្តីជំនឿ គឺជាអំណោយទានរបស់ព្រះចំពោះអស់អ្នកដែលទ្រង់សព្វព្រះហឫទ័យ នោះបង្ហាញឲ្យឃើញច្បាស់ថា ទ្រង់មិនអាចមានគោលបំណងប្រទានសេចក្តីសង្គ្រោះ ដល់អស់អ្នកណាដែលទ្រង់មិនបានប្រទានជំនឿឲ្យនោះឡើយ។

*ហេតុផលទី៨*- ប្រសិនបើព្រះគ្រីស្ទមិនបានសុគតសម្រាប់មនុស្សទាំងអស់ នោះបទគម្ពីរច្បាស់ជាបានព្យាយាមប្រាប់ថា មនុស្សទាំងអស់គួរតែជឿហើយមែនទេ?

គេត្រូវតែយល់ថា សេចក្តីជំនឿដែលព្រះគម្ពីរបានចែង មានដំណាក់កាលផ្សេងៗនៃការលូតលាស់ និងលំដាប់លំដោយត្រឹមត្រូវមួយនៃការប្រើប្រាស់។ យើងមិនត្រូវគិតថា ព្រះគម្ពីរព្យាយាមបញ្ចុះបញ្ចូលឲ្យជឿ ដោយតម្រូវឲ្យមនុស្សទាំងអស់ជឿថា ព្រះគ្រីស្ទបានសុគតសម្រាប់ខ្លួនជាពិសេសនោះទេ។ នៅមានការជាច្រើនផ្សេងទៀតដែលគេជឿថា មនុស្សទាំងអស់អាចទទួលបាន។ គ្មាននរណាម្នាក់ត្រូវបានបង្គាប់ឲ្យជឿលើអ្វីមួយ ដែលគ្មានភស្តុតាងគ្រប់គ្រាន់សម្រាប់ការនោះបានទេ។ ឧទាហរណ៍៖

ក. ការដំបូងដែលមនុស្សត្រូវជឿ គឺពួកគេមិនអាចសង្គ្រោះខ្លួនឯងបាន ដោយព្រោះពួកគេជាមនុស្សមានបាប។ មនុស្សគ្រប់រូប មាន

ភស្តុតាងសម្រាប់ការនេះនៅក្នុងខ្លួនម្នាក់ៗ ដូចជាសាវ័ក ប៉ុល បាន

បង្ហាញនៅក្នុងគម្ពីររ៉ូម ជំពូក ១, ២ និង ៣ រួចហើយ។ តែ មានមនុស្ស ជាច្រើនពុំបានជឿការនេះទេ ទោះបីជាពួកគេមាន ភស្តុតាងជាច្រើនសម្រាប់ការនេះក៏ដោយ!

ខ. ដំណឹងល្អហៅអ្នកមានបាបឲ្យជឿថា ព្រះបានប្រទានផ្លូវសង្គ្រោះមួយ ដោយព្រះយេស៊ូវគ្រីស្ទ។ មនុស្សរាប់លាននាក់បានឮពីដំណឹងល្អ តែគេបដិសេធមិនព្រមទទួលយក ទោះបីជាមានភស្តុតាងជា ច្រើនសម្រាប់ការនេះក៏ដោយ។

គ. ដំណឹងល្អហៅអ្នកមានបាបឲ្យជឿថា មិនមានព្រះអង្គសង្គ្រោះ ណាផ្សេងទៀតក្រៅពីព្រះយេស៊ូវគ្រីស្ទឡើយ។ ត្រង់នេះគឺជារឿង មួយដែលពួកយូដាបដិសេធមិនព្រមជឿ តែពួកគេបែរជាហៅទ្រង់ ថា ជាខ្មាំងសត្រូវរបស់ព្រះជំនួសវិញ!

ការត្រាស់ហៅជាទូទៅទាំងនេះមិនត្រូវបានធ្វើឡើង ដោយព្រោះព្រះគ្រីស្ទបានសុគតសម្រាប់មនុស្សទាំងអស់ទេ ប៉ុន្តែដោយព្រោះសេចក្តីពិតទាំងនេះ ជាភស្តុតាងបង្ហាញដល់មនុស្សទាំងអស់វិញ។ ហើយទាល់តែកិច្ចការនៃសេចក្តីជំនឿទាំងនេះបានសម្រេច ទើបគេបានទទួលការត្រាស់ហៅឲ្យជឿថា ព្រះយេស៊ូវបានសុគតសម្រាប់ខ្លួនគេជាពិសេសបាន។ មនុស្សមួយចំនួនបានកត់សម្គាល់ឃើញថា បទជំនឿរបស់ពួកសាវ័ក (បទជំនឿសង្ខេបរបស់ពួកគ្រីស្ទានសម័យបុរាណ) បានដាក់ត្រង់ចំណុចចុងក្រោយថា “ការអត់ទោសនៃអំពើបាប និងជីវិតអស់កល្បជានិច្ច” មានន័យថា មុនពេលដែលយើងអាចមកដល់ត្រង់នេះ មានការផ្សេងទៀតដែលយើងត្រូវជឿ ហើយមានភស្តុតាងជាច្រើនសម្រាប់ការទាំងអស់នេះ។ យើងត្រឡប់ទៅឯការវែកញែកនេះម្តងទៀតនៅជំពូក៨។

## ជំពូក ២

*ការពន្យល់សេចក្តីផ្តើមនៃខគម្ពីរដែលប្រើពាក្យថា “លោកិយ”*

ខ្ញុំមានការស្ទាក់ស្ទើរក្នុងការនិយាយពីបទគម្ពីរដែលត្រូវប្រើ ដើម្បីគាំទ្រដល់គំនិតដែលថា ព្រះគ្រីស្ទបានសុគតសម្រាប់មនុស្សទាំងអស់។ នេះមិនមែនដោយព្រោះខគម្ពីរទាំងនេះធ្វើឲ្យខ្ញុំពិបាកពន្យល់នោះទេ ប៉ុន្តែដោយព្រោះខ្ញុំមិនចង់និយាយពីការមិនពិត។ ប៉ុន្តែខ្ញុំគិតថា ប្រហែលជាអ្នកដែលប្រកាន់ការខុសឆ្គងរឿងនេះ បាននាំយកខគម្ពីរភាគច្រើននៃខគម្ពីរទាំងនេះ ទៅក្នុងការកត់សម្គាល់របស់អ្នកអានរបស់ខ្ញុំរួចទៅហើយ។ ដូច្នេះ ឥឡូវនេះខ្ញុំត្រូវតែផ្តល់ចម្លើយឲ្យដល់បងប្អូន ដើម្បីឆ្លើយតបទៅកាន់ពួកគេ។

មិនត្រូវទទួលការបក់ផាត់ដោយគ្រាន់តែសំឡេងនៃពាក្យឡើយ។ ចូរចងចាំជានិច្ចពីរបៀបទូទៅនៃការបង្រៀនរបស់ព្រះគម្ពីរ ហើយមិនត្រូវបកស្រាយខគម្ពីរ ឲ្យផ្ទុយទៅនឹងរបៀបទូទៅនៃបទគម្ពីរទាំងមូលឡើយ។ ឧទាហរណ៍៖ យើងអាចបង្ហាញថាពាក្យ “លោកិយ” ត្រូវតែមានន័យសំដៅទៅលើអ្វីដែលនៅជុំវិញបរិបទខគម្ពីរនោះចង់និយាយ ។ ពាក្យ “លោកិយ” មានការប្រើប្រាស់អត្ថន័យប្រាំផ្សេងគ្នាគឺ៖

| | |
|---|---|
| ១. សកលលោក ឬក៏ | យ៉ូប ៣៩:១៣ |
| ផែនដីដែលមានមនុស្សរស់នៅនេះ | ម៉ាថាយ ១៣:៣៨ |
| | កិច្ចការ ១៧:២៤ |
| | អេភេសូរ ១:៤ |
| | និងកន្លែងជាច្រើនទៀត |

២. មនុស្សដែលនៅក្នុងពិភពលោកនេះដូចជា៖

មនុស្សទាំងអស់ គ្មានការលើកលែង រ៉ូម ៣:៦

មនុស្សទាំងអស់ គ្មានការបែងចែក យ៉ូហាន ៧:៤

មនុស្សជាច្រើន ម៉ាថាយ ១៨:៧

មនុស្សភាគច្រើន រ៉ូម ១:៨

ចក្រភពរ៉ូម លូកា ២:១

មនុស្សល្អ យ៉ូហាន ៦:៣៣

មនុស្សអាក្រក់ យ៉ូហាន ១៥:១៧

និងកន្លែងជាច្រើនទៀត

៣. លោកិយ ជាប្រព័ន្ធខូចអាក្រក់មួយ កាឡាទី ៦:១៤

និងកន្លែងជាច្រើនទៀត

៤. ស្ថានមនុស្ស យ៉ូហាន ១៨:៣៦

និងកន្លែងជាច្រើនទៀត

៥. នគររបស់សាតាំង យ៉ូហាន ១៤:៣០

និងកន្លែងជាច្រើនទៀត

អ្នកខ្លះអាចនឹងបដិសេធថា ទេ ពាក្យនេះត្រូវតែមានន័យតែមួយដូចគ្នា ទោះជាវាកើតឡើងនៅកន្លែងណាក្នុងព្រះគម្ពីរក៏ដោយ។ ខ្ញុំឆ្លើយថា ការនោះមិនត្រឹមត្រូវទេ ដ្បិតមានកន្លែងខ្លះព្រះគម្ពីរបានប្រើប្រាស់ន័យផ្សេងគ្នាសម្រាប់ពាក្យដដែលនោះនៅក្នុងប្រយោគតែមួយ។ នៅក្នុងគម្ពីរម៉ាថាយ ៨:២២ “ស្លាប់” មានន័យថា ទីមួយស្លាប់ខាងព្រលឹងវិញ្ញាណ ហើយទីពីរស្លាប់ខាងរូបកាយ។ នៅក្នុងគម្ពីរ យ៉ូហាន ១:១០ ពាក្យថា “លោកិយ” ទីមួយមានន័យថា ផែនដីសម្រាប់មនុស្សរស់នៅ ទីពីរ

សំដៅលើភពផែនដី ហើយទីបីសំដៅលើមនុស្សមួយចំនួនដែលរស់នៅលើផែនដីនេះ។

ដូចគ្នានេះផងដែរ ប្រសិនបើជួនកាលគេប្រើពាក្យថា “លោកិយ” សំដៅមនុស្សដែលតិចជាងមនុស្សទាំងអស់ដែរ នោះគេមិនអាចវែកញែកបានថា ពាក្យនេះតែងតែមានន័យសំដៅលើមនុស្សទាំងអស់បានទេ។ ហើយមានកន្លែងជាច្រើនដែលបញ្ជាក់យ៉ាងច្បាស់ថា ពាក្យនេះសំដៅលើមនុស្សដែលតិចជាងមនុស្សទាំងអស់។

លូកា ២:១ “មនុស្សទាំងអស់នៅផែនដី” បង្ហាញយ៉ាងច្បាស់ថា វាសំដៅលើចក្រភពរ៉ូម មិនមែនសំដៅលើមនុស្សទាំងអស់ដែលរស់នៅលើផែនដីនេះឡើយ។

យ៉ូហាន ១:១០ “លោកិយ...មិនស្គាល់ទ្រង់ទេ”។ ប៉ុន្តែ មានមនុស្សមួយចំនួនបានជឿទ្រង់។ ដូច្នេះពាក្យថា “លោកិយ” មិនអាចសំដៅលើមនុស្សទាំងអស់បានឡើយ។

យ៉ូហាន ៨:២៦ “ខ្ញុំក៏ប្រាប់ដល់មនុស្សលោកដែរ”។ ប៉ុន្តែមានតែពួកយូដាប៉ុណ្ណោះ ដែលព្រះគាត់និយាយ។ ដូច្នេះពាក្យថា “លោកិយ (មនុស្សលោក)” មិនអាចសំដៅលើមនុស្សទាំងអស់បានឡើយ។

យ៉ូហាន ១២:១៩ “លោកិយទាំងស្រុងទៅតាមអ្នកនោះហើយ”។ ត្រង់នេះសំដៅតែពួកយូដាភាគច្រើនដែលបានដើរតាមទ្រង់ប៉ុណ្ណោះ។ វាមិនសំដៅលើមនុស្សទាំងអស់ឡើយ។

១យ៉ូហាន ៥:១៩ “លោកិយទាំងមូល”។ ប៉ុន្តែមានអ្នកជឿពិតប្រាកដជាច្រើននៅក្នុងលោកិយនេះ ដែលពួកគេមិនស្ថិតក្នុងអំណាចរបស់មេកំណាច។ ដូច្នេះពាក្យថា “លោកិយ” មិនអាចសំដៅលើមនុស្សទាំងអស់បានឡើយ។

ដូច្នេះពាក្យថា “លោកិយ” ជាទូទៅសំដៅលើមនុស្សមួយចំនួនដែលនៅក្នុងលោកិយនេះ។ នៅក្នុងកន្លែងទាំងអស់នោះ គេប្រើវាឲ្យទាក់ទងនឹងសេចក្តីសង្គ្រោះត្រង់នេះខ្ញុំយល់ឃើញថា គ្មានហេតុផលណាមួយដែលពាក្យនេះគួរសំដៅលើអ្វីផ្សេងទៀតនោះឡើយ ។

បន្ទាប់ពីការពិនិត្យសង្កេតជាទូទៅទាំងអស់នេះហើយ ចូរយើងមកមើលបទគម្ពីរខ្លះដែលប្រើពាក្យថា “លោកិយ” ដូចជា យ៉ូហាន ១:២៩; ៣:១៦; ៤:៤២; ៦:៥១; ២ កូរិនថូស ៥:១៩ ហើយ ១ យ៉ូហាន ២:២។ ក្នុងការប្រើប្រាស់ខគម្ពីរទាំងអស់នេះ អ្នកខ្លះបានវែកញែកថា៖

១. លោកិយមានមនុស្សគ្រប់ទាំងអស់គ្រប់រូប ។

២. គេថាព្រះគ្រីស្ទត្រូវសុគតសម្រាប់លោកិយ។

៣. ដូច្នេះ ព្រះគ្រីស្ទបានសុគតសម្រាប់មនុស្សទាំងអស់គ្រប់រូប។

ការលើកហេតុផលនេះមិនត្រឹមត្រូវទេ ពីព្រោះពាក្យថា “លោកិយ” កំពុងតែត្រូវបានប្រើនៅក្នុងគំនិតពីរផ្សេងគ្នា។ នៅក្នុងគំនិតទីមួយ “លោកិយ” សំដៅលើភពផែនដី។ នៅក្នុងគំនិតទីពីរ ពាក្យនេះសំដៅលើមនុស្សដែលនៅក្នុងលោកិយនេះ។ មិនមានអត្ថន័យដូចគ្នាណាវាងគំនិតទាំងពីរនេះឡើយ។ ដូច្នេះ ការសន្និដ្ឋាននោះជាការមិនពិតទេ (លុះត្រាតែចង់បង្ហាញថា ព្រះគ្រីស្ទបានសុគតសម្រាប់ភពផែនដី)។

អ្នកខ្លះបានព្យាយាមសរសេរការវែកញែកនេះជាថ្មីម្តងទៀត យ៉ាងដូច្នេះថា៖

១. កន្លែងខ្លះនៅក្នុងបទគម្ពីរ ពាក្យថា “លោកិយ” សំដៅលើមនុស្សទាំងអស់គ្រប់រូប។

២. គេថាព្រះគ្រីស្ទត្រូវសុគតសម្រាប់លោកិយ។

៣. ដូច្នេះ ព្រះគ្រីស្ទបានសុគតសម្រាប់មនុស្សទាំងអស់គ្រប់រូប។

ការវែកញែកនេះក៏មានកំហុសដែរ ពីព្រោះយើងមិនអាចទាញជាសេចក្តីសន្និដ្ឋានសកលទូទៅមួយបានឡើយ នៅពេលដែលឃ្លាទីមួយគ្រាន់តែសំដៅថា "កន្លែងខ្លះ" នោះ។ លើសពីនោះទៅទៀត ខ្ញុំត្រូវតែនិយាយដដែលៗនៅក្នុងកន្លែងជាច្រើនថា ការសុគតរបស់ព្រះគ្រីស្ទមានការទាក់ទងទៅនឹង "ចៀមរបស់ទ្រង់" ឬ "ពួកជំនុំរបស់ទ្រង់" តែប៉ុណ្ណោះ។

ដូច្នេះ គេច្បាស់ជាសរសេរការវែកញែកនេះជាថ្មីម្តងទៀតថា៖

១. កន្លែងខ្លះនៅក្នុងបទគម្ពីរ ពាក្យថា "លោកិយ" សំដៅលើមនុស្សទាំងអស់គ្រប់រូប។

២. កន្លែងខ្លះនៅក្នុងបទគម្ពីរបានចែងថា ព្រះគ្រីស្ទត្រូវសុគតសម្រាប់លោកិយទាំងមូល។

៣. ដូច្នេះ ព្រះគ្រីស្ទបានសុគតសម្រាប់មនុស្សទាំងអស់គ្រប់រូប។

យើងទាំងអស់គ្នាអាចឃើញយ៉ាងច្បាស់ថា ការវែកញែកទាំងនេះ ពិតជាគួរឲ្យអស់សំណើចមែន! វាត្រូវតែបង្ហាញថា "កន្លែងខ្លះ" នៃឃ្លាទីមួយដូចគ្នាទៅនឹង "កន្លែងខ្លះ" នៃឃ្លាទីពីរដែរ។ ដោយវាមិនអាចទៅរួចបាន ការវែកញែកនេះមិនបានបង្ហាញភស្តុតាងអ្វីទាល់តែសោះ។ ហើយនៅក្នុងករណីណាក៏ដោយ យើងមិនអាចទាញយកការសន្និដ្ឋានសកលមួយ ពីការលើកឡើងដែលមានកំណត់ទីមួយបានឡើយ ដូចជាយើងបានឃើញខាងដើមអញ្ចឹង។

ដូច្នេះនៅក្នុងសេចក្តីផ្តើមនេះ ខ្ញុំគិតថា ខ្ញុំបានបំផុសពីកំហុសនានានៃការវែកញែកដែលមានមូលដ្ឋានលើការប្រើប្រាស់ពាក្យថា "លោកិយ"ហើយ។ ខ្ញុំហ៊ាននិយាយថា ការវែកញែកដែលខ្សោយនេះគឺបណ្តាលមកពីគេធ្វើឡើងដោយមិនមានការពិនិត្យពិចារណាយ៉ាងម៉ត់ចត់! ប៉ុន្តែសូមទុកការវែកញែកនេះមួយអន្លើសិន

ហើយយើងទៅមើលបទគម្ពីរដោយផ្ទាល់វិញម្ដង។

## ជំពូក ៣

*ការសិក្សាលម្អិតមួយនៃបទគម្ពីរយ៉ូហាន ៣:១៦*

ជាញឹកញាប់គេយកខនេះដើម្បីបង្រៀនថា៖

“ស្រឡាញ់” = ១. ព្រះមានអារម្មណ៍ខាងឯធម្មជាតិនេះសម្រាប់ការល្អនៃ

“មនុស្សលោក” = ២. មនុស្សជាតិទាំងមូលគ្រប់វ័យ គ្រប់សម័យកាលដែល

“បានប្រទាន” = ៣. ទ្រង់បានប្រទានព្រះរាជបុត្រាទ្រង់ឲ្យមកសុគត មិនសម្រាប់មនុស្សទាំងអស់ទេ ប៉ុន្តែ

“អស់អ្នកណា” = ៤. អស់អ្នកណាដែលមាននិស្ស័យចង់ជឿ

“មាន” = ៥. អាចទទួលជីវិតអស់កល្បជានិច្ចវិញ។

ផ្ទុយពីការនេះ យើងខ្ញុំយល់ឃើញថា ខនេះបង្រៀនដូចខាងក្រោមវិញ៖

“ស្រឡាញ់” = ១. ព្រះមានសេចក្ដីស្រឡាញ់ពិសេសអស្ចារ្យមួយ

ដែលទ្រង់បានសព្វព្រះហឫទ័យឲ្យ

"មនុស្សលោក"= ២. មនុស្សគ្រប់ជាតិសាសន៍ គឺជារាស្ត្រទាំងអស់របស់ទ្រង់បានទទួលសេចក្ដីសង្គ្រោះ

"បានប្រទាន" = ៣. ដោយតាំងព្រះរាជបុត្រារបស់ទ្រង់ ជាព្រះអង្គសង្គ្រោះ

"អស់អ្នកណា" = ៤. អស់អ្នកណាដែលជឿ ហើយមានតែពួកគេប៉ុណ្ណោះដែល

"មាន" = ៥. មានគ្រប់ទាំងសិរីរុងរឿង ដែលទ្រង់មានបំណងព្រះហឫទ័យសម្រាប់ ពួកគេ។

មានការបីយ៉ាងដែលត្រូវសិក្សាដោយប្រុងប្រយ័ត្ននៅទីនេះ។ ទីមួយសេចក្ដីស្រឡាញ់របស់ព្រះ។ ទីពីរ កម្មបទនៃសេចក្ដីស្រឡាញ់របស់ព្រះដែលត្រង់នេះគេហៅថា "លោកិយ" (មនុស្សលោក) ។ ទីបី គោលបំណងនៃសេចក្ដីស្រឡាញ់របស់ព្រះ ដែលអ្នកជឿ "មិនត្រូវវិនាស"។

១. វាមានសារៈសំខាន់ណាស់ថា គ្មានអ្វីដែលគេអាចនិយាយថា ព្រះមិនគ្រប់លក្ខណ៍បានទេ។ កិច្ចការរបស់ទ្រង់សុទ្ធតែគ្រប់លក្ខណ៍។ ប៉ុន្តែប្រសិនគេវែកញែកថាទ្រង់មានគោលបំណងមួយសម្រាប់សេចក្ដីសង្គ្រោះដល់មនុស្សទាំងអស់ តែបន្ទាប់មកទ្រង់ក៏បានបរាជ័យក្នុងការសង្គ្រោះមនុស្សទាំងអស់ នោះមានន័យថា គោលបំណងរបស់ទ្រង់ខ្សោយ ហើយសុភមង្គលរបស់ទ្រង់ក៏មិនពេញលេញដែរ។

គ្មានបទគម្ពីរណាមួយដែលបញ្ជាក់ថា ព្រះបរាជ័យចំពោះសេចក្ដីល្អនៃមនុស្សទាំងអស់ទេ។ ផ្ទុយទៅវិញ បទគម្ពីរបានបង្ហាញយ៉ាងច្បាស់ថា ព្រះមានសេចក្ដីមេត្តាករុណាពេញទី លើអស់អ្នកណាដែលទ្រង់សព្វព្រះទ័យផ្ដល់ឲ្យ។ សេចក្ដីស្រឡាញ់របស់ទ្រង់ គឺជាកិច្ចការដ៏មានសេរីភាពពេញទីមួយនៃបំណងព្រះហឫទ័យ

របស់ទ្រង់ គឺមិនមែនជាអារម្មណ៍ដែលទ្រង់មាន ដោយសារភាពកំសត់របស់យើងនោះទេ។ (ប្រសិនបើ ភាពកំសត់ធ្វើឲ្យទាក់ទាញបំណងព្រះហឫទ័យរបស់ទ្រង់ដើម្បីឲ្យទ្រង់ជួយ នោះទ្រង់គួរតែមានសេចក្តីមេត្តាករុណាចំពោះអារក្ស និងអ្នកដែលត្រូវវិនាសដែរ!)

សេចក្តីស្រឡាញ់ដែលគេបានពិពណ៌នានៅទីនេះ គឺជាកិច្ចការដ៏ពិសេស និងដ៏កំពូលមួយនៃបំណងព្រះហឫទ័យរបស់ព្រះ ចំពោះអ្នកជឿ។ ពាក្យថា "ដល់ម្ល៉េះ" និង "ដើម្បី" សង្កត់ធ្ងន់ទៅលើលក្ខណៈពិសេសនៃសេចក្តីស្រឡាញ់នេះ ហើយផ្តោតទៅលើគោលបំណងដ៏ជាក់ច្បាស់នៃសេចក្តីស្រឡាញ់នេះ ដើម្បីសង្គ្រោះដល់អ្នកជឿពីសេចក្តីវិនាស។ មានន័យថា សេចក្តីស្រឡាញ់នេះ មិនអាចជាសេចក្តីស្រឡាញ់ធម្មតាមួយចំពោះមនុស្សទាំងអស់បានទេ ដ្បិតអ្នកខ្លះក្នុងចំណោមនោះនឹងវិនាសជាមិនខាន។

បទគម្ពីរផ្សេងទៀតក៏បានឯកភាពថា សេចក្តីស្រឡាញ់នៃព្រះ គឺជាកិច្ចការដ៏កំពូលមួយ ហើយជាពិសេសសម្រាប់អ្នកជឿ ឧទាហរណ៍ដូចជា គម្ពីររ៉ូម ៥:៨ ឬ ១យ៉ូហាន ៤:៩-១០។ គេនឹងមិនអាចនិយាយតាមអារម្មណ៍អំពីសេចក្តីល្អសម្រាប់មនុស្សទាំងអស់ ដូចនៅក្នុងរបៀបទាំងប៉ុន្មានខាងលើនេះបានទេ។

ជាការជាក់ច្បាស់ណាស់ថា ព្រះសព្វព្រះហឫទ័យនឹងសេចក្តីល្អសម្រាប់ពួកអ្នកដែលទ្រង់ស្រឡាញ់។ អញ្ចឹង យើងត្រូវតែព្រមថា ទ្រង់ស្រឡាញ់តែអស់អ្នកណាដែលបានទទួលសេចក្តីល្អនោះប៉ុណ្ណោះ។ សេចក្តីស្រឡាញ់ដដែលនេះ បានធ្វើឲ្យទ្រង់ប្រទានព្រះគ្រីស្ទមក ហើយធ្វើឲ្យទ្រង់ប្រទានគ្រប់ទាំងសេចក្តីត្រូវការផ្សេងៗទៀតដែរ។ "ឯព្រះអង្គ ដែលមិនបានសំចៃទុកនូវព្រះរាជបុត្រាទ្រង់បង្កើតគឺបានបញ្ជូនទ្រង់ទៅជំនួសយើងរាល់គ្នា នោះតើមានទំនងអ្វី ឲ្យទ្រង់មិនប្រទានគ្រប់ទាំងអស់មកយើង ជាមួយព្រះរាជបុត្រាទ្រង់នោះផង" (រ៉ូម ៨:៣២)។ ដូច្នេះ សេចក្តីស្រឡាញ់ពិសេសរបស់ព្រះនេះ អាចបានតែដល់អ្នកណា ដែលព្រះបានប្រទាន

ព្រះគុណ និងសិរីរុងរឿងមកប៉ុណ្ណោះ។

ឥឡូវនេះបងប្អូនអើយ សូមបងប្អូនវិនិច្ឆ័យ ថាតើសេចក្ដីស្រឡាញ់របស់ព្រះដែលទ្រង់បានប្រទានមករួមទាំងព្រះរាជបុត្រារបស់ទ្រង់ផងនោះ អាចជាបំណងព្រះហឫទ័យល្អទូទៅនៅក្នុងទ្រង់ ចំពោះមនុស្សទាំងអស់បានដែរឬទេ? តើនោះមិនមែនជាសេចក្ដីស្រឡាញ់ពិសេស ចំពោះតែអ្នកជឿដែលព្រះបានជ្រើសរើសទេឬអី?

២. យើងត្រូវតែពិនិត្យមើល ពីអ្វីដែលជាកម្មបទនៃសេចក្ដីស្រឡាញ់របស់ព្រះ នៅទីនេះគេហៅកម្មបទនោះថា “លោកិយ”។ អ្នកខ្លះនិយាយថា ពាក្យនេះសំដៅថា មនុស្សទាំងអស់គ្រប់ៗរូប។ ខ្ញុំអាចឃើញថា វាមិនមានន័យយ៉ាងដូច្នេះទេ។ យើងបានបង្ហាញពីអត្ថន័យផ្សេងៗនៃពាក្យថា “លោកិយ” ដែលគេបានប្រើនៅក្នុងបទគម្ពីររួចមកហើយ។ ហើយនៅក្នុងព្រះគម្ពីរ យ៉ូហាន ៣:១៦ ជាសេចក្ដីស្រឡាញ់ដែលគេលើកយកមកនិយាយនៅខាងដើម ហើយគោលបំណងលើកយកមកនិយាយនៅខាងចុង មិនអាចឯកភាពជាមួយនឹងអត្ថន័យដែលសំដៅលើ “មនុស្សទាំងអស់គ្រប់ៗរូប” ដែលអ្នកខ្លះខំធ្វើឲ្យវាមានអត្ថន័យថា “លោកិយ” នៅក្នុងពាក់កណ្ដាលខបានទេ!

ចំណែកខាងយើងវិញ យើងយល់ថា ពាក្យនេះគឺសំដៅលើពួកជ្រើសរើសរបស់ព្រះ ដែលបានខ្ចាត់ខ្ចាយនៅក្នុងលោកិយក្នុងចំណោមជាតិសាសន៍ទាំងអស់។ អត្ថប្រយោជន៍ពិសេសពីព្រះនោះ មិនមែនសម្រាប់តែពួកយូដាប៉ុណ្ណោះទេ។ កន្លែងនេះចង់និយាយថា “ព្រះជាម្ចាស់ស្រឡាញ់ពួកជ្រើសរើសរបស់ទ្រង់នៅក្នុងលោកិយនេះ ដល់ម្ល៉េះបានជាទ្រង់បានប្រទានព្រះរាជបុត្រារបស់ទ្រង់មកជាមួយបំណងផែនការនេះ ដើម្បីឲ្យអ្នកជឿបានទទួលការសង្គ្រោះដោយសារទ្រង់”។ មានហេតុផលជាច្រើនដែលគាំទ្រដល់គំនិតនេះ។ និស្ស័យនៃសេចក្ដីស្រឡាញ់របស់ព្រះដូចដែលយើងបានពិនិត្យមើលហើយនោះ មិនអាចនឹងសម្រាប់មនុស្សទាំងអស់

គ្រប់រូបបានទេ។ ពាក្យថា “លោកិយ” ដែលនៅក្នុងខនេះ ត្រូវតែជាមនុស្សលោក ដែលទទួលបានជីវិតអស់កល្បជានិច្ច។ ការនេះត្រូវបានបញ្ជាក់ដោយខគម្ពីរ ក្រោយៗទៀតដូចជា យ៉ូហាន ៣:១៧ ដែលជាកន្លែងទីបីនៃពាក្យថា “លោកិយ”។ គេនិយាយថា គោលបំណងរបស់ព្រះក្នុងការដែលចាត់ព្រះរាជបុត្រាមកគឺ “ដើម្បីឲ្យលោកិយបានសង្គ្រោះ”។ ប្រសិនបើពាក្យ “លោកិយ ឬមនុស្សលោក” នៅទីនេះ ត្រូវគេយល់ថា ជាអ្នកផ្សេងទៀតក្រៅពីពួកអ្នកជឿដែលព្រះបានជ្រើសរើស នោះមានន័យថា ទ្រង់បានទទួលបរាជ័យនៅក្នុងគោលបំណងរបស់ទ្រង់ហើយ។ យើងមិនហ៊ាននិយាយយ៉ាងដូច្នេះទេ។ តាមពិតទៅ វាមិនចំឡែកទេ ដែលគេហៅពួកអ្នកជឿរបស់ព្រះថា “លោកិយ ឬមនុស្សលោក” “គ្រប់ទាំងសាច់ឈាម” “គ្រប់ទាំងជាតិសាសន៍” និង “គ្រប់គ្រួសារដែលនៅលើផែនដី” នោះ។ ឧទាហរណ៍៖ នៅក្នុងគម្ពីរ យ៉ូហាន ៤:៤២ ចែងថា ព្រះគ្រីស្ទជាព្រះដ៏ជួយសង្គ្រោះមនុស្សលោក។ អ្នកសង្គ្រោះម្នាក់របស់មនុស្សដែលមិនបានសង្គ្រោះ អញ្ចឹងអ្នកសង្គ្រោះនោះនឹងមានតែឈ្មោះប៉ុណ្ណោះ។ ដូច្នេះ អស់អ្នកដែលគេហៅថា “មនុស្សលោក” នៅទីនេះ គឺសំដៅតែអ្នកដែលបានទទួលសេចក្ដីសង្គ្រោះប៉ុណ្ណោះ។

មានមូលហេតុជាច្រើនដែលគេហៅអ្នកជឿថា “លោកិយ ឬមនុស្សលោក” ពីព្រោះដើម្បីបែងចែកឲ្យដាច់ពីគ្នារវាងមនុស្ស និងពួកទេវតា ហើយដើម្បីបដិសេធពួកយូដាដ៏មានអំនួត ដែលគេគិតថា មានតែខ្លួនគេប៉ុណ្ណោះទើបជារាស្ត្ររបស់ព្រះ ហើយនិងដើម្បីបង្រៀនពីភាពផ្សេងគ្នារវាងសញ្ញាចាស់ដែលបានធ្វើឡើងជាមួយសាសន៍តែមួយ និងសញ្ញាថ្មី នៅពេលដែលគ្រប់ទីកន្លែងផ្សេងទៀតក្នុងពិភពលោកបានស្ដាប់បង្គាប់ដល់ព្រះគ្រីស្ទ។ ម្យ៉ាងវិញទៀតគឺដើម្បីបង្ហាញពីលក្ខខ័ណ្ឌធម្មជាតិរបស់អ្នកជឿ ក្នុងនាមជាមនុស្សលោកលើផែនដីនេះ។

ប្រសិនបើគេនៅតែរែកញែកថាពាក្យ “លោកិយ” នៅទីនេះ សំដៅថា មនុស្សគ្រប់រូបទាំងអស់ជាកម្មបទនៃសេចក្ដីស្រឡាញ់របស់ព្រះ ចុះហេតុអ្វីបានជាព្រះមិន

បានបើកសម្តែងពីព្រះយេស៊ូវ ដល់មនុស្សទាំងអស់ដែលទ្រង់ស្រឡាញ់យ៉ាងខ្លាំងនោះទៅវិញ? ជាការចំឡែកមែនទែន ដែលគេនិយាយថាព្រះគួរប្រទានព្រះរាជបុត្រារបស់ទ្រង់សម្រាប់ពួកគេ តែបែរជាមិនបានប្រាប់គេពីសេចក្ដីស្រឡាញ់របស់ទ្រង់ទៅវិញនោះ! មានមនុស្សរាប់លាននាក់មិនដែលបានឮពីដំណឹងល្អទាល់តែសោះ! តើគេថាព្រះស្រឡាញ់មនុស្សទាំងអស់ដោយរបៀបណា ប្រសិនបើមនុស្សទាំងអស់មិនបានស្គាល់ពីការទំនុកបម្រុងរបស់ព្រះចំពោះសេចក្ដីស្រឡាញ់នេះផងនោះ?

ជាទីបញ្ចប់ពាក្យ “លោកិយ” មិនអាចមានន័យសំដៅលើមនុស្សទាំងអស់គ្រប់ៗរូបបានទេ លុះត្រាតែលោកអ្នកគិតថា៖

សេចក្ដីស្រឡាញ់របស់ព្រះចំពោះមនុស្សជាច្រើន គឺឥតបានការ ព្រោះពួកគេនៅតែត្រូវវិនាសដដែល។

ព្រះគ្រីស្ទត្រូវបានប្រទានមក សម្រាប់មនុស្សរាប់លាននាក់ដែលមិនដែលស្គាល់ពីទ្រង់សោះ។

ព្រះគ្រីស្ទត្រូវបានប្រទានមក សម្រាប់មនុស្សរាប់លាននាក់ដែលមិនអាចជឿដល់ទ្រង់សោះ។

ព្រះផ្លាស់ប្ដូរសេចក្ដីស្រឡាញ់របស់ទ្រង់ ដើម្បីបោះបង់អស់អ្នកដែលវិនាស (ឬក៏មានន័យម្យ៉ាងទៀតថា ទ្រង់នៅតែបន្តស្រឡាញ់ពួកគេនៅស្ថាននរកទៀត)។

ព្រះខកខានមិនបានប្រទានអ្វីៗទាំងអស់ សម្រាប់ពួកអ្នកដែលទ្រង់បានប្រទានមកឯព្រះគ្រីស្ទ។

ព្រះមិនបានស្គាល់ពួកអ្នកដែលនឹងជឿ ហើយនឹងបានទទួលសេចក្ដីសង្គ្រោះជាមុនទេ។

គំនិតដែលមិនត្រឹមត្រូវខាងលើនេះ យើងមិនត្រូវយកចិត្តទុកដាក់ទេ។ “លោកិយ” សំដៅលើតែពួកអ្នកជ្រើសរើសដែលខ្ចាត់ខ្ចាយនៅលើលោកិយនេះប៉ុណ្ណោះ។

៣. របៀបពួកជ្រើសរើសរបស់ព្រះ មកទទួលជីវិតនៅក្នុងព្រះរាជបុត្រារបស់ទ្រង់ គឺត្រូវនិយាយថា ដោយសារការជឿ។ ជាការពិតណាស់ “គ្រប់អ្នកជឿទាំងអស់នឹងមិនវិនាសឡើយ”។

ប្រសិនបើ គេវែកញែកថា ព្រះគ្រីស្ទបានសុគតសម្រាប់មនុស្សទាំងអស់ ក្នុងខណៈដែលយើងដឹងថាមានតែអ្នកជឿប៉ុណ្ណោះនឹងបានសង្គ្រោះ អញ្ចឹងតើអ្វីខ្លះដែលធ្វើឲ្យមានភាពផ្សេងគ្នារវាងអ្នកជឿ និងអ្នកមិនជឿ? ពួកគេមិនបានធ្វើការនោះឲ្យមានភាពផ្សេងគ្នាដោយខ្លួនឯងនោះទេ (សូមមើល ១កូរិនថូស ៤:៧)។ មានន័យថា ព្រះបានធ្វើឲ្យពួកគេមានភាពផ្សេងគ្នាវិញ។ ប្រសិនបើព្រះបានធ្វើឲ្យពួកគេមានភាពផ្សេងគ្នា តើទ្រង់អាចប្រទានព្រះគ្រីស្ទមកសម្រាប់មនុស្សទាំងអស់ដោយរបៀបណា?

ខគម្ពីរនេះប្រកាសពីបំណងផែនការរបស់ព្រះថា អ្នកជឿនឹងបានសង្គ្រោះ។ ដូច្នេះមានន័យថា ព្រះមិនបានប្រទានព្រះរាជបុត្រារបស់ទ្រង់មកសម្រាប់អ្នកមិនជឿទេ។ តើទ្រង់អាចប្រទានព្រះរាជបុត្រារបស់ទ្រង់មកសម្រាប់អស់អ្នកដែលទ្រង់មិនបានប្រទានព្រះគុណាឲ្យជឿដោយរបៀបណា?

ឥឡូវនេះ សូមអ្នកអានពិចារណាការទាំងអស់នេះ ហើយជាពិសេសត្រង់ចំណុចទីមួយ គឺសេចក្តីស្រឡាញ់នៃព្រះ។ ហើយសូមសួរដោយម៉ត់ចត់ថា តើវាអាចជាសេចក្តីស្រឡាញ់ទូទៅមួយ ដល់មនុស្សទាំងអស់បានឬទេ ខណៈដែលមនុស្សជាច្រើនដែលទ្រង់ស្រឡាញ់ជាខ្លាំងត្រូវវិនាសនោះ? ឬក៏ តើគេមិនគួរយល់ថាសេចក្តីស្រឡាញ់នេះ ជាសេចក្តីស្រឡាញ់ពិសេសតែមួយរបស់ព្រះវរបិតាចំពោះកូនៗរបស់ទ្រង់ ដើម្បីធ្វើឲ្យអនាគតរបស់ពួកគេមានសុវត្ថិភាពទេឬអី? នោះលោកអ្នក

នឹងមានចម្លើយមួយ ថាតើព្រះគម្ពីរបង្រៀនថា ព្រះគ្រីស្ទបានសុគតទុកជាថ្លៃលោះទូទៅមួយ ឬក៏ជាការប្រោសលោះពិសេសមួយយ៉ាងស័ក្តិសិទ្ធិសម្រាប់អ្នកជឿគ្រប់រូប ? ហើយចូរចងចាំថា ខគម្ពីរយ៉ូហាន ៣:១៦ ត្រូវបានគេប្រើញឹកញាប់ណាស់ដើម្បីគាំទ្រគំនិតដែលថា ព្រះគ្រីស្ទបានសុគតសម្រាប់មនុស្សទាំងអស់។ ដូចជាខ្ញុំបានបង្ហាញរួចមកហើយថា វាជាគំនិតមួយដែលខុសស្រឡះ!

## ជំពូក ៤

*ការសិក្សាលម្អិតមួយអំពីគម្ពីរ ១យ៉ូហាន ២:១-២*

នេះគឺជាខមួយទៀតដែលត្រូវបានប្រើជាញឹកញាប់ ដោយពួកអ្នកដែលរ៉ែកញែកថាការសុគតរបស់ព្រះគ្រីស្ទគឺសម្រាប់មនុស្សទាំងអស់គ្រប់ៗរូប។ គេនិយាយថា ឃ្លា "លោកិយទាំងមូល" ត្រូវតែមានន័យថា "មនុស្សទាំងអស់ដែលនៅក្នុងលោកិយនេះ" ហើយឃ្លាដែលបញ្ជាក់ពីនោះគឺ "មិនមែនសម្រាប់តែយើងប៉ុណ្ណោះទេ" ក្រៅពីពួកអ្នកជឿ មនុស្សទាំងអស់ក៏ជាពួកអ្នកដែលព្រះគ្រីស្ទបានសុគតជំនួសដែរ។

ខ្ញុំអាចឆ្លើយការនេះដោយខ្លីៗបានដោយនិយាយថា នៅក្នុងកន្លែងផ្សេងទៀតពាក្យថា "លោកិយ" មានន័យសំដៅលើ "មនុស្សដែលរស់នៅក្នុងលោកិយនេះ"។ ដូច្នេះ ឃ្លា "លោកិយទាំងមូល" មិនសំដៅលើមនុស្សដែលលើសពី "មនុស្សដែលរស់នៅក្នុងលោកិយទាំងមូល" នេះទេ គឺជាពួកអ្នកដែលទទួលបានការប្រោសលោះដូចជាមានចែងនៅក្នុង គម្ពីរវិវរណៈ ៥:៩។ ប៉ុន្តែដោយព្រោះមាន

ការប្រើប្រាស់ខនេះច្រើនក្នុងគម្ពីរ១យ៉ូហាន ខ្ញុំសូមលើកយកការសិក្សាលម្អិតមួយផ្សេងទៀត ដោយប្រើសំណួរបួន។

១. តើសាវ័ក យ៉ូហានកំពុងសរសេរផ្ញើទៅនរណា? ជាការពិតណាស់ បទគម្ពីរទាំងនោះ គឺសម្រាប់ពួកជំនុំទាំងអស់ ប៉ុន្តែផ្នែកជាច្រើននៃបទគម្ពីរនោះ ត្រូវបានសរសេរទៅកាន់មនុស្សពិសេស។ គេត្រូវតែយល់បទគម្ពីរទាំងនេះ នៅក្នុងពន្លឺនៃសេចក្តីពិតនោះ។ ដូច្នេះ យើងសម្គាល់ឃើញថា៖

ក. លោក យ៉ូហាន ជាសាវ័កពិសេសម្នាក់ចំពោះពួកយូដា- កាឡាទី ២:៩។

ខ. គាត់បានសរសេរទៅកាន់ពួកអ្នក ដែលបានឮព្រះបន្ទូលរបស់ព្រះ (១យ៉ូហាន ២:៧) ហើយយើងដឹងថា ព្រះបន្ទូលរបស់ព្រះបាន “ទៅកាន់ពួកយូដាមុនគេបង្អស់”។

គ. ភាពខុសគ្នាដែលលោក យ៉ូហាន បានធ្វើឡើងរវាង “យើង” និង “លោកិយ” បានបង្ហាញយ៉ាងច្បាស់ថា គាត់បានសរសេរទៅកាន់ពួកយូដាដែលជាសាសន៍ដូចគាត់។

ឃ. ជាញឹកញាប់ លោកយ៉ូហាន បានទូន្មានឲ្យប្រុងប្រយ័ត្ននឹងគ្រូក្លែងក្លាយ។ ឧទាហរណ៍៖ បទគម្ពីរ ១យ៉ូហាន ២:១៩។ តាមពិតទៅ គាត់បានសរសេរទៅកាន់ពួកយូដាដូចគ្នា ព្រោះគាត់បានសរសេរពីគ្រូទាំងនោះថា ឲ្យ “គេបានចាកចេញពីពួកយើងទៅ”។

ចូរចងចាំថា ពួកជនជាតិយូដាស្អប់សាសន៍ដទៃណាស់ ហើយគេមានគំនិតថា មានតែជនជាតិរបស់ខ្លួនប៉ុណ្ណោះដែលជារាស្ត្ររបស់ព្រះ។ តើអាចមានអ្វីលើសពីការដែលលោកយ៉ូហានគួរនិយាយទៀត ដែលថា ព្រះយេស៊ូវបានសុគត មិនសម្រាប់តែពួកអ្នកជឿជនជាតិយូដាប៉ុណ្ណោះទេ ប៉ុន្តែក៏សម្រាប់អ្នកជឿទាំងអស់ដែលនៅក្នុងលោកិយទាំងមូលដែរ នោះ? យើងមានបទគម្ពីរមួយទៀតដែលបង្ហាញនូវការ

សង្កត់ធ្ងន់ដូចគ្នា នៅក្នុងគម្ពីរយ៉ូហាន ១១:៥២។ លោក យ៉ូហានបង្ហាញពីការព្រួយបារម្ភយ៉ាងច្បាស់ ដើម្បីការពារគ្រីស្ទបរិស័ទជនជាតិយូដា មិនឲ្យធ្លាក់ទៅក្នុងកំហុសចាស់ដែលគេស្មានថា មានតែពួកគេប៉ុណ្ណោះដែលជាគ្រីស្ទបរិស័ទ។ លោក យ៉ូហានបានទទូចថា ក៏មានគ្រីស្ទបរិស័ទដែលជាសាសន៍ដទៃនានាទូទាំងលោកិយនេះដែរ។ នៅទីនេះមិនមានសេចក្តីបង្រៀនថាព្រះគ្រីស្ទបានសុគតសម្រាប់មនុស្សទាំងអស់ទេ។

២. ហេតុអ្វីបានជាលោកយ៉ូហានបានសរសេរមក? គាត់បានសរសេរមកដើម្បីកំសាន្តចិត្តដល់ពួកអ្នកជឿដែលមានទុក្ខលំបាក ដោយអំពើបាបរបស់ពួកគេ ដើម្បីកុំឲ្យពួកគេអស់សង្ឃឹម។ យើងធ្វើការកត់សម្គាល់ឃ្លា "ប្រសិនបើអ្នកណាធ្វើបាប..."ដូចខាងក្រោម៖

ក. មានតែអ្នកជឿប៉ុណ្ណោះដែលនឹងអាចទទួលការកំសាន្តចិត្ត ដែលព្រះគ្រីស្ទជាអ្នកគាំទ្រពួកគេ។

ខ. មានតែអ្នកជឿប៉ុណ្ណោះដែលនឹងអាចទទួលការកំសាន្តចិត្ត រីឯ អ្នកមិនជឿវិញគឺនៅក្រោមសេចក្តីក្រោធរបស់ព្រះ។

គ. លោក យ៉ូហានបានពិពណ៌នាពីពួកគេថា ជា "កូនតូចៗ...បាប របស់ពួកគេបានទទួលការអត់ទោស"។

និយាយឲ្យស្រួលស្តាប់ទៅ គោលបំណងរបស់លោក យ៉ូហានបាញ់ឆ្ពោះទៅកាន់តែពួកអ្នកជឿប៉ុណ្ណោះ។ តើវាអាចជាសេចក្តីកំសាន្តចិត្តដល់ពួកអ្នកជឿដោយរបៀបណា ដែលគេប្រាប់ថាព្រះគ្រីស្ទបានសុគតសម្រាប់មនុស្សទាំងអស់គ្រប់ៗរូប តែមនុស្សជាច្រើនមិនបានទទួលការសង្គ្រោះវិញនោះ? ពាក្យនេះមិនបានផ្តល់នូវសេចក្តីកំសាន្តចិត្តទេ លុះត្រាតែគេយល់ថា ព្រះគ្រីស្ទគឺជាព្រះអង្គសង្គ្រោះរបស់អ្នកជឿទាំងអស់ ដែលនៅគ្រប់ទីកន្លែងក្នុងលោកិយនេះ។

៣. តើពាក្យថា “ដង្វាយធួននឹងបាប” មានន័យយ៉ាងដូចម្ដេច? ជាភាសាក្រិកគេបកប្រែពាក្យ “ដង្វាយធួននឹងបាប” នេះ ទាក់ទងនឹងពាក្យថា “ទីសន្ដោសប្រោស” នៅក្នុងគម្ពីរហេព្រើរ ៩:៥។ ការប្រើប្រាស់នេះ បានផ្ដល់ឲ្យយើងនូវការយល់ដឹងមួយអំពីអត្ថន័យនៃពាក្យនេះ។ “ទីសន្ដោសប្រោស” គឺជាបន្ទះបួនជ្រុងធ្វើពីមាសស្រោបលើហឹបនៃសេចក្ដីសញ្ញា ដែលមានបន្ទះនៃក្រឹត្យវិន័យនៅក្នុងនោះ (និក្ខមនំ ២៥:១៧-២២)។ ក្រឹត្យវិន័យដែលចោទប្រកាន់ថាមនុស្សមានបាប ត្រូវបានគ្របបាំងដោយទីសន្ដោសប្រោស។ នេះគឺជារូបភាព អំពីរបៀបដែលព្រះយេស៊ូវគ្រីស្ទបានគ្របបាំងក្រឹត្យវិន័យរបស់ព្រះ ដោយការសុគតរបស់ទ្រង់ យ៉ាងនោះក្រឹត្យវិន័យមិនអាចចោទប្រកាន់អស់អ្នកដែលជឿទ្រង់បានទេ។ ព្រះយេស៊ូវគឺជាដង្វាយធួននឹងបាប (ទីសន្ដោសប្រោស) របស់ពួកអ្នកជឿដល់ទ្រង់។ អញ្ចឹង តើគេពិតជាអាចនិយាយថា មនុស្សទាំងអស់គ្រប់រូបនៅក្នុងលោកិយនេះរួចផុតពីការផ្ដន្ទាទោស ក្នុងនាមជាមនុស្សមានបាបបានដែរឬទេ? ក្នុងការយល់បែបនេះ តើគេពិតជាអាចវែកញែកថា ព្រះគ្រីស្ទជាដង្វាយឲ្យធួននឹងបាបនៃលោកិយទាំងមូលឬ?

៤. អញ្ចឹង តើអ្វីទៅជាអត្ថន័យនៃពាក្យ “លោកិយទាំងមូល”? ឃ្លានេះបានកើតឡើងជាច្រើនដងនៅក្នុងសម័យសញ្ញាថ្មី ហើយជាញឹកញាប់វាមិនមានន័យថាមនុស្សគ្រប់រូបនោះទេ។ ឧទាហរណ៍៖

លូកា ២:១ ប៉ុន្តែ មានតែមនុស្សដែលនៅក្នុងចក្រភពរ៉ូមប៉ុណ្ណោះ ដែលត្រូវបានគេទារពន្ធ។

រ៉ូម ១:៨ ប៉ុន្តែ ផ្នែកដទៃទៀតនៃលោកិយនេះ គេមិនបានឮពីពួកជំនុំនៅក្នុងទីក្រុងរ៉ូមទេ នៅពេលនោះ។

កូឡុស ១:៦ ប៉ុន្តែផ្នែកដទៃទៀតនៃលោកិយនេះ គេមិនបានទទួលដំណឹងល្អទេនៅពេលនោះ។

វិវរណៈ ៣:១០ លោកិយទាំងមូលគឺត្រូវរងទុក្ខ ប៉ុន្តែនេះមិនសំដៅលើមនុស្ស គ្រប់រូបទេ ដ្បិតមានមនុស្សមួយចំនួនបានរួចផុតពីការរងទុក្ខនោះ។

ពិតមែនហើយ នៅក្នុងកន្លែងទាំងអស់នេះ និងកន្លែងដទៃទៀត លោកិយទាំងមូល មានន័យ មិនលើសពីមនុស្សជាច្រើនទេ។

ដូចគ្នានេះផងដែរ នៅក្នុងបទគម្ពីរមួយចំនួនមានឃ្លាខ្លះថា "គ្រប់ទាំងមនុស្ស" មានន័យមិនលើសពីមនុស្សគ្រប់ប្រភេទទេ។ ឧទាហរណ៍៖ ទំនុកដំកើង ៩៨:៣ និង យ៉ូអែល ២:២៨ (បានសម្រេចនៅក្នុងគម្ពីរកិច្ចការ ២:១៧)។

ជាការពិតណាស់ ជួនកាលលោកិយទាំងមូល សំដៅលើមនុស្សទាំងអស់ ក្រៅពីគ្រីស្ទបរិស័ទអ្នកជឿ ដូចជានៅក្នុង ១យ៉ូហាន ៥:១៩ និង វិវរណៈ ១២:៩។

ឧទាហរណ៍ទាំងនេះបានបង្ហាញយ៉ាងច្បាស់ថា វាមិនមានសារៈសំខាន់ក្នុងការដែលយល់ឃ្លា "លោកិយទាំងមូល" ជារបៀប "រួមបញ្ចូលអ្វីៗគ្រប់យ៉ាង"នោះទេ។ អត្ថន័យនេះ មិនត្រូវការឲ្យវាមានន័យលើសពីបរិបទ ដែលវាគួរមានន័យនោះឡើយ។

ខ្ញុំសន្និដ្ឋានថា អត្ថបទនៃបទគម្ពីរនេះសំដៅលើកិច្ចការរបស់ព្រះគ្រីស្ទសម្រាប់អ្នកជឿទាំងអស់ ទាំងសាសន៍យូដា ទាំងសាសន៍ដទៃគឺដូចតែគ្នាទេ។ តាមពិតទៅបទគម្ពីរចែងថា ទ្រង់គឺជាដង្វាយធួននឹងបាបរបស់ពួកគេ។ គ្មាននរណាម្នាក់បានវែកញែកដោយម៉ឺងម៉ាត់ថា មនុស្សទាំងអស់ដែលនៅគ្រប់ទីកន្លែងបានទទួលសេចក្ដីសង្គ្រោះគ្រប់ៗគ្នាដោយព្រះគ្រីស្ទឡើយ។ ហើយក៏គ្មានជំនួយណាមួយដើម្បីលើកឡើងថា ព្រះគ្រីស្ទគឺជាដង្វាយឲ្យធួននឹងបាប សម្រាប់មនុស្សទាំងអស់គ្រប់ៗរូបដែរ។ លោក យ៉ាកុប មិនបានទទួលការកំសាន្តចិត្ត ដោយគ្រាន់តែឮថា មានពោតគ្រប់គ្រាន់នៅប្រទេសអេហ្ស៊ីបនោះទេ។ តាមពិតទៅ គាត់អាចនឹងឃ្លានស្លាប់ដោយអត់មានពោតយកមកធ្វើជាអាហារ។ ដូច្នេះព្រះគ្រីស្ទគឺជាសេចក្ដីកំសាន្តចិត្តតែមួយ

ចំពោះអស់អ្នកណាដែលបានទទួលសេចក្ដីសង្គ្រោះនៅក្នុងលោកិយទាំងមូល។

## ជំពូក ៥

*ការពន្យល់សង្ខេប នៃបទគម្ពីរចំនួនប្រាំមួយ*

ជួនកាលក្នុងចំណោមបទគម្ពីរផ្សេងៗទៀត ត្រូវបានគេប្រើដើម្បីលើកឡើងថា ព្រះគ្រីស្ទបានសុគតសម្រាប់មនុស្សទាំងអស់ ដូចខាងក្រោមនេះ

១. យ៉ូហាន ១:៩ ខនេះអាចនឹងបកប្រែឲ្យបានប្រសើរបំផុតថា "នោះជាពន្លឺពិតដែលបានមកក្នុងលោកិយនេះ ដើម្បីបំភ្លឺមនុស្សទាំងអស់" (ចូរប្រៀបធៀប យ៉ូហាន ៣:១៩ និង ១២:៤៦)។

មានន័យថា ព្រះគ្រីស្ទបានយាងមកក្នុងលោកិយនេះ ជាការមួយដែលធ្វើឲ្យមនុស្សបានភ្លឺ ។ ដូច្នេះអស់អ្នកណាដែលមានពន្លឺនៃសេចក្ដីពិត ពន្លឺនោះមកតែពីព្រះគ្រីស្ទទេ។ ពិតមែនហើយ នេះជាកន្លែងកម្សោយមួយដែលបង្កើតមូលដ្ឋានលើការវែកញែកនានាសម្រាប់ការប្រោសលោះជាសកល។

២. យ៉ូហាន ១:២៩ ពិតប្រាកដណាស់ មនុស្សទាំងអស់បានដឹងជាទូទៅថាព្រះគ្រីស្ទបានដោះបាប។ ប៉ុន្តែដែលទ្រង់ដោះ ហើយដកបាបចេញពីមនុស្សទាំងអស់គ្រប់គ្នានោះមិនពិតទេ ទោះទាំងនៅក្នុងខគម្ពីរក្ដី និងទោះទាំងនៅក្នុងបទពិសោធន៍របស់យើងក្ដី!

៣. យ៉ូហាន ៣:១៧ ខនេះ គេមិនអាចយល់សំដៅថា ព្រះគ្រីស្ទបានសុគតសម្រាប់មនុស្សទាំងអស់ទេ ដ្បិត៖

ក. មនុស្សទាំងអស់មិនបានទទួលសេចក្ដីសង្គ្រោះគ្រប់ៗគ្នា។

ខ. មនុស្សជាច្រើននឹងទទួលការផ្ដន្ទាទោស នៅពេលព្រះគ្រីស្ទ យាងមក។

គ. ព្រះគ្រីស្ទត្រូវបានតាំងឡើង សម្រាប់ការធ្លាក់ចុះនៃមនុស្សមួយចំនួន (លូកា ២:៣៤)។

ឃ. គោលបំណងនៃការយាងមករបស់ព្រះគ្រីស្ទ មិនអាចខុសគ្នាពីគោលបំណងនានាដ៏នៅអស់កល្បជានិច្ចរបស់ព្រះជាម្ចាស់បានទេ គឺថាមនុស្សមួយចំនួនជាប់ការផ្ដន្ទាទោសដោយព្រោះអំពើបាបរបស់ពួកគេរួចស្រេចទៅហើយ។ តើព្រះបានចាត់ព្រះរាជបុត្រាមកដើម្បីសង្គ្រោះមនុស្សទាំងនោះឬអី?

លោកិយដែលបានទទួលសេចក្ដីសង្គ្រោះ ទៅតាមបំណងព្រះហឫទ័យរបស់ទ្រង់ គឺជាលោកិយនៃរាស្ត្រទាំងអស់របស់ព្រះ។

៤. យ៉ូហាន ៤:៤២ និង ១យ៉ូហាន ៤:១៤ ដែលគេហៅព្រះគ្រីស្ទថា ជាព្រះអង្គសង្គ្រោះនៃលោកិយ យើងយល់ដូចខាងក្រោមថា៖

ក. មិនមានអ្នកសង្គ្រោះឯទៀណាទៀត សម្រាប់មនុស្សណាទៀតនៅក្នុងលោកិយនេះឡើយ ហើយ

ខ. ទ្រង់តែមួយប៉ុណ្ណោះ ដែលសង្គ្រោះមនុស្សដែលទទួលបានការសង្គ្រោះទាំងអស់ នៅគ្រប់ទីកន្លែងក្នុងលោកិយនេះ។

តាមពិតទៅ គេមិនអាចហៅទ្រង់ថា ព្រះអង្គសង្គ្រោះនៃលោកិយបានឡើយ ព្រោះទ្រង់មិនបានសង្គ្រោះមនុស្សទាំងអស់។

៥. យ៉ូហាន ៦:៥១ ពាក្យ “លោកិយ” នៅខនេះបានបង្ហាញយ៉ាងច្បាស់ដូចពន្លឺថ្ងៃអញ្ចឹង ថាវាមិនបានសំដៅលើមនុស្សទាំងអស់ទេ! ខនេះចែងថា ព្រះគ្រីស្ទបាន

ប្រទានព្រះជន្មរបស់ទ្រង់ ដើម្បីឲ្យអ្នកឯទៀតមានជីវិត។ តើយើងពិតជាអាចស្មានថា មនុស្សទាំងអស់សុទ្ធតែមានជីវិតរបស់ទ្រង់ឬ? តើអ្នកដែលត្រូវទទួលទណ្ឌកម្មធ្លាក់ទៅក្នុងស្ថាននរកទាំងនោះ មានព្រះជន្មរបស់ទ្រង់ឬទេ? យើងអាចនិយាយថា "បាទ" បានចំពោះសំណួរទាំងពីរនោះ ប្រសិនបើពាក្យ "លោកិយ" សំដៅលើមនុស្សគ្រប់រូបទាំងអស់។

៦. ២ កូរិនថូស ៥:១៩ នៅត្រង់នេះទៀត យើងត្រូវតែទាញអត្ថន័យនៃពាក្យ "លោកិយ" ពីបរិបទរបស់វា។ អស់អ្នកដែលគេហៅថា "លោកិយ" នៅក្នុងខ១៩ គឺសំដៅលើ "យើង" នៅក្នុងខ១៨ ហើយ "យើង" នៅក្នុងខ២១។ ការអ្វីៗដែលគេនិយាយអំពី នៅក្នុងកន្លែងទាំងអស់នេះ គឺជាពួកអ្នកជឿប៉ុណ្ណោះ។ "លោកិយ" នៅទីនេះ គឺសំដៅលើតែអស់អ្នកណាដែលអំពើរំលងរបស់គេបានអត់ទោសឲ្យប៉ុណ្ណោះ។

ប្រសិនបើ "លោកិយ" នៅទីនេះគេទាញឲ្យមានន័យថា មនុស្សគ្រប់រូបនៅក្នុងលោកិយនេះ ចុះហេតុអ្វីបានជាមនុស្សទាំងអស់មិនបានជានាជាមួយនឹងព្រះ? គេមិនបាននិយាយថា ព្រះនឹងផ្សះផ្សាមនុស្សទាំងអស់ក្នុងល័ក្ខខ័ណ្ឌជាក់លាក់នានាទេ។ តែតាមពិតទៅ ទ្រង់បានធ្វើយ៉ាងដូច្នោះមែន!

នេះគឺជាការការពារ និងជាចម្លើយរបស់យើង ចំពោះអស់អ្នកដែលបំភ្លៃអត្ថបទនៃបទគម្ពីរទាំងនេះ ដើម្បីគាំទ្រគំនិតរបស់ពួកគេដែលថា ព្រះគ្រីស្ទបានសុគតសម្រាប់មនុស្សទាំងអស់។ កំលាំងទាំងមូលនៃការវែកញែករបស់ពួកគេនៅក្នុងកន្លែងទាំងអស់នេះ គឺផ្អែកលើពាក្យតែមួយម៉ាត់ "លោកិយ" ជាពាក្យដែលមានន័យលើសពីមួយទៅវិញ! សូមអ្នកអាន "បង្ហាញភស្តុតាងគ្រប់ទាំងអស់ ហើយតោងឲ្យជាប់នូវអ្វីដែលល្អ"។

# ជំពូក ៦

## *ការពន្យល់អំពីខគម្ពីរនានាដែលប្រើប្រាស់ពាក្យ*

## *“មនុស្សទាំងអស់” ឬ “មនុស្សគ្រប់រូប”*

មានការទូទៅខ្លះ ដែលត្រូវនិយាយជាមុន អំពីការប្រើប្រាស់នៃពាក្យថា “ទាំងអស់”។ វាមានអត្ថន័យពីរនៅក្នុងការប្រើប្រាស់ធម្មតា។ វាអាចមានន័យថា “ចំនួនទាំងអស់” ឬក៏ “មនុស្សគ្រប់ប្រភេទ”។ ខ្ញុំត្រៀមជាស្រេចនឹងនិយាយថា មិនច្រើនជាងមួយឯងនៅក្នុងដប់ឯងនៅក្នុងព្រះគម្ពីរ ដែលវាមានន័យថា “ចំនួនទាំងអស់”! ការប្រើប្រាស់ដ៏សាមញ្ញបំផុតនោះ គឺសំដៅលើ “មនុស្សគ្រប់ប្រភេទ”។ ឧទាហរណ៍៖

លូកា ១១:៤២ ពាក្យជាក់ស្តែងនៅទីនេះគឺ “ជីទាំងអស់”។ ប៉ុន្តែអ្នកបកប្រែបានបកប្រែថា “ជីគ្រប់មុខ” ។ យើងជឿថានោះត្រឹមត្រូវហើយ។

យ៉ូហាន ១២:៣២ ជាការពិតណាស់ មនុស្សជាតិទាំងអស់មិនត្រូវបានទាញមកឯព្រះគ្រីស្ទទេ។ “មនុស្សទាំងអស់” នៅកន្លែងនេះ អាចមានន័យថាមនុស្សគ្រប់ប្រភេទប៉ុណ្ណោះ។

កិច្ចការ ២:១៧ ជាបទពិសោធ បង្ហាញឲ្យឃើញយ៉ាងច្បាស់ថា ព្រះវិញ្ញាណបរិសុទ្ធមិនត្រូវបានចាក់លើមនុស្សជាតិទាំងអស់ទេ។ “មនុស្សទាំងអស់” អាចសំដៅតែមនុស្សគ្រប់ប្រភេទប៉ុណ្ណោះ មិនមែនតែជនជាតិយូដាប៉ុណ្ណោះទេ។

កិច្ចការ ១០:១២ តាមពិតពាក្យជាក់ស្តែងគឺ “សត្វទាំងអស់”។ ប៉ុន្តែអ្នកបកប្រែបានសរសេរយ៉ាងត្រឹមត្រូវថា “សត្វគ្រប់មុខ”។

ពីឧទាហរណ៍ខាងលើនេះ (ហើយមានជាច្រើនទៀតដែលយើងអាចប្រើបាន) នោះយើងអាចទាញជាសេចក្តីសន្និដ្ឋានពាដូចខាងក្រោម៖

ក. ពាក្យ “ទាំងអស់” ជាញឹកញាប់មានន័យថា “មួយចំនួននៃប្រភេទទាំងអស់”។

ខ. ពាក្យ “ទាំងអស់” អាចមានន័យថា “ទាំងអស់នៃប្រភេទជាក់ លាក់ណាមួយ”។ នៅក្នុងព្រះគម្ពីររ៉ូម ៥:១៨ “មនុស្សទាំងអស់” ជាក់ស្តែងសំដៅលើ “មនុស្សទាំងអស់ដែលបានរាប់ជាសុចរិត” ឬ ក៏ “អ្នកជឿទាំងអស់”។

គ. នៅពេលដែលព្រះគម្ពីរសញ្ញាចាស់បានទាយថា “មនុស្សគ្រប់ ជាតិសាសន៍” នឹងបានផ្លាស់ប្រែ តែព្រះគម្ពីរសញ្ញាថ្មីបង្ហាញថា គឺសំដៅលើ រាស្ត្រជ្រើសរើសរបស់ព្រះជាម្ចាស់ពីសាសន៍ទាំងអស់ វិញ។

បន្ទាប់ពីការពិនិត្យសង្កេតទាំងនេះ ខ្ញុំនឹងលើកយកបទគម្ពីរជាក់លាក់ជាច្រើន ដែលត្រូវបានប្រើជាញឹកញាប់ ដោយអស់អ្នកដែលវែកញែកថា ព្រះគ្រីស្ទបានសុគតសម្រាប់មនុស្សជាតិទាំងអស់គ្រប់រូប។

១. ប្រហែលជាមានបទគម្ពីរចម្បងមួយក្នុងចំណោមបទគម្ពីរទាំងនោះគឺ១ធីម៉ូថេ ២:៤-៦។ តាមបទគម្ពីរនេះ គេវែកញែកថា៖

ប្រសិនបើព្រះជាម្ចាស់នឹងផ្តល់ឲ្យមនុស្សទាំងអស់ទទួលបានសេចក្តីសង្គ្រោះ ព្រះគ្រីស្ទច្បាស់ជាសុគតសម្រាប់មនុស្សទាំងអស់ហើយ។ ប៉ុន្តែ នៅទីនេះគេនិយាយថា ព្រះនឹងឲ្យមនុស្សទាំងអស់បានទទួលសេចក្តីសង្គ្រោះ។ ដូច្នេះ ព្រះគ្រីស្ទច្បាស់ជាបានសុគតសម្រាប់មនុស្សទាំងអស់ហើយ។

ចូរយើងដោះស្រាយជាមួយនឹងពាក្យ “ទាំងអស់” ដែលមានន័យលើសពីមួយនេះ។ ប្រសិនបើពាក្យនេះមានន័យថា “មនុស្សគ្រប់ប្រភេទ” នោះយើងទទួលយកថា វាត្រឹមត្រូវហើយ។ ប្រសិនបើពាក្យនេះមានន័យថា “មនុស្សជាតិទាំងអស់” នោះយើងសូមបដិសេធចំពោះការដែលគេថា ព្រះនឹងឲ្យពួកគេបានទទួលសេចក្តីសង្គ្រោះ។

គេអាចគិតពីបំណងព្រះហឫទ័យរបស់ព្រះតាមរបៀបពីរយ៉ាងគឺៈ

ក. បំណងព្រះហឫទ័យរបស់ទ្រង់សម្រាប់យើង គឺជាអ្វីៗដែលទ្រង់សព្វព្រះហឫទ័យឲ្យយើងធ្វើ។

ខ. បំណងព្រះហឫទ័យរបស់ទ្រង់ផ្ទាល់ គឺជាអ្វីៗដែលទ្រង់នឹងធ្វើ។

ឥឡូវនេះ ប្រសិនបើ បំណងព្រះហឫទ័យរបស់ព្រះនៅក្នុងខនេះ ត្រូវបានគេទាញឲ្យមានន័យថា "ជាអ្វីដែលទ្រង់សព្វព្រះហឫទ័យឲ្យមនុស្សធ្វើ" នោះមានន័យថា សាវ័កកំពុងតែនិយាយថា ព្រះសព្វព្រះហឫទ័យឲ្យមនុស្សជាតិទាំងអស់ ប្រើមធ្យោបាយសមស្របដើម្បីចូលមកឯសេចក្តីសង្គ្រោះហើយ។ ប៉ុន្តែមនុស្សជាតិមួយភាគធំបានរស់នៅ ហើយស្លាប់ទៅវិញ ដោយមិនដឹងពីរឿងនេះសោះ ដ្បិតការទំនុកបម្រុងរបស់ព្រះមិនបានផ្តល់មធ្យោបាយនៃព្រះគុណនេះមកពួកគេ! ដូច្នេះ "មនុស្សទាំងអស់" អាចមានន័យយ៉ាងច្រើនត្រឹមតែ "មនុស្សទាំងអស់ដែលបានឮដំណឹងល្អ" ប៉ុណ្ណោះ។ វាមិនអាចមានន័យសំដៅលើមនុស្សជាតិទាំងអស់បានទេ។

ម្យ៉ាងវិញទៀត ប្រសិនបើបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ត្រូវបានគេទាញឲ្យមានន័យថា "ជាអ្វីៗដែលទ្រង់សព្វព្រះហឫទ័យចង់ធ្វើ" នោះយើងអាចនិយាយថា វាត្រូវតែកើតឡើងជាមិនខាន។ ព្រះធ្វើអ្វីៗតាមតែទ្រង់សព្វព្រះហឫទ័យ (ទំនុកដំកើង ១១៥:៣)។ ដូច្នេះប្រសិនបើ "មនុស្សទាំងអស់" សំដៅលើមនុស្សជាតិទាំងអស់ នោះមានន័យថា មនុស្សទាំងអស់បានទទួលសេចក្តីសង្គ្រោះហើយ។ (ប្រសិនបើមិនបានសង្គ្រោះមនុស្សទាំងអស់ទេ នោះមានន័យថា ព្រះបានបរាជ័យនៅក្នុងគោលបំណងរបស់ទ្រង់ ដែលរកគិតមិនដល់)។

នៅទីនេះ យើងឲ្យអត្ថន័យ បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ថា "ជាអ្វីៗដែលទ្រង់សព្វព្រះហឫទ័យចង់ធ្វើ" អញ្ចឹង យើងដឹងយ៉ាងច្បាស់ថា វាត្រូវតែកើតឡើង

ជាមិនខាន។ ដូច្នេះយើងសួរថា៖ អញ្ចឹងពាក្យថា “មនុស្សទាំងអស់” អាចមានន័យថាយ៉ាងដូចម្តេច បើយើងដឹងយ៉ាងច្បាស់ថា “មនុស្សទាំងអស់” មិនបានទទួលសេចក្តីសង្គ្រោះហើយនោះ? សាវ័ក ប៉ុលក៏បាននិយាយដែរថាពាក្យ “មនុស្សទាំងអស់” សំដៅលើ “ប្រភេទមនុស្សទាំងអស់ដែលកំពុងរស់នៅក្នុងសម័យនៃការប្រកាសដំណឹងល្អនេះ”។ បច្ចុប្បន្ននេះ មធ្យោបាយនៃព្រះគុណ និងវិសាលភាពនៃពួកជំនុំ កំពុងតែពង្រីកទៅគ្រប់ទីកន្លែងក្នុងលោកិយនេះ។ ដូច្នេះ យើងគួរអធិស្ឋានសម្រាប់មនុស្សគ្រប់ប្រភេទ (ចូរប្រៀបធៀបខ១ និងខ២ “ទាំងពួកស្តេច និងពួកមន្ត្រី”) ដ្បិតឥឡូវនេះ ព្រះអម្ចាស់នឹងសង្គ្រោះមនុស្សគ្រប់ប្រភេទ ហើយមិនមែនតែពួកយូដាប៉ុណ្ណោះទេ។

ចូរចំណាំការពីរយ៉ាង៖

ក. ព្រះសព្វព្រះហឫទ័យ ឲ្យមនុស្សមួយចំនួនគ្រប់ប្រភេទទាំងអស់ គួរទទួលបាននូវ សេចក្តីសង្គ្រោះ និងការស្គាល់ពីសេចក្តីពិត។

ខ. នោះសបញ្ជាក់ឲ្យឃើញយ៉ាងច្បាស់ថា វាមិនមែនជា ព្រះហឫទ័យរបស់ព្រះទេ ដែលមនុស្សជាតិទាំងអស់គួរស្គាល់ពី សេចក្តីពិតនោះ។ ការនេះបានប្រាប់យ៉ាងច្បាស់ហើយ ដូចជានៅក្នុង បទគម្ពីរទំនុកដំកើង ១៤៧:១៩-២០; ម៉ាថាយ ១១:២៥-២៦; កិច្ចការ ១៤:១៦; កូល៉ុស ១:២៦; កិច្ចការ ១៧:៣០។

ដោយហេតុផលទាំងនេះ យើងសូមបដិសេធចំពោះការដែលគេថា ពាក្យ “មនុស្សទាំងអស់” ដែលនៅក្នុងព្រះគម្ពីរ អាចមានន័យសំដៅលើមនុស្សទាំងអស់។ វាមានន័យសំដៅលើតែមនុស្សមួយចំនួនគ្រប់ប្រភេទដែលត្រូវបានលោះដោយព្រះគ្រីស្ទតែប៉ុណ្ណោះ ដូចជានៅក្នុងខ៦។ ការនេះត្រូវគ្នាជាមួយអ្វីដែលបានចែងនៅក្នុងបទគម្ពីរវិវរណៈ ៥:៩។

២. ឥឡូវនេះ ចូរយើងមកឯបទគម្ពីរមួយទៀតដែលគេប្រើជាញឹកញាប់ដើម្បីលើកឡើងអំពីការធួននឹងបាបជាសកល -២ពេត្រុស ៣:៩។ ពីខគម្ពីរនេះ គេនិយាយថាៈ

ក. ព្រះមិនមានព្រះហឫទ័យឲ្យអ្នកណាម្នាក់វិនាសឡើយ ហើយ

ខ. ព្រះសព្វព្រះហឫទ័យឲ្យមនុស្សគ្រប់គ្នាបានប្រែចិត្ត។

ដ្បិតមានតែ ដោយសារការសុគតរបស់ព្រះគ្រីស្ទប៉ុណ្ណោះ ដែលមនុស្សអាចមកឯការប្រែចិត្តបាន អញ្ចឹងមានន័យថាទ្រង់ច្បាស់ជាសុគតសម្រាប់មនុស្សគ្រប់គ្នាហើយ។

យើងមិនត្រូវការនិយាយពាក្យច្រើន ក្នុងការឆ្លើយនឹងការលើកឡើងនេះទេ។ នៅទីនេះ សាវ័ក កំពុងនិយាយអំពីពាក្យថា "យើង"។ តើមនុស្សទាំងនេះជានរណា? បើមើលពីបរិបទនៃសំបុត្រ យើងអាចឆ្លើយថា ពួកគេជាអ្នកដែលៈ

ក. ទទួលបានសេចក្តីសន្យាដ៏ធំវិសេសបំផុត ជំពូក ១:៤។

ខ. គេហៅថា "ពួកស្ងួនភ្ងា" ជំពូក ៣:១។

គ. ត្រូវបានញែកពីមនុស្សចំអក ជំពូក ៣:៣។

ឃ. គេហៅនៅក្នុងសំបុត្រដំបូងរបស់គាត់ថា "ពួកអ្នករើសតាំង" ជំពូក ១:២។

ង. គេហៅនៅក្នុងសំបុត្រដំបូងរបស់គាត់ថា "រាស្ត្រដ៏ជាកេរអាករ" ជំពូក ២:៩។

ឥឡូវបើគេវែកញែកថា ព្រះអម្ចាស់មិនឲ្យមនុស្សគ្រប់ប្រភេទទាំងអស់ខាងលើនេះវិនាសទេ នោះមានន័យថា ទ្រង់មានព្រះហឫទ័យឲ្យមនុស្សទាំងអស់បានប្រែចិត្តឬ? នោះពិតជាល្ងីល្ងើណាស់! ខនេះបានបញ្ជាក់ច្បាស់ណាស់ថា មានតែរាស្ត្រជ្រើសរើសរបស់ព្រះប៉ុណ្ណោះដែលមិនត្រូវវិនាស។

៣. បទគម្ពីរបន្ទាប់ដែលត្រូវពិនិត្យគឺ ហេព្រើរ ២:៩។ នៅទីនេះ បានចែងថា ព្រះគ្រីស្ទបានភ្លក់សេចក្តីស្លាប់ជំនួសមនុស្សទាំងអស់។ ពាក្យថា “មនុស្សទាំងអស់” ជាញឹកញាប់ ត្រូវបានគេប្រើសំដៅលើមនុស្សទាំងអស់នៃប្រភេទជាក់លាក់មួយ។ ឧទាហរណ៍៖

ក. ១កូរិនថូស ១២:៧ ជាក់ស្តែង គឺសំដៅលើមនុស្សទាំងអស់ដែលព្រះបានប្រទានអំណោយទានមក។

ខ. កូល៉ុស ១:២៨ ជាក់ស្តែង គឺសំដៅលើមនុស្សទាំងអស់ដែលមិនលើសពីមនុស្សដែលសាវ័ក ប៉ុលបានប្រកាសប្រាប់។

ដូច្នេះនៅត្រង់កន្លែងនេះ បរិបទរបស់វាចង្អុលបង្ហាញពីអស់អ្នកដែលព្រះគ្រីស្ទបានភ្លក់សេចក្តីស្លាប់ជំនួស។ ពួកគេជា (ហេព្រើរ ២)៖

ក. កូនជាច្រើន (ខ ១០)

ខ. ពួកអ្នកដែលទ្រង់ញែកជាបរិសុទ្ធ (ខ ១១)

គ. បងប្អូន (ខ ១១)

ឃ. ពួកកូនចៅដែលព្រះបានប្រទានមក (ខ ១៣)

ង. ពួកអ្នកដែលទ្រង់ប្រោសឲ្យរួច (ខ ១៥)

ពួកទាំងអស់ខាងលើនេះហើយ ដែលព្រះគ្រីស្ទបានភ្លក់សេចក្តីស្លាប់ជំនួស។ ដ្បិតគ្មានចំណុចណាមួយនៃការពិពណ៌នាខាងលើនេះ អាចសំដៅទៅអ្នកដែលមិនជឿទេ នោះមានន័យថា “មនុស្សទាំងអស់” នៅត្រង់នេះ មិនអាចសំដៅលើមនុស្សទាំងអស់បានឡើយ។

៤. ២កូរិនថូស ៥:១៤-១៥ ត្រង់នេះត្រូវបានគេទាញឲ្យមានន័យថា ព្រះគ្រីស្ទបានសុគតសម្រាប់មនុស្សទាំងអស់ដែលបានស្លាប់ទៅហើយ។ ប៉ុន្តែ សាវ័ក ប៉ុល គ្រាន់

តែនិយាយថា មនុស្សទាំងអស់ដែលព្រះគ្រីស្ទបានសុគតជំនួសបានស្លាប់ហើយ ហើយឥឡូវនេះ ពួកគេបានរស់សម្រាប់ទ្រង់។ មានតែពួកអ្នកជឿប៉ុណ្ណោះ ដែលមានចិត្តចង់ធ្វើយ៉ាងដូច្នោះ។ ការដែលគេនិយាយថាព្រះគ្រីស្ទត្រូវសុគត ហើយនិងរស់ឡើងវិញសម្រាប់ពួកគេ គឺជាការពិតរបស់ពួកអ្នកជឿប៉ុណ្ណោះ។

នៅពេលសាវ័ក ប៉ុល និយាយថា "នោះទាំងអស់ឈ្មោះថាស្លាប់ហើយ" សេចក្តីស្លាប់នេះ គាត់មិនបាននិយាយសំដៅពីសេចក្តីស្លាប់ក្នុងអំពើបាបរបស់មនុស្សទាំងអស់ទេ គឺនិយាយពីសេចក្តីស្លាប់ខាងឯព្រលឹងវិញ្ញាណវិញ។ គោលបំណងរបស់គាត់ គឺចង់បង្ហាញថា អស់អ្នកដែលព្រះគ្រីស្ទបានសុគតជំនួស ឥឡូវនេះបានស្លាប់ខាងអំពើបាបហើយ ហើយរស់នៅខាងឯព្រះវិញ។ នៅត្រង់នេះ គ្មានអ្វីដែលគាត់និយាយអំពីការធួននឹងបាបជាសកលមួយនោះទេ ប៉ុន្តែគាត់បាននិយាយច្រើនអំពីការសុគតរបស់ព្រះគ្រីស្ទ ដែលមានលទ្ធផលនៅក្នុងមនុស្សដែលកំពុងរស់នៅជាជីវិតបរិសុទ្ធមួយតែប៉ុណ្ណោះ!

៥. ១កូរិនថូស ១៥:២២ ដែលខនេះមិនអាចប្រើដើម្បីបង្ហាញថា ព្រះគ្រីស្ទបានសុគតជំនួសមនុស្សទាំងអស់ គឺបានបង្ហាញយ៉ាងច្បាស់ពីសេចក្តីពិតដែល សាវ័ក ប៉ុល សរសេរនៅក្នុងខ២៣ អំពីសេចក្តីរស់ឡើងវិញនៃ "ពួកអ្នកដែលជារបស់ផងព្រះគ្រីស្ទ" ហើយនៅក្នុងខ២០ អំពីការសម្រាប់ពួកអ្នកដែល "ព្រះគ្រីស្ទជាផលដំបូង"។ ជាការពិតណាស់ ការទាំងអស់នេះមិនអាចនិយាយអំពីមនុស្សទាំងអស់បានទេ។ នៅត្រង់នេះ សាវ័ក ប៉ុល និយាយអំពីអ្នកជឿ ជាពួកអ្នកដែលបានស្លាប់នៅក្នុងអ័ដាម ហើយជាពួកអ្នកដែលត្រូវបានធ្វើឲ្យមានជីវិតនៅក្នុងព្រះគ្រីស្ទ។

៦. រ៉ូម ៥:១៨ នេះគឺជាខមួយដែលត្រូវបានប្រើច្រើន ដោយមនុស្សមួយចំនួនដើម្បីគាំទ្រគំនិតដែលថា ការសុគតរបស់ព្រះគ្រីស្ទនាំឲ្យមនុស្សទាំងអស់មានជីវិត។ យើងអាចនិយាយដោយខ្លីៗថា "មនុស្សទាំងអស់" នៅក្នុងពាក់កណ្តាលទីពីរនៃខនេះ គេអាចយល់សំដៅលើអស់អ្នកដែលទទួលអំណោយទានដ៏ឥតគិតថ្លៃនោះ តែ

ប៉ុណ្ណោះ។ ពួកគេត្រូវបានពិពណ៌នានៅក្នុងខ១៧ ថាជាពួកអ្នកដែល “ពួកអ្នកដែលទទួលព្រះគុណដ៏បរិបូរ” ជាអ្នកដែល “បានសោយរាជ្យក្នុងជីវិតលើសទៅទៀតដោយសារតែម្នាក់...គឺព្រះយេស៊ូវគ្រីស្ទ” ហើយនៅក្នុងខ១៩ ជាពួកអ្នកដែល “បានត្រលប់ជាសុចរិត”។ ក្នុងចំណុចទាំងអស់នេះ មិនមានចំណុចណាមួយដែលនិយាយសំដៅអំពីមនុស្សទាំងអស់ទេ។

ប៉ុន្តែដោយព្រោះ គេយកខនៃបទគម្ពីរនេះមកវែកញែកច្រើន ដូច្នេះយើងនឹងសិក្សាបទគម្ពីរទាំងមូលនេះ ឲ្យកាន់តែពេញលេញឡើងថែមទៀត។ គេនិយាយថា រវាងព្រះគ្រីស្ទ និងលោកអ័ដាម មានភាពស្រដៀងគ្នាមួយ (ខ ១៤)។ មានកិច្ចការខ្លះដែលព្រះគ្រីស្ទបានធ្វើ ដូចជាកិច្ចការខ្លះដែលលោកអ័ដាមបានធ្វើដែរ។ (នៅពេលដំណាលគ្នានោះ សាវ័ក ប៉ុល បានចង្អុលបង្ហាញថា មានកិច្ចការជាច្រើនដែលខុសគ្នារវាង លោក អ័ដាម និងព្រះគ្រីស្ទ ខ១៥-១៦ និងខ១៧។ ពីការនេះយើងឃើញថា យើងមិនអាចបង្ហាញថា លោកអ័ដាម និងព្រះគ្រីស្ទ មិនមានលក្ខណៈដូចគ្នាទាំងស្រុងបានទេ)។ ការប្រៀបធៀបនៅទីនេះ គឺសំដៅពីរបៀបដែលទង្វើរបស់អ័ដាម ធ្វើឲ្យមានឥទ្ធិពលដល់មនុស្សដទៃទៀត ដូចជាខ្លួនគាត់ផ្ទាល់ដែរ ហើយទង្វើរបស់ព្រះគ្រីស្ទក៏ដូចគ្នាដែរ គឺទង្វើរបស់ទ្រង់ធ្វើឲ្យមានឥទ្ធិពលដល់មនុស្សដទៃទៀត។ គេមិនបានវែកញែកថា “មនុស្សទាំងអស់” ដែលបានទទួលឥទ្ធិពលពីលោកអ័ដាម គឺជា “មនុស្សទាំងអស់” ដដែល ដែលបានទទួលឥទ្ធិពលពីព្រះគ្រីស្ទទេ។ ការនេះនឹងត្រូវបានបង្ហាញយ៉ាងច្បាស់ដូចខាងក្រោម៖

ក. បទគម្ពីរបានចាត់ទុកព្រះគ្រីស្ទថា ជាពូជរបស់ស្ត្រី (លោកុប្បត្តិ ៣:១៥)។ ដូច្នេះ មិនមានន័យថា ទ្រង់ក៏ជាអ្នកតំណាងនៃពូជរបស់ សត្វពស់ ជាពូជដែលត្រូវបានញែកចេញពីពូជស្ត្រីផងបានទេ។ និយាយឲ្យខ្លីទៅព្រះគ្រីស្ទមិនអាចតំណាងឲ្យពូជ ឬកូនចៅទាំងអស់ របស់អ័ដាមបានទេ។

ខ. នៅក្នុង យ៉ូហាន ១៧:៩ ព្រះយេស៊ូវផ្ទាល់បានបង្ហាញថា ទ្រង់ មិនមែនជាអ្នកតំណាងរបស់មនុស្សទាំងអស់ដែលកើតមកពី អ័ដាម ទេ។

គ. នៅក្នុងហេព្រើរ ៧:២២ គេហៅព្រះគ្រីស្ទថា ជាអ្នកតំណាង របស់ពួកអ្នកដែលស្ថិតនៅក្រោមសេចក្ដីសញ្ញាថ្មីមួយ។ សេចក្ដីសញ្ញា ថ្មីនេះគឺមិនបានធ្វើជាមួយពូជ ឬកូនចៅអ័ដាមទាំងអស់ទេ។

ឃ. អេសាយ ៥៣:៥-៦ បានបង្ហាញយ៉ាងច្បាស់ថា ព្រះគ្រីស្ទត្រូវ រងទុក្ខជំនួសអ្នកដទៃ។ បទគម្ពីរបានចង្អុលបង្ហាញថា មនុស្សមួយ ចំនួននឹងរងទុក្ខសម្រាប់ខ្លួនឯង។ ដូច្នេះព្រះគ្រីស្ទមិនមែនជាអ្នក តំណាងនៃពូជទាំងអស់របស់អ័ដាមទេ។

ង. ព្រះគ្រីស្ទមិនអាចតំណាងឲ្យនរណាម្នាក់ ជាអសារឥតការឡើយ។ ប៉ុន្តែប្រសិនបើទ្រង់ជាអ្នកតំណាងមនុស្សទាំងអស់ នោះការងារ របស់ទ្រង់ សម្រាប់ពួកអ្នកដែលត្រូវទទួលទោសធ្លាក់ស្ថាននរក នឹងទៅជាអសារឥតការមិនខាន។

ច. ប្រសិនបើ ព្រះជាម្ចាស់សព្វព្រះហឫទ័យនឹងអ្វីដែលព្រះរាជ បុត្រាបានធ្វើ ដូចជាទ្រង់បានសព្វព្រះហឫទ័យហើយ នោះទ្រង់ ច្បាស់ជាសព្វព្រះហឫទ័យនឹងពួកអ្នក ដែលព្រះរាជបុត្រាបានធ្វើ ជំនួស ដែរ។ ប៉ុន្តែព្រះជាម្ចាស់មិនសព្វព្រះហឫទ័យនឹងមនុស្ស ទាំងអស់ទេ។ ដូច្នេះព្រះគ្រីស្ទមិនគួរអាចនឹងតំណាងឲ្យមនុស្ស ទាំងអស់បានដែរ។

ឆ. ដែលព្រះគ្រីស្ទមិនអាចតំណាងឲ្យមនុស្សទាំងអស់ ដូចជា លោកអ័ដាមបាន គឺបានបង្ហាញយ៉ាងច្បាស់តាមបទគម្ពីរដូចជាម៉ាថាយ ២០:២៨; ២៦:២៨ យ៉ូហាន ១០:១៥; ១៧:៩ កិច្ចការ ២០:២៨ និងរ៉ូម ៨:៣៣។

# ជំពូក ៧

*ការពន្យល់ពីខគម្ពីរដែលហាក់ដូចជា លើកឡើងថា*

*អស់អ្នកដែលព្រះគ្រីស្ទបានសុគតជំនួស នៅតែអាចវិនាសបាន*

អ្នកខ្លះបានវែកញែកសម្រាប់ការប្រោសលោះសកលមួយ ដោយម៉ឺងម៉ាត់ថា មានបទគម្ពីរខ្លះលើកឡើងថា មនុស្សមួយចំនួនដែលព្រះគ្រីស្ទបានសុគតជំនួស នៅតែអាចវិនាសបាន។ នៅក្នុងករណីនេះ វាមិនមែនជាបញ្ហាទៀតទេ ដែលគេថា ព្រះគ្រីស្ទគួរសុគតជំនួសមនុស្សទាំងអស់ តែមិនបានសង្គ្រោះមនុស្សទាំងអស់នោះ។

ជាដំបូង ខ្ញុំសូមនិយាយថា ប្រសិនបើមនុស្សខ្លះដែលព្រះគ្រីស្ទបានសុគតជំនួសត្រូវបានបាត់បង់ នោះមិនអាចបង្ហាញថា ទ្រង់បានសុគតជំនួសមនុស្សបាត់បង់ទាំងអស់នោះឡើយ! ហើយជាការពិតណាស់ យើងសូមបដិសេធថា គ្មានបទគម្ពីរណាមួយដែលលើកឡើងថា រាស្ត្ររើសតាំងណាមួយរបស់ព្រះអាចនឹងបាត់បង់ទៅបានឡើយ។ ដូច្នេះចូរយើងពិនិត្យមើលបទគម្ពីរនានាដែលត្រូវបានប្រើជាញឹកញាប់ ដោយអស់អ្នកដែលយើងជំទាស់។

១. រ៉ូម ១៤:១៥ នៅត្រង់នេះ គេបាននិយាយថា សាវ័ក ប៉ុល បង្រៀនថា អ្នកដែលព្រះគ្រីស្ទបានសុគតជំនួស អាចនឹងវិនាសបាន។ យើងសូមឆ្លើយថា ខនោះមិនបាននិយាយយ៉ាងដូច្នេះទេ។ សាវ័ក ប៉ុល មិនបាននិយាយអ្វី ក្រៅពីព្រមានដល់យើងពីអ្វីដែលយើងមិនត្រូវធ្វើ នោះទេ។ ការព្រមានមិនឲ្យធ្វើអ្វីមួយ មិនបង្ហាញថាយើងអាចធ្វើការនោះបានទេ។

យើងត្រូវតែចងចាំផងដែរថា បទគម្ពីរបានប្រើពាក្យ “ពួកបរិសុទ្ធ” និង “បងប្អូន” ដើម្បីពិពណ៌នាពីមនុស្សទាំងអស់ដែលនិយាយថា ជាសមាជិកនៃពួក

ជំនុំរបស់ព្រះគ្រីស្ទ។ បទគម្ពីរនេះមិនបង្ហាញថា អ្នកដែលព្រះគ្រីស្ទបានសុគតជំនួស អាចវិនាសបាត់បង់ទេ។ វាអាចត្រឹមតែបង្ហាញថា ប្រសិនបើអ្នកខ្លះដែលយើងបាន គិតថាជា "បងប្អូន" តែតាមពិតមិនមែនជាបងប្អូនវិញនោះ ពួកគេនឹងត្រូវបានបាត់ បង់នៅទីបំផុតជាពុំខាន។

២. ១កូរិនថូស ៨:១១ គេបាននិយាយម្តងទៀតនៅទីនេះថា អ្នកដែលព្រះគ្រីស្ទ បានសុគតជំនួសនឹងត្រូវវិនាស។ យើងសូមឆ្លើយថា វាមិនចាំបាច់ទាល់តែសោះ ដែលពាក្យ "វិនាស" នៅក្នុងកន្លែងនេះ មានន័យសំដៅទៅការធ្លាក់ស្ថាននរកអស់ កល្បជានិច្ច។ អំពើបាបតែងតែធ្វើឲ្យមានការវិនាសជានិច្ច តែវាក៏អាចនឹងមិននាំទៅ រកសេចក្តីវិនាសតែរហូតដែរ ដ្បិតមនុស្សមានបាបខ្លះត្រូវបានទទួលសេចក្តី សង្គ្រោះដោយសារព្រះគ្រីស្ទ។

ហើយការដែលគាត់ហៅអ្នកនោះថា "បងប្អូន" គាត់មិនបានសំដៅអ្វីដែល លើសពីហ្នឹងទេ។ នៅខនេះ មិនមានភស្តុតាងណាមួយបង្ហាញថា អ្នកដែល ព្រះគ្រីស្ទបានសុគតជំនួស បាត់បង់រហូតដល់អស់កល្បទេ។

៣. ២ពេត្រុស២:១ មុនពេលគេអាចប្រើខនេះដើម្បីបង្ហាញថា ព្រះគ្រីស្ទបានសុគត ជំនួសមនុស្សទាំងអស់រួមទាំងពួកអ្នកដែលត្រូវវិនាសផងនោះ ខនេះច្បាស់ជា បង្ហាញថា៖

ក. ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ត្រូវបានគេឲ្យមានន័យសំដៅលើ ពាក្យ ថា "ព្រះជាម្ចាស់ ឬព្រះអម្ចាស់" ហើយ

ខ. សេចក្តីប្រោសលោះដោយការសុគតរបស់ព្រះគ្រីស្ទ ត្រូវបានគេ ឲ្យមាន ន័យសំដៅថា "ទិញ"។

គ. គ្រូទាំងនោះជាពួកអ្នកជឿពិត ហើយមិនគ្រាន់តែជាគ្រូបង្រៀន នោះ ទេ។

ឃ. ពួកជ្រើសរើសរបស់ព្រះអាចនឹងវិនាសបានដែរ ហើយ

ង. ការសុគតរបស់ព្រះគ្រីស្ទ គឺសម្រាប់មនុស្សទាំងអស់។

ប៉ុន្តែ ការទាំងនេះសុទ្ធតែមិនជាក់លាក់ ហើយក៏មិនមែនជាមូលដ្ឋានសម្រាប់បង្កើតគំនិតអំពីសេចក្ដីប្រោសលោះជាសកលមួយដែរ។ យើងសូមបង្ហាញថា៖

ក. ពាក្យ “ព្រះអម្ចាស់” ដែលគេប្រើនៅក្នុងទីនេះ និងកន្លែងផ្សេងទៀតនៅក្នុងព្រះគម្ពីរសញ្ញាថ្មី គឺមិនមែនជាពាក្យក្រិកដែលគេតែងប្រើជាញឹកញាប់សំដៅទៅព្រះយេស៊ូវគ្រីស្ទនោះទេ។ ពាក្យនេះសំដៅទៅព្រះជាម្ចាស់ច្រើនជាង ដែលមានន័យថា ទ្រង់ជាចៅហ្វាយ ឬម្ចាស់នៃមនុស្សទាំងអស់។

ខ. ពាក្យ “ទិញ” ជាធម្មតាត្រូវភ្ជាប់ជាមួយនឹងពាក្យផ្សេងទៀត ដូចជា “ដោយព្រះលោហិត” ឬ “ដោយការសុគត” ឬ “ដោយតម្លៃមួយ” នៅពេលនិយាយសំដៅពីការសុគតរបស់ព្រះគ្រីស្ទ។ នៅទីនេះ បើគ្មានពាក្យទាំងនេះទេ នោះនឹងធ្វើឲ្យវាមានលក្ខណៈចន្លោះប្រហោង ដូច្នេះវាអាចនឹងមានន័យថា អ្វីដែលត្រូវបានទិញមកនេះ គឺគ្រាន់តែជាការប្រោសទូទៅមួយពីសេចក្ដីអាក្រក់ខ្លះៗនៃជីវិតនេះប៉ុណ្ណោះ ដូចជា នៅក្នុងខ២០នៃបទគម្ពីរនេះ។

ទាំងអស់នេះ គឺជាបំណងព្រះហឫទ័យរបស់ព្រះ ដែលក្នុងសេចក្ដីល្អរបស់ទ្រង់ ទ្រង់បានការពារមនុស្សមួយចំនួន ឲ្យរួចពីសេចក្ដីដ៏អាក្រក់នៃលោកិយនេះ។ ប៉ុន្តែដោយសារគ្រូក្លែងក្លាយរបស់ពួកគេ ពួកគេបានបដិសេធមិនឲ្យទ្រង់ការពារពួកគេឡើយ ដូច្នេះហើយ នៅទីបញ្ចប់ពួកគេនៅក្នុងសេចក្ដីវិនាស។ តើគេអាចបង្ហាញភស្តុតាងថា ព្រះគ្រីស្ទបានសុគតសម្រាប់មនុស្សទាំងអស់បានដោយរបៀបណា?

៩. ហេព្រើរ ១០:២៩ ជាចុងក្រោយ គេវែកញែកពីខនេះថា ប្រសិនបើ អ្នកដែលបានញែកជាបរិសុទ្ធ អាចជាន់ឈ្លីព្រះគ្រីស្ទបាន នោះច្បាស់ជាមានន័យថា ទ្រង់បានសុគតជំនួសពួកគេ តែទ្រង់សង្គ្រោះមិនបានសម្រេច។ យើងសូមឆ្លើយថា៖

ក. អ្វីដែលជាគោលបំណងនៅទីនេះ គឺចង់បង្ហាញពីភាពធ្ងន់ធ្ងរនៃ ការបែកបែរពីជំនឿ។ វាជាការដែលធ្ងន់ធ្ងរមួយ ដែលបំពានដល់ ក្រឹត្យវិន័យរបស់លោក ម៉ូសេ។ តើវាធ្ងន់ជាងអម្បាលម៉ានទៅទៀត ដែលបំពានដល់ដំណឹងល្អពីព្រះរាជបុត្រានៃព្រះនោះ!

ខ. នៅទីនេះ គេនិយាយសំដៅទៅបុគ្គល ដែលអះអាងថាខ្លួនជា អ្នកជឿ តែវាមិនដូចជាអ្វីដែលពួកគេបានអះអាងសោះ។

គ. អ្នកនិពន្ធកំពុងប្រើការព្រមានមួយ ដើម្បីការពារមិនឲ្យអ្នកអាន ណាម្នាក់របស់គាត់ បានត្រូវបាត់បង់ឡើយ។ គាត់និយាយថា "ប្រសិនបើ អ្នកបន្តធ្វើបាបតាមចិត្តទៀត..."។ នេះមិនបានបង្ហាញ ថា អ្នកជឿពិតនៅតែអាចបន្តធ្វើយ៉ាងដូច្នេះទៀតទេ។ នៅក្នុង លក្ខណៈដូច គ្នានេះ ព្រះបានដាស់តឿនដល់លោក យ៉ូសែបឲ្យ ភៀសខ្លួនទៅប្រទេសអេហ្ស៊ីប ក្រែងលោស្តេចហេរ៉ូឌសម្លាប់បុត្រ តូចយេស៊ូវ។ ការដាស់ តឿនបានប្រទានមក មិនមែនដោយព្រោះ ព្រះយេស៊ូវអាចនឹងត្រូវគេសម្លាប់នោះទេ ប៉ុន្តែដើម្បីធានាថាទ្រង់ នឹងមិនត្រូវគេសម្លាប់។

ឃ. ការ"រាប់ព្រះលោហិតនៃសេចក្តីសញ្ញាដែលបានញែកគេចេញជាបរិសុទ្ធ" មិនចាំបាច់បង្ហាញថា ពួកទាំងនេះជាពួកអ្នកដែលព្រះគ្រីស្ទបានសុគតជំនួសនោះទេ។

១. ជាញឹកញាប់ ពួកសាវ័កហៅពួកជំនុំជារួមថា "ពួកបរិសុទ្ធ"។ នេះមិនបង្ហាញថា បុគ្គលម្នាក់ៗសុទ្ធតែដូច្នេះនោះទេ។

២. ជួនកាល គេនិយាយអំពីអស់អ្នកដែលបានទទួលបុណ្យជ្រមុជទឹកហើយថាជា "អ្នកដែលបានញែកជាបរិសុទ្ធ" នៅ

ក្នុងគំនិតនេះបង្ហាញថា ជាអ្នកដែលបានញែកពីពួកអ្នកមិន ជ្រមុជទឹក។

ង. ប្រសិនបើគេទទូចថា អស់អ្នកដែលជាន់ឈ្លីព្រះគ្រីស្ទជាអ្នកជឿពិត ប៉ុន្តែបានបាត់បង់វិញ នោះមានន័យថាយើងយល់ព្រមថា៖

១. សេចក្ដីជំនឿ និងភាពបរិសុទ្ធ មិនមែនជាសញ្ញាដៅសំគាល់នៃពួករើសតាំងរបស់ព្រះទេ។

២. គេអាចញែកអ្នកជឿពិត ចេញពីព្រះគ្រីស្ទបាន។យើងបានបង្ហាញពីភាពផ្ទុយគ្នានៃចំណុចទាំងពីរនេះរួចហើយ។

ក្នុងបទគម្ពីរនេះបញ្ជាក់យ៉ាងច្បាស់ ចំពោះអស់អ្នកដែលគ្រាន់តែនិយាយថាខ្លួនជាគ្រីស្ទាន ហើយពួកគេបានធ្វើបាបដ៏អាក្រក់នៃការបំពានលើអ្វីដែលខ្លួនបាននិយាយ។ ហើយនៅពេលព្រមគ្នានោះ វាជាការដាស់តឿនដល់អ្នកជឿពិត ដើម្បីកុំឲ្យពួកគេនឹងធ្វើបាបអញ្ចឹងឡើយ។

ដោយមានជំនួយពីព្រះ ខ្ញុំបានផ្ដល់ជូនលោកអ្នកនូវការពន្យល់យ៉ាងច្បាស់លាស់មួយ ហើយពីបទគម្ពីរដែលគេតែងប្រើជាញឹកញាប់ ដោយពួកអ្នកដែលបង្ហាញថា ព្រះគ្រីស្ទបានសុគតសម្រាប់មនុស្សទាំងអស់ ដូច្នេះបានជាខ្ញុំបង្កើតឲ្យមានជាប្រធានបទនេះឡើង គឺថាការសុគតរបស់ព្រះគ្រីស្ទគឺសម្រាប់តែរាស្ត្ររើសតាំងរបស់ព្រះប៉ុណ្ណោះ។

# ជំពូក ៨

*ការលោតត្រដាងពីការត្រិះរិះពិចារណាមិនត្រឹមត្រូវមួយចំនួន*

វាហាក់ដូចជាមានការវែកញែកល្ងីល្ងើខ្លះ ត្រូវបានគេប្រើប្រាស់នៅបច្ចុប្បន្ននេះ។ ឥឡូវនេះ ខ្ញុំនឹងឆ្លើយដោយត្រួសៗ ហើយបន្ទាប់មកយើងនឹងបញ្ចប់សៀវភៅនេះ។

១. មានការវែកញែកមួយដែលបានវែកញែកយ៉ាងដូចនេះថាៈ

អ្វីដែលមនុស្សគ្រប់គ្នាមានអារម្មណ៍ថាត្រូវតែជឿ នោះវាច្បាស់ជាពិតមិនខាន។ មនុស្សគ្រប់គ្នាត្រូវមានអារម្មណ៍ជឿថា ព្រះគ្រីស្ទបានសុគតសម្រាប់មនុស្សទាំងអស់។ ដូច្នេះវាជាការពិតដែលព្រះគ្រីស្ទបានសុគតសម្រាប់មនុស្សទាំងអស់មែន។

ខ្ញុំគិតថា "មនុស្សគ្រប់គ្នា" នៅក្នុងការវែកញែកនេះគឺសំដៅមនុស្សទាំងអស់ ហើយ "ជឿ" មានន័យថា ជំនឿដែលបានសង្គ្រោះមួយនៅក្នុងព្រះគ្រីស្ទ។ ការមួយដែលយើងបានដឹងច្បាស់អំពីមនុស្សគ្រប់រូបតាមបទគម្ពីរ គឺថាពួកគេស្ថិតនៅក្នុងសណ្ឋាននៃសេចក្តីស្លាប់ខាងព្រលឹងវិញ្ញាណមួយ និងនៅក្រោមសេចក្តីក្រោធរបស់ព្រះជាម្ចាស់។ ដូច្នេះការវែកញែកនេះពិតជាកំពុងតែលើកឡើងពីមនុស្សទាំងអស់ដែលនៅក្នុងសណ្ឋាននៃសេចក្តីស្លាប់ និងការផ្តន្ទាទោសឲ្យត្រូវជឿថា វាជាបំណងព្រះបាប្ទ័យរបស់ព្រះ ដែលព្រះគ្រីស្ទគួរតែសុគតសម្រាប់មនុស្សទាំងអស់ជាពិសេស ហើយ។

គ្មានបទគម្ពីរណាមួយដែលនិយាយថា ព្រះគ្រីស្ទបានសុគតសម្រាប់អ្នកនេះ ឬអ្នកនោះជាក់លាក់នោះទេ ប៉ុន្តែគ្រាន់តែនិយាយថា ទ្រង់បានសុគតសម្រាប់ "មនុស្សមានបាប" ដោយមិនបង្ហាញពីបុគ្គលជាក់លាក់ណាមួយ ប៉ុណ្ណោះ។ ហើយក៏គ្មានការបង្គាប់ ឬសេចក្តីសន្យានៃព្រះគម្ពីរ ហៅអ្នកណាមួយឲ្យមកជឿថា ព្រះគ្រីស្ទបានសុគតសម្រាប់ខ្លួនជាពិសេសនោះដែរ។

លើសពីនោះទៀត វាមិនមែនជាការពិតទេ ដែលមនុស្សទាំងអស់ត្រូវចង់ជឿដើម្បីឲ្យបានសង្រ្គោះនៅក្នុងព្រះគ្រីស្ទនោះ លុះត្រាតែព្រះគម្ពីរប្រាប់ឲ្យមនុស្សទាំងអស់ធ្វើអញ្ចឹង។ វាមិនអាចជាកាតព្វកិច្ចនៃមនុស្សរាប់លាននាក់ដែលមិនធ្លាប់ឮពីព្រះគ្រីស្ទ ត្រូវមានសេចក្តីជំនឿដែលបានសង្រ្គោះក្នុងទ្រង់នោះទេ។ សាវ័ក ប៉ុលបានបង្ហាញនៅក្នុងគម្ពីររ៉ូម ២:១២ថា មនុស្សជាច្រើននឹងត្រូវផ្តន្ទាទោស ដោយគ្រាន់តែអំពើបាបដែលប្រឆាំងនឹងការបំភ្លឺនៃធម្មជាតិ។ នេះជាភស្តុតាងដែលបង្ហាញថា សេចក្តីជំនឿដែលបានសង្រ្គោះនៅក្នុងព្រះគ្រីស្ទ គឺមិនតម្រូវឲ្យពួកគេធ្វើអ្វីនោះទេ! ដូច្នេះ ការវែកញែកនេះច្បាស់ជាត្រូវសរសេរម្តងទៀតថា៖

មនុស្សទាំងអស់ដែលបានហៅមកដោយដំណឹងល្អឲ្យបានជឿ នោះត្រូវតែជាការពិត។មនុស្សទាំងអស់ដែលបានឮដំណឹងល្អ គឺត្រូវតែមានចិត្តចង់ជឿ ថាព្រះគ្រីស្ទបានសុគតសម្រាប់ខ្លួនជាពិសេស។

ដូច្នេះជាការពិត ដែលព្រះគ្រីស្ទបានសុគតសម្រាប់មនុស្សទាំងអស់ដែលឮដំណឹងល្អ។ តើអ្នកណាទៅដែលមិនឃើញថា ការវែកញែកនេះ ជាបុព្វហេតុឥតប្រយោជន៍ដែលវាការពារនោះ ! ឥឡូវនេះយើងកំពុងតែសារភាពថា ជំនឿនោះមិនតម្រូវឲ្យមនុស្សទាំងអស់ទេ ប៉ុន្តែតម្រូវឲ្យតែពួកដែលឮដំណឹងល្អប៉ុណ្ណោះ។ ដូច្នេះការវែកញែកសម្រាប់សេចក្តីប្រោសលោះជាសកលទូទៅមួយ គឺត្រូវបានបំផ្លាញអស់រលីងហើយ។

ជាថ្មីម្តងទៀត យើងសូមបដិសេធចំពោះការវែកញែកទីពីរ។ នៅពេលដែលដំណឹងល្អត្រូវបានប្រកាស អ្វីដែលគេអាចនិយាយត្រឹមតែថា “អ្នកណាដែលជឿ ហើយទទួលបុណ្យជ្រមុជទឹក នោះនឹងបានសង្រ្គោះ តែអ្នកណាដែលមិនព្រមជឿ នោះនឹងត្រូវទោសវិញ” ប៉ុណ្ណោះ (ម៉ាកុស ១៦:១៦) ឬក៏និយាយថា “គ្មានសេចក្តីសង្រ្គោះ ដោយសារអ្នកណាទៀតសោះ ដ្បិតនៅក្រោមមេឃ គ្មាននាមឈ្មោះណាទៀតបានប្រទានមកមនុស្សលោក ឲ្យយើងរាល់គ្នាបានសង្រ្គោះនោះ

ឡើយ (កិច្ចការ ៤:១២)។ និយាយឲ្យស្រួលស្ដាប់ទៅ កាតព្វកិច្ចនៃអ្នកឮដំណឹងល្អ គឺត្រូវជឿថា ចាំបាច់ត្រូវមានអ្នកសង្គ្រោះម្នាក់ ហើយជឿថាព្រះយេស៊ូវគឺជាអ្នកសង្គ្រោះនោះឯង ព្រមទាំងជឿថា ព្រះគ្រីស្ទមិនបានសុគតសម្រាប់មនុស្សទាំងអស់ជាពិសេសនោះទេ។

មានលំដាប់លំដោយមួយនៅក្នុងកិច្ចការនានា ដែលព្រះតម្រូវឲ្យគេបានជឿ។ ទាល់តែពួកគេជឿលើកិច្ចការខ្លះនៃកិច្ចការទាំងនោះ ទើបមានសេចក្ដីសម្រាកបាន។ គេមិនបញ្ជូនឲ្យមនុស្សម្នាក់នៅលើកំពូលកាំជណ្ដើរ ដោយមិនឡើងតាមកាំជណ្ដើរខាងក្រោមៗនោះទេ។ ការនេះវាផ្ទុយពីច្បាប់នៃដំណឹងល្អ ក្នុងការហៅនរណាម្នាក់ឲ្យបានជឿថាព្រះគ្រីស្ទបានសុគតសម្រាប់គាត់ជាពិសេស។ ជាដំបូងអ្នកនោះត្រូវជឿ៖

១. ពីសេចក្ដីពិតនៃដំណឹងល្អជាទូទៅ

២. ថា សេចក្ដីជំនឿគឺជាផ្លូវតែមួយសម្រាប់សេចក្ដីសង្គ្រោះ

៣. ថា យើងត្រូវការអ្នកសង្គ្រោះម្នាក់ ហើយ

៤. ថា ព្រះគ្រីស្ទអាចសង្គ្រោះគាត់បាន។

លំដាប់លំដោយនៃកិច្ចការនានារបស់ព្រះនៅក្នុងការជឿងល់ដំណឹងល្អ ដំបូងអ្នកនោះត្រូវប្រែចិត្ត ហើយជឿថា ដំណឹងល្អគឺជាព្រះបន្ទូលរបស់ព្រះ ព្រមទាំងជឿថាព្រះយេស៊ូវបានបើកសំដែងពីរបៀបនៃការសង្គ្រោះរបស់ព្រះ។ ទីពីរ ត្រូវជឿថាមានទំនាក់ទំនងសំខាន់មួយរវាង សេចក្ដីជំនឿ និងសេចក្ដីសង្គ្រោះ។ ទីបី ត្រូវជឿថា មានសេចក្ដីជំនឿពិសេសមួយ ដោយព្រះវិញ្ញាណបរិសុទ្ធ អំពីភាពចាំបាច់នៃព្រះអង្គសង្គ្រោះមួយអង្គ សម្រាប់គាត់ជាពិសេស ហើយគាត់បានមកដោយ "នឿយព្រួយ ហើយផ្ទុកធ្ងន់"។ ទីបួន ត្រូវជឿថា មានការទុកចិត្តដ៏ម៉ត់ចត់មួយខាងព្រលឹងវិញ្ញាណឯល់ព្រះគ្រីស្ទ ក្នុងការឆ្លើយតបចំពោះសេចក្ដីសន្យានៃដំណឹងល្អ ដើម្បី

ទទួលអស់អ្នកដែលមកឯទ្រង់។

បន្ទាប់ពីការទាំងអស់នេះ នឹងមានការដឹងច្បាស់ពីសេចក្ដីស្រឡាញ់របស់ព្រះ និងការសុគតរបស់ព្រះគ្រីស្ទសម្រាប់គាត់ជាពិសេស ដោយមានមូលដ្ឋានលើសេចក្ដីពិតនោះ ដែលវាជួយឲ្យគាត់អាចធ្វើការទាំងបួនដំបូងនៃសេចក្ដីជំនឿបាន។ (ដ្បិតបើគ្មានជំនួយនៃព្រះវិញ្ញាណរបស់ព្រះទេ នោះគេមិនអាចធ្វើអ្វីបានទាំងអស់)។

ដូច្នេះការវែកញែករបស់យើងត្រូវសរសេរឡើងវិញម្ដងទៀត យ៉ាងដូច្នេះថា៖

អស់អ្នកណាដែលជឿជាក់ ពីភាពចាំបាច់នៃអ្នកសង្គ្រោះម្នាក់ និងផ្លូវត្រឹមត្រូវនៃសេចក្ដីសង្គ្រោះ ព្រមទាំងស្រេកឃ្លានរកព្រះគ្រីស្ទ នឹងមានចិត្តចង់ជឿជាមិនខាន។

មនុស្សទាំងអស់នោះជឿថា ព្រះគ្រីស្ទសុគតសម្រាប់ខ្លួនជាពិសេស។

ដូច្នេះដែលព្រះគ្រីស្ទបានសុគតសម្រាប់មនុស្សបែបនោះ គឺពិតហើយ។

ឥឡូវនេះ វាបានបញ្ជាក់យ៉ាងច្បាស់ថា អស់អ្នកដែលបានឮដំណឹងល្អ មិនត្រឹមតែជឿថា ព្រះគ្រីស្ទបានសុគតសម្រាប់ពួកគេជាពិសេសនោះទេ ប៉ុន្តែពួកគេថែមទាំងត្រូវតែមានលក្ខណ:សម្បត្តិដូចដែលយើងបានពិពណ៌នាខាងលើទៀតផង។ ការបរាជ័យក្នុងការជឿថា ព្រះគ្រីស្ទបានសុគតសម្រាប់ខ្លួនជាពិសេស នោះគឺមិនមែនជាបុព្វហេតុ ដែលនាំឲ្យមានការផ្ដន្ទាទោសរបស់មនុស្សមានបាបទេ។ អ្នកនោះត្រូវបានផ្ដន្ទាទោសរួចស្រេចទៅហើយ ដោយព្រោះគាត់មិនបានជឿពីសេចក្ដីពិតនៃព្រះបន្ទូលរបស់ព្រះជាទូទៅ។

ដូច្នេះដើម្បីសរសេរការវែកញែកនេះ តាមលក្ខណ:សមហេតុផល និងតាមព្រះគម្ពីរ យើងត្រូវតែធ្វើឲ្យឃ្លាថា “មនុស្សទាំងអស់” (នៅក្នុងការវែកញែកទីមួយ) ឲ្យទៅជា “មនុស្សជាច្រើនដែលបានត្រាស់ហៅ” (នៅក្នុងការសរសេរឡើងវិញទីមួយ) វិញ ហើយបន្ទាប់មកពី “មនុស្សជាច្រើនដែលបានត្រាស់ហៅ” ឲ្យទៅជា “មនុស្សមួយចំនួនដែលត្រូវបានជ្រើសរើស” (នៅក្នុងការសរសេរឡើងវិញទីពីរនៃ

ការរែកញែកនេះ)។ នៅត្រង់នេះ តើមានកន្លែងណាមួយដែលគាំទ្រដល់ការប្រោសលោះជាសកលទូទៅមួយដែរឬទេ?

២. ការលើកឡើងមួយទៀតត្រូវបានគេប្រើ ដើម្បីប្រឆាំងនឹងការបង្រៀនដែលថា ការសុគតរបស់ព្រះគ្រីស្ទសម្រាប់តែពួករើសតាំង ដោយចោទសួរថា ប្រសិនបើព្រះគ្រីស្ទមិនបានសុគតសម្រាប់មនុស្សទាំងអស់ទេ តើពួកគេអាចដឹងច្បាស់ថាទ្រង់បានសុគតសម្រាប់ពួកគេដោយរបៀបណា? គោលលទ្ធិនេះ ធ្វើឲ្យចិត្តគំនិតរបស់ពួកអ្នកជឿពោរពេញទៅដោយការសង្ស័យ និងសេចក្តីភ័យខ្លាច។ ប្រសិនបើព្រះគ្រីស្ទមិនបានសុគតសម្រាប់មនុស្សទាំងអស់ទេ តើពួកគេអាចដឹងជាប្រាកដដោយរបៀបណា ដែលថា ទ្រង់បានសុគតសម្រាប់ពួកគេនោះ?

យើងសូមឆ្លើយថា វាមិនមែនជាការចាំបាច់ទេ ដែលអ្នកមានបាបចូលមកឯព្រះគ្រីស្ទ ត្រូវដឹងថាព្រះគ្រីស្ទបានសុគតជំនួសគាត់ជាពិសេសនោះ ។ វាគ្រប់គ្រាន់ហើយ ប្រសិនបើគាត់គ្រាន់តែដឹងថា៖

ក. សេចក្តីសង្គ្រោះតាមរយៈការសុគតរបស់ព្រះគ្រីស្ទ គឺពិតប្រាកដ ចំពោះអ្នកជឿគ្រប់រូប

ខ. អ្នកណាដែលស្តាប់បង្គាប់តាមការត្រាស់ហៅរបស់ព្រះជាម្ចាស់ ព្រះនឹងទទួលស្គាល់

គ. ព្រះគុណដ៏វិសេសឥតគិតថ្លៃ គឺមានសម្រាប់ពួកអ្នកដែលមាន សេចក្តីទុក្ខវេទនា និងអ្នកដែលមានបញ្ហាចិត្តផ្ទុកធ្ងន់ ព្រមទាំងជឿថា

ឃ. ការសុគតរបស់ព្រះគ្រីស្ទ គឺគ្រប់គ្រាន់សម្រាប់ពួកអ្នកដែលមក រកទ្រង់។

ការទាំងអស់នេះត្រូវបានធ្វើឲ្យដឹងប្រាកដច្បាស់ ដោយការសុគតរបស់ព្រះគ្រីស្ទ។ តើត្រូវការអ្វីទៀត? តើគោលលទ្ធិបែបនេះធ្វើឲ្យមានការសង្ស័យដោយរបៀបណា?

ម្យ៉ាងវិញទៀត ប្រសិនបើព្រះគ្រីស្ទបានសុគតសម្រាប់មនុស្សទាំងអស់ តែមនុស្សមួយចំនួនបែរជាបានបាត់បង់របូតអស់កល្បជានិច្ច នោះទើបជាបុព្វហេតុដែលធ្វើឲ្យមានការសង្ស័យ! ប្រសិនបើអ្នកណាម្នាក់ដែលព្រះគ្រីស្ទបានសុគតជំនួសរួចហើយ តែបែរជាត្រូវផ្តន្ទាទោសឲ្យធ្លាក់ស្ថាននរកវិញ យ៉ាងនោះមិនមានការដឹងប្រាកដច្បាស់ថា មនុស្សទាំងអស់នឹងមិនទទួលការផ្តន្ទាទោសនោះទេ!

៣. ប៉ុន្តែមនុស្សមួយចំនួននិយាយថា ព្រះគុណរបស់ព្រះជាម្ចាស់មានពោរពេញទៅដោយសិរីល្អខ្លាំងណាស់ ប្រសិនបើយើងនិយាយថា ព្រះបានចាត់ព្រះរាជបុត្រារបស់ទ្រង់មក ដើម្បីជាសេចក្តីសង្គ្រោះដល់មនុស្សទាំងអស់ នោះពួកគេនឹងមានព្រះគុណនោះប្រសិនបើពួកគេចង់បាន។

យើងសូមឆ្លើយថា តើព្រះគុណអ្វី ដែលទ្រង់ត្រូវធ្វើឡើងសម្រាប់មនុស្សទាំងអស់ជាសកល?

នោះមិនអាចជាព្រះគុណនៃការរើសតាំងបានទេ ដ្បិតព្រះមិនបានជ្រើសរើសមនុស្សទាំងអស់ទេ (រ៉ូម ៩:១១-១៥)

នោះមិនអាចជាព្រះគុណនៃការត្រាស់ហៅដ៏ស័ក្តិសិទ្ធិបានទេ ដ្បិតទ្រង់ត្រាស់ហៅតែអស់អ្នកដែលទ្រង់បានជ្រើសរើសប៉ុណ្ណោះ (រ៉ូម ៨:៣០)

នោះមិនអាចជាព្រះគុណនៃការញែកជាបរិសុទ្ធបានទេ ដ្បិតមានតែពួកជំនុំប៉ុណ្ណោះដែលបានញែកជាបរិសុទ្ធ (អេភេសូរ ៥:២៥-២៧)

នោះមិនអាចជាព្រះគុណនៃការរាប់ជាសុចរិតបានទេ ដ្បិតគ្មានអ្នកណាក្រៅពីអ្នកជឿទេ ដែលត្រូវបានរាប់ជាសុចរិត (រ៉ូម ៣:២២)

នោះមិនអាចជាព្រះគុណនៃការប្រោសលោះបានទេ ដ្បិតពួកអ្នកដែលបានប្រោសលោះត្រូវបានរើសចេញមកពីគ្រប់ជាតិសាសន៍ (វិវរណៈ ៥:៩)។

អញ្ចឹង តើព្រះគុណអ្វីទៅ ដែលអាចជាព្រះគុណសកល?

ប្រសិនបើជាការពិតដែលថា ព្រះមានបំណងព្រះហឫទ័យចង់ឲ្យមនុស្សទាំងអស់បានទទួលសេចក្ដីសង្គ្រោះដោយលក្ខខ័ណ្ឌដែលពួកគេជឿ តើទ្រង់បានរៀបចំលក្ខខ័ណ្ឌដែលពួកគេមិនអាចបំពេញបានឬ? (ប្រៀបដូចជា អ្នកនឹងឲ្យលុយ៥០ម៉ឺនរៀលដល់មនុស្សខ្វាក់ម្នាក់ ប្រសិនបើគាត់បើកភ្នែកមើលឃើញលុយនោះបាន) យ៉ាងអញ្ចឹងដែរ។ តើការនេះអាចបង្ហាញឲ្យឃើញពីព្រះគុណរបស់ព្រះដោយរបៀបណា? តើការនេះ វានឹងមិនធ្វើឲ្យទ្រង់ក្លាយទៅជាអ្នកកំពុតទៅហើយឬ? ប្រសិនបើអ្នកចង់ពង្រីកព្រះគុណនៃសេចក្ដីសង្គ្រោះសម្រាប់មនុស្សទាំងអស់ នោះចូរអ្នកពង្រីកវាសម្រាប់ពួកអ្នកបាត់បង់វិញទៅ! ដូច្នេះ ព្រះគុណសកល ជារឿយៗមិនមានភាពស័ក្ដិសិទ្ធិទេ។ តើអ្នកពិតជាបានពង្រីកព្រះគុណនោះឲ្យធំជាងមុនឬ?

៤. អ្នកខ្លះក៏បាននិយាយដូច្នេះដែរថា សេចក្ដីល្អនៃការសុគតរបស់ព្រះគ្រីស្ទនឹងកាន់តែធំឡើង ប្រសិនបើសេចក្ដីល្អនោះត្រូវបានផ្ដល់ឲ្យមនុស្សទាំងអស់។

យើងសូមឆ្លើយថា សេចក្ដីល្អនៃការសុគតរបស់ព្រះគ្រីស្ទ មិនបានវាស់ដោយចំនួនមនុស្សដែលវាគ្របដណ្ដប់នោះទេ ប៉ុន្តែដោយបំណងព្រះហឫទ័យដែលទ្រង់សម្រេចវិញ។ មិនថាអ្នកទទួលប្រយោជន៍ជាមនុស្សច្រើន ឬមនុស្សតិចទេ ព្រះមានបំណងព្រះហឫទ័យត្រឹមណា វាមិនអាចមានសេចក្ដីល្អដែលធំជាងនោះបានឡើយ។

៥. អ្នកខ្លះបាននិយាយថា នឹងមានហេតុផលប្រសើរជាងសម្រាប់មនុស្សទាំងអស់ក្នុងការទាញយកសេចក្ដីកំសាន្តចិត្តពីការសុគតរបស់ទ្រង់ ប្រសិនបើព្រះគ្រីស្ទបានសុគតសម្រាប់មនុស្សទាំងអស់។

យើងសូមឆ្លើយនឹងការលើកឡើងនេះថា សេចក្ដីកំសាន្តចិត្តជាកម្មសិទ្ធិរបស់អ្នកជឿ (ហេព្រើរ ៦:១៧ ១៨) រីឯអ្នកមិនជឿវិញគឺនៅក្រោមសេចក្ដីក្រោធរបស់ព្រះ (យ៉ូហាន ៣:៣៦)។ អ្នកជឿមិនអាចទទួលសេចក្ដីកំសាន្តចិត្ត ដោយសារការពង្រីកការសុគតរបស់ព្រះគ្រីស្ទ ដើម្បីបញ្ចូលពួកអ្នកដែលនៅជាប់ក្រោមសេចក្ដី

ក្រោធរបស់ព្រះ មកជាមួយផងបានទេ។

នៅពេលណាមានការល្បួងល និងសេចក្តីល្បួង សូមឲ្យគេព្យាយាមកំសាន្ត ចិត្តខ្លួនគេដោយការវែកញែកខាងក្រោមនេះចុះ

ព្រះគ្រីស្ទបានសុគតសម្រាប់មនុស្សទាំងអស់

ខ្ញុំជាមនុស្សម្នាក់

ដូច្នេះ ព្រះគ្រីស្ទបានសុគតសម្រាប់ខ្ញុំហើយ។

តើចិត្តរបស់គាត់ នឹងមិនប្រាប់គាត់ថា នេះគឺជាការគិតខុសទេឬអី? តើមិនមានកូនមនុស្សរាប់លាននាក់ ដែលព្រះមិនបានបើកសម្តែងអង្គទ្រង់ឲ្យពួកគេស្គាល់ទេឬអី? តើមានការកំសាន្តចិត្តអ្វី នៅក្នុងការដែលគិតយ៉ាងដូច្នេះ?

ប្រភពដ៏ធំមួយនៃសេចក្តីកំសាន្តចិត្តចំពោះអ្នកជឿ គឺសេចក្តីពិតដែល ព្រះគ្រីស្ទ កំពុងតែអង្វរព្រះជាម្ចាស់សម្រាប់ពួកអ្នកដែលទ្រង់បានសុគតជំនួស។ ការនេះយើងបានបង្ហាញពីមុនរួចមកហើយ (ផ្នែកទី១ ជំពូក ៧)។ ប្រសិនបើការសុគតរបស់ព្រះគ្រីស្ទ គឺសម្រាប់មនុស្សទាំងអស់ តែការអង្វរជំនួសរបស់ទ្រង់មិនសម្រាប់មនុស្សទាំងអស់ (យ៉ូហាន ១៧:៩) នោះមិនមែនជាសេចក្តីកំសាន្តចិត្តទេ ពីព្រោះគេមិនអាចញែកការសុគតរបស់ព្រះគ្រីស្ទចេញពីការអង្វរជំនួសរបស់ទ្រង់បាន។ យើងមិនអាចបង្កើនសេចក្តីកំសាន្តចិត្ត ដោយសារការពង្រីកការធួននឹងបាបនៃការសុគតរបស់ទ្រង់ ឲ្យធំទូលាយជាងការអង្វរជំនួសរបស់ទ្រង់បានឡើយ។

ប្រសិនបើសេចក្តីជំនឿ និងភាពបរិសុទ្ធនៃពួករើសតាំង មិនរកបានមកសម្រាប់ពួកគេ ដោយការសុគតរបស់ព្រះគ្រីស្ទទេ អញ្ចឹងតើសេចក្តីជំនឿ និងភាពបរិសុទ្ធនោះបានមកពីណា? អញ្ចឹងមានតែមកពីខ្លួនពួកគេ? តើនេះគឺជាសេចក្តីកំសាន្តចិត្តពង្រីកដែលអ្នកផ្តល់ឲ្យ ដើម្បីបញ្ចូនយើងចេញពីព្រះគុណដ៏វិសេស

របស់ព្រះ ទៅកាន់ឆន្ទៈ “សេរី” របស់យើងវិញឬ? តើអ្នកនឹងបញ្ជូនព្រលឹងដែលចង់បានសេចក្ដីជំនឿ និងភាពបរិសុទ្ធទៅឯណា? តើអ្នកនឹងមិនបញ្ជូនគេទៅឯព្រះដែលបានប្រទានព្រះគុណទាំងអស់នោះមកដោយឥតគិតថ្លៃ តាមរយៈការដែលព្រះគ្រីស្ទរកបាន ទេឬអី?

ប៉ុន្តែ គេនិយាយយ៉ាងដូច្នេះថា គ្មាននរណាម្នាក់អាចប្រាកដថា ព្រះគ្រីស្ទបានសុគតសម្រាប់ខ្លួននោះទេ លុះត្រាតែព្រះគ្រីស្ទបានសុគតសម្រាប់មនុស្សទាំងអស់។

យើងសូមឆ្លើយថា ការនិយាយនេះពិតជាខុសហើយ ដ្បិតអ្នកជឿជាច្រើនបានដឹងយ៉ាងច្បាស់ថា ព្រះគ្រីស្ទបានសុគតសម្រាប់ពួកគេ ទោះជាពួកគេមិនជឿថាទ្រង់បានសុគតសម្រាប់មនុស្សទាំងអស់ក៏ដោយ! មូលដ្ឋាននៃការដឹងជាប្រាកដច្បាស់គឺជាសេចក្ដីពិតដែលព្រះគ្រីស្ទបានសុគតសម្រាប់អ្នកជឿទាំងអស់។ ទ្រង់បានសុគតសម្រាប់ពួកគេ មិនមែនដោយព្រោះពួកគេជឿទេ តែពួកគេជឿដោយព្រោះទ្រង់បានសុគតជំនួសពួកគេវិញ។ ទ្រង់បានសុគតសម្រាប់ពួករើសតាំង។ តាមរយៈអត្ថប្រយោជន៍ពីការសុគតរបស់ព្រះគ្រីស្ទ ពួកគេបានក្លាយជាអ្នកជឿ។

ពួកគេដឹង តាមរយៈកិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធដែលនៅក្នុងពួកគេម្នាក់ៗ។ ពួកគេបានមកឯព្រះគ្រីស្ទដោយស្មោះត្រង់ដើម្បីទទួលសេចក្ដីមេត្តាករុណា។ ពួកគេដឹងបទគម្ពីរប្រកាសថា ការសុគតរបស់ព្រះគ្រីស្ទ គឺគ្រប់គ្រាន់សម្រាប់មនុស្សទាំងអស់ដែលមកឯទ្រង់។ ហើយដោយព្រោះពួកគេដឹងថាពួកគេជាអ្នកជឿ នោះពួកគេអាចនឹងដឹងថា ព្រះគ្រីស្ទបានសុគតសម្រាប់ពួកគេហើយ។

ឥឡូវនេះ ចូរបងប្អូនអ្នកអានវិនិច្ឆ័យដោយខ្លួនឯងចុះ ថាតើមូលដ្ឋានគ្រឹះនៃការដឹងប្រាកដច្បាស់ខាងក្រោមនេះ ប្រសើរជាងការរែកញែកខុសឆ្គងឬទេ?

ព្រះគ្រីស្ទបានសុគតសម្រាប់មនុស្សទាំងអស់ (រួមទាំងអ្នកបាត់បង់ដែរ)

ខ្ញុំជាមនុស្សម្នាក់

ដូច្នេះ តើទ្រង់បានសុគតសម្រាប់ខ្ញុំឬ?

សម្រាប់ជាការរំលែកញ្ញែកចុងក្រោយ សូមបងប្អូនអ្នកអាន សិក្សាព្រះគម្ពីររ៉ូម ៨:៣២-៣៩។ ខ្ញុំមិនសង្ស័យទេក្នុងការដែលគាត់បាននិយាយថា រាល់សេចក្ដីកំសាន្ត ចិត្តខាងវិញ្ញាណដែលរកបានមក គឺមាននៅក្នុងតែព្រះលោហិតព្រះយេស៊ូវដែល បានហូរ ហើយនៅក្នុងការអង្វរជំនួសរបស់ទ្រង់ប៉ុណ្ណោះ។ ការទាំងពីរនេះគឺ សម្រាប់ពួករើសតាំងរបស់ព្រះ ដើម្បីឲ្យពួកគេទទួលបានមកុដនៃសិរីរុងរឿងដ៏ អស់កល្បជានិច្ច ដែលមិនចេះសាបសូន្យ។